ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION, YOUTH AND SPORT



វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# ប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដោយផ្តោតលើការសិក្សារបស់សិស្សក្នុងខេត្តកំពង់ស្ពឺ

# THE EFFECTIVENESS OF MANAGING COMMUNITY LEARNING CENTER ON STUDENT-BASED LEARNING IN KAMPONG SPEU PROVINCE, CAMBODIA.


ដោយ/By

ម៉េត សិរី/ METH SEREY


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

# ក្រសួងអប់រំ យុវជន និងកីឡា

# MINISTRY OF EDUCATION, YOUTH AND SPORT

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដោយផ្ដោតលើការសិក្សារបស់សិស្សក្នុងខេត្តកំពង់ស្ពឺ

# THE EFFECTIVENESS OF MANAGING COMMUNITY LEARNING CENTER ON STUDENT-BASED LEARNING IN KAMPONG SPEU PROVINCE, CAMBODIA.

ដោយ/BY

**ម៉េត សិរី/ METH SEREY**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

គ្រូដឹកនាំបន្ទោល៖ បណ្ឌិត ឈាង សទ្ធាត

គ្រូដឹកនាំរង៖ លោក សៀង វាសនា

# សេចក្ដីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមធ្វើការបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "ប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដោយផ្ដោតលើការសិក្សារបស់សិស្ស" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុងប្រាកដមែន។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សា សម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជា បានសិក្សាស្រាវជ្រាវចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ហត្ថលេខាបេក្ខជន**

**ម៉េត សិរី**

# លិខិតបញ្ជាក់

**បណ្ឌិត ឈាង សទ្ធាត** គ្រូដឹកនាំបង្គោល

**លោក សៀង ឋាសនា** គ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ម៉ែត សរី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដោយផ្ដោតលើការសិក្សារបស់សិស្សក្នុងខេត្តកំពង់ស្ពឺ**" ប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**លោកបណ្ឌិត ឈាង សទ្ធាត**
គ្រូឧទ្ទេស
វិទ្យាស្ថានជាតិអប់រំ

**លោក សៀង ឋាសនា**
គ្រូឧទ្ទេស
វិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៣០៧ **អយក.ឧទ**

(**ការសម្គាល់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ិន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ច័ន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ តុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះ **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ លោក/លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន ចែករំលែកបទពិសោធន៍ដល់ខ្ញុំបាទ ក៏ដូចជាមិត្តភក្តិទាំងអស់គ្នា។ សូមថ្លែងអំណរគុណដល់ **លោក ថន ថារិន** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក គណៈគ្រប់គ្រង លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស និង សហគមន៍ នៅមជ្ឈមណ្ឌលសិក្សាសហគមន៍ក្នុងខេត្តកំពង់ស្ពឺ ដែលបានចូលរួមសហការក្នុងការប្រមូលទិន្នន័យតាមកម្រងសំណួរនៅខេត្តកំពង់ស្ពឺ ធ្វើឱ្យការសិក្សាស្រាវជ្រាវសម្រេចបានលទ្ធផលល្អប្រសើរ និងទាន់ពេលវេលា។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណ ចំពោះ**លោកបណ្ឌិត ឈាង សង្វាត** សាស្ត្រាចារ្យដឹកនាំបង្គោលក្នុងដឹកនាំដំណើរការសរសេរនិក្ខេបបទ ពន្យល់ណែនាំលើខ្លឹមសាររួម បង្ហាញជាផែនទីគំនិត និងចំណេះដឹងល្អៗ ព្រមទាំងបទពិសោធន៍នានា ជំរុញដល់លទ្ធផលនៃការសរសេរនិក្ខេបបទរបស់ខ្ញុំបាទទទួលបានជោគជ័យ និង ធានាបាននូវគុណភាពនៃការបណ្តុះបណ្តាល។ ខ្ញុំបាទក៏សូមអរគុណដល់ **លោក សៀង វាសនា** ជាគ្រូដឹកនាំរង ដែលតែងតែផ្តល់កិច្ចគាំទ្រ ចំណេះដឹង និងចែករំលែកបទពិសោធន៍ជាច្រើន ដល់រូបខ្ញុំបាទ រហូតដល់សម្រេចបានជាលទ្ធផលល្អប្រសើរ។

ខ្ញុំបាទសូមថ្លែងនូវការដឹងគុណ និងសេចក្តីស្រឡាញ់អស់ពីបេះដូង ចំពោះក្រុមគ្រួសារ លោកពុក អ្នកម្តាយ ពូមីង បងប្អូន ពិសេសឧត្តមភរិយា **ហេង សុខនី** ដែលបានផ្តល់ការគាំទ្រជានិច្ច តែងតែលើកទឹកចិត្តរហូតមក និងផ្តល់ឱកាសឱ្យរូបខ្ញុំបាទបានបន្តការសិក្សារហូតដល់ចប់សព្វគ្រប់ តាមក្តីប្រាថ្នា។

***សូមអរគុណ!***

# មាតិកា


**សេចក្ដីប្រកាសអះអាងរបស់បេក្ខជន** ............ i

**លិខិតបញ្ជាក់** ............ ii

**សេចក្ដីថ្លែងអំណរគុណ** ............ iv

**បញ្ជីតារាង** ............ viii

**បញ្ជីរូបភាព** ............ ix

**បញ្ជីអក្សរកាត់** ............ x

**មូលន័យសង្ខេប** ............ xi

**ជំពូកទី១** ............ 1

**សេចក្ដីផ្ដើម** ............ 1

១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ............ 1

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ............ 5

១.៣.គោលបំណងនៃស្រាវជ្រាវ ............ 6

១.៤. សំណួរស្រាវជ្រាវ ............ 6

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ............ 6

១.៦. វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ ............ 7

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ 7

**ជំពូកទី២** ............ 9

**រំឭកទ្រឹស្ដី** ............ 9

២.១. ព័ត៌មានការអប់រំបច្ចេកទេស មសស នៅខេត្តកំពង់ស្ពឺ ............ 9

២.២ និយមន័យ ............ 10

២.៣ ផែនការយុទ្ធសាស្ត្រអប់រំ (ESP) ឆ្នាំ ២០១៩-២០២៣ ............ 10

២.៤ គោលនយោបាយស្ដីពីការអប់រំបច្ចេកទេស ............ 11

២.៥ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ............ 11

២.៦ គោលនយោបាយការអប់រំក្រៅប្រព័ន្ធ ............ 13

២.៧ ផែនការគោលសម្រាប់ការអប់រំបច្ចេកទេស ............ 14

២.៨ គោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ............ 14

២.៩ ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ របស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ....... 16
២.១០. មុខងារ និង តួនាទី របស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ( មសស) ....... 17
២.១១ ក្របខណ្ឌវាយតម្លៃស្ថានភាពដំណើរការរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ....... 19
**ជំពូកទី៣** ....... 22
**វិធីសាស្ត្រស្រាវជ្រាវ** ....... 22
៣.១. គម្រោងវិភាគ ....... 22
៣.២ ការប្រមូលទិន្នន័យ ....... 22
៣.៣ ឧបករណ៍ស្រាវជ្រាវ ....... 23
៣.៤ ការជ្រើសរើសភាគសំណាក ....... 28
៣.៥ ការវិភាគទិន្នន័យ ....... 29
**ជំពូកទី៤** ....... 31
**លទ្ធផល និងការពិភាក្សា** ....... 31
៤.១. ទិន្នន័យព័ត៌មានទូទៅពីគណៈគ្រប់គ្រង គ្រូជំនាញ សិស្ស និង សហគមន៍ ....... 31
៤.១.១.ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង ....... 31
៤.១.២.ព័ត៌មានទូទៅរបស់គ្រូ ....... 32
៤.១.៣ ព័ត៌មានទូទៅរបស់សិស្ស ....... 32
៤.១.៤.ព័ត៌មានទូទៅរបស់សហគមន៍ ....... 33
៤.២ ប្រសិទ្ធភាពគ្រប់គ្រងការអប់រំបច្ចេកទេស នៅសហគមន៍ មសស ខេត្តកំពង់ស្ពឺ ....... 33
៤.២.១ ទិន្នន័យគណៈគ្រប់គ្រងឆ្លើយតបពីប្រសិទ្ធភាពនៃការគ្រប់គ្រង មសស ....... 33
៤.២.២ ទិន្នន័យពីលោកគ្រូ អ្នកគ្រូឆ្លើយតបនឹង ប្រសិទ្ធភាពនៃការគ្រប់គ្រង ....... 39
៤.២.៣ ទិន្នន័យឆ្លើយតបពីសិស្ស លើការអប់រំបណ្តុះបណ្តាលបច្ចេកទេស ....... 45
៤.២.៤ ទិន្នន័យឆ្លើយតបពីសហគមន៍ លើឥរិយាបថបំពេញការងាររបស់សិស្ស ....... 48
៤.៣ ការពិភាក្សាពីប្រសិទ្ធភាពគ្រប់គ្រងការអប់រំបច្ចេកទេស នៅសហគមន៍ មសស ....... 49
៤.៤. បញ្ហាប្រឈមក្នុងការគ្រប់គ្រង មសស នៅសហគមន៍ខេត្តកំពង់ស្ពឺ ....... 54
៤.៤.១ ទិន្នន័យពីការឆ្លើយតបរបស់គណៈគ្រប់គ្រង ....... 54
៤.៤.២.ទិន្នន័យពីការឆ្លើយតបរបស់លោកគ្រូ អ្នកគ្រូបង្រៀនបច្ចេកទេស ....... 56
៤.៤.៣ ទិន្នន័យគុណវិស័យពីសហគមន៍ និង ពីសិស្ស ....... 57

៤.៥ ការពិភាក្សាពីបញ្ហាប្រឈមក្នុងការគ្រប់គ្រង មសសនៅសហគមន៍ខេត្តកំពង់ស្ពឺ ..... 60
**ជំពូកទី៥** ..... 65
**សេចក្តីសន្និដ្ឋាន និងសំណូមពរ** ..... 65
៥.១ សេចក្តីសន្និដ្ឋាន ..... 65
៥.២ សំណូមពរ ..... 66
ក. ក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ..... 67
ខ. គណៈគ្រប់គ្រង និងគ្រូបង្រៀនការអប់រំបច្ចេកទេស ..... 67
គ. សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត ..... 68
**ឯកសារយោង** ..... 69

# បញ្ជីតារាង


| ល.រ | បរិយាយ | ទំព័រ |
|---|---|---|
| ១.១ | ស្ថិតិ មសស ទូទាំងប្រទេស និង ចំនួនអ្នកសិក្សាជំនាញ | 4 |
| ៣.១ | ចំនួនភាគសំណាកដែលបានទទួលទិន្នន័យពីកម្រងសំណួរ | 29 |
| ៤.១ | ការរៀបចំផែនការរបស់គណៈគ្រប់គ្រង | 34 |
| ៤.២ | កសាងសមត្ថភាពគ្រូ របស់គណៈគ្រប់គ្រង | 35 |
| ៤.៣ | កសាងសមត្ថភាពសិស្សរបស់គណៈគ្រប់គ្រង | 36 |
| ៤.៤ | ភាគីពាក់ព័ន្ធរបស់គណៈគ្រប់គ្រង | 36 |
| ៤.៥ | ធនធានរូបវន្តរបស់គណៈគ្រប់គ្រង | 37 |
| ៤.៦ | ការជានាគុណភាពរបស់គណៈគ្រប់គ្រង | 38 |
| ៤.៧ | សរុបគណៈគ្រប់គ្រងពីប្រសិទ្ធភាពនៃការគ្រប់គ្រង | 39 |
| ៤.៨ | ការងារគ្រប់គ្រង និងដឹកនាំ ឆ្លើយតបពីគ្រូបង្រៀន | 40 |
| ៤.៩ | ការងារកសាងសមត្ថភាពគ្រូ ឆ្លើយតបពីគ្រូបង្រៀន | 40 |
| ៤.១០ | តារាងទិន្នន័យ ការងាររបស់ថ្នាក់ដឹកនាំ ឆ្លើយតបពីគ្រូបង្រៀន | 41 |
| ៤.១១ | ភាគីពាក់ព័ន្ធឆ្លើយតបពីគ្រូបង្រៀន | 42 |
| ៤.១២ | ធនធានរូបវន្តឆ្លើយតបពីគ្រូបង្រៀន | 43 |
| ៤.១៣ | ការជានាគុណភាព របស់ថ្នាក់ដឹកនាំឆ្លើយតបពីគ្រូបង្រៀន | 44 |
| ៤.១៤ | សរុប លោកគ្រូ អ្នកគ្រូ ឆ្លើយតបនឹងប្រសិទ្ធភាពនៃការគ្រប់គ្រង | 44 |
| ៤.១៥ | អំពីមេរៀន ឆ្លើយតបពីសិស្ស | 45 |
| ៤.១៦ | ការបង្រៀនរបស់គ្រូឆ្លើយតបពីសិស្ស | 46 |
| ៤.១៧ | ការសិក្សារៀនសូត្រឆ្លើយតបពីសិស្ស | 47 |
| ៤.១៨ | សរុបរបស់សិស្ស លើការអប់រំបណ្តុះបណ្តាលបច្ចេកទេស | 47 |
| ៤.១៩ | ឆ្លើយតបពីសហគមន៍ លើឥរិយាបថបំពេញការងាររបស់អតីតសិស្សក្នុងការ | 48 |
| ៤.២០ | សរុបពីគណៈគ្រប់គ្រង គ្រូបង្រៀន សិស្ស និងសហគមន៍ | 50 |
| ៤.២១ | ដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រង | 54 |
| ៤.២២ | ពីការយល់ឃើញរបស់គ្រូបង្រៀនចំពោះការងារគ្រប់គ្រង | 56 |
| ៤.២៣ | សរុបពីគណៈគ្រប់គ្រង គ្រូបង្រៀន បំពេញការងារលើដំណើរការប្រតិបត្តិ | 61 |

# បញ្ជីរូបភាព


| ល.រ | បរិយាយ | ទំព័រ |
|---|---|---|
| ២.១ | គំនូសប្រៀបធៀបរវាងសាលារៀន និងមសស | 19 |

# បញ្ជីអក្សរកាត់

| | |
|---|---|
| មសស | : មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| APPEAL | : Asia Pacific Program of Education for All |
| CLC | : Community Learning Center |
| CBL | : Community Based Learning |
| DNFE | : Department of Non-Formal Education |
| EFA | : Education for All |
| ESP | : Education Sector Plan |
| FDI | : Foreign Direct Investment |
| GDP | : Gross Domestic Product |
| GOs | : Governmental Organizations |
| Moeys | : Ministry of Education Youth and Sport |
| NGO | : Non-Governmental Organizations |
| NFE | : Non-Formal Education |
| NFUAJ | : National Federation of UNESCO Associations in Japan |
| UNESCO | : United Nation Educational, Scientific & Cultural Organization |
| SD | : Standard Deviation |

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវពី "ប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដោយផ្តោត លើការសិក្សារបស់សិស្សក្នុងខេត្តកំពង់ស្ពឺ" មានគោលបំណងសិក្សាស្វែងយល់ពីប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍និងបញ្ហាប្រឈមនានាលើការងារគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ពីការបណ្តុះបណ្តាលអប់រំបច្ចេកទេសក្នុងខេត្តកំពង់ស្ពឺ។

វិធីសាស្ត្រស្រាវជ្រាវគឺប្រើប្រាស់កម្រងសំណួរតាមបែបបរិមាណវិស័យដោយបន្សីគ្នាជាមួយសំណួរស្រាវជ្រាវទាំងពីរ នៃប្រធានបទដែលលើកយកមកសិក្សា។ ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរក្នុងចំនួន ២៤ មជ្ឈមណ្ឌលសិក្សាសហគមន៍នៅខេត្តកំពង់ស្ពឺ ដែលមានចំនួនសំណាកសរុប ១៥១នាក់ បែងចែកជា៤ប្រភេទ៖ គណៈគ្រប់គ្រង៣៥នាក់ គ្រូបង្រៀន៣១នាក់ សិស្ស៧០នាក់ និងតំណាងខាងសហគមន៍ ១៥នាក់។ ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយតាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ព្រមទាំងគណនាតាមរូបមន្តកំណត់ជាក់លាក់។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដោយផ្តោត លើការសិក្សារបស់សិស្សក្នុងខេត្តកំពង់ស្ពឺ។ ការអនុវត្តលើការងារ ដឹកនាំ និងគ្រប់គ្រងពិតជាមានសារៈសំខាន់ណាស់ចំពោះការងារអប់រំបច្ចេកទេសនៅ មសស ដើម្បីលើកកម្ពស់ការបណ្តុះបណ្តាលជំនាញឱ្យមានប្រសិទ្ធភាពនិងគុណភាព សម្រាប់អ្នកសិក្សាគ្រប់រូប។ ប្រសិទ្ធភាពទាំងនេះអាចសម្រេចទៅបានតាមផែនការកំណត់ ក៏តម្រូវឱ្យគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សផ្តោតការយកចិត្តទុកដាក់ទៅលើការអនុវត្តការងារជាប្រចាំតាមផែនការ និង ការអនុវត្តការងារតាមតួនាទីភារកិច្ចជាប្រចាំផងដែរ ពីព្រោះការងារគ្រប់គ្រងដែលមានប្រសិទ្ធភាពអាចទទួលបានលទ្ធផលជាវិជ្ជមានឬអវិជ្ជមាន អាស្រ័យលើការចូលរួមពីសំណាក់ គណៈកម្មការគ្រប់រូបរបស់ មសស ដោយផ្តោតលើលទ្ធផលនិងការសិក្សានិងគុណភាពជំនាញរបស់សិស្សគ្រប់រូបពេលរៀនចប់វគ្គផងដែរ។ ដោយឡែកទាក់ទងទៅនឹងផ្នែកកិច្ចការងារជាមួយភាគីពាក់ព័ន្ធ និងការកសាងធនធានរូបវន្តក៏ត្រូវតែពង្រឹង និង បំពេញទៅតាមផែនការសកម្មភាពដែលបានកំណត់ សំដៅលើកកម្ពស់កិច្ចការងារអប់រំបច្ចេកទេសកាន់តែមានប្រសិទ្ធផល

និងប្រសិទ្ធភាពខ្ពស់ ។ បញ្ហាប្រឈមដែលបានលើកឡើង គឺពិតជារាំងស្ទះដល់ដំណើរ ព្រមទាំងប៉ះពាល់ដល់ការអនុវត្តការងារគ្រប់គ្រង គុណភាពនិងប្រសិទ្ធភាព នៃការអប់រំបច្ចេកទេសតាមរយៈលទ្ធផលការសិក្សារបស់សិស្សផងដែរ។ ការផ្តល់ការគាំទ្រកញ្ចប់ថវិកាមួយសមស្របនឹងតាមតម្រូវការចាំបាច់ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការគាំទ្រដំណើរការរបស់ មសស គឺជាយន្តការមួយដើម្បីពង្រឹងការធានាគុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបច្ចេកទេសដែលឆ្លើយតបទៅនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា កំណែទម្រង់របស់រាជរដ្ឋាភិបាល លើការងារអប់រំបច្ចេកទេសជំនាញដល់ប្រជាពលរដ្ឋក្នុងសហគមន៍ដែលជាកម្លាំងពលកម្មបម្រើដល់ វិស័យសេដ្ឋកិច្ចជាតិ សង្គមជាតិ ឈានទៅរកភាពរុងរឿង និងរីកចម្រើន។

ជារួមប្រសិទ្ធភាពនៃការគ្រប់គ្រង មសស ជាវិជ្ជមាន ចំពោះការអប់រំបច្ចេកទេសជំនាញ បានគ្រប់ជ្រុងជ្រោយ និងបានបង្ហាញពីកម្រិតល្អប្រសើរនៃការអនុវត្តការងារព្រមទាំងបង្កលទ្ធភាព និងឱកាសល្អប្រសើរចំពោះការសិក្សាលើការងារអប់រំបច្ចេកទេស ដែលស្របតាមគោលនយោបាយអប់រំក្រៅប្រព័ន្ធ គោលនយោបាយអប់រំបច្ចេកទេស គោលនយោបាយអប់រំពេញមួយជីវិត គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបន្តអភិវឌ្ឍន៍ការងារមជ្ឈមណ្ឌលសិក្សាសហគមន៍ជាប្រចាំ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពភាពស័ក្តិសិទ្ធិក្នុងការងារគ្រប់គ្រង មសស ខេត្តកំពង់ស្ពឺ។ គណៈគ្រប់គ្រង មសស គួរមានយន្តការពង្រឹងសមត្ថភាពលើការងារគ្រប់គ្រងផ្អែកលើលទ្ធផល ដើម្បីធានាគុណភាព និងភាពស័ក្តិសិទ្ធិនៃការងារគ្រប់គ្រងស្ថាបន ស្របតាមគោលនយោបាយទី២ របស់ក្រសួងអប់រំ យុវជន និងកីឡា។

# ជំពូកទី១
# សេចក្ដីផ្ដើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងពិភពលោកនិងតំបន់ ការអភិវឌ្ឍន៍ជំនាញមានការរីកចម្រើនយ៉ាងឆាប់រហ័សដោយសារមានការយល់ឃើញថាវាជាកត្តាមួយចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ច ។ ការផ្លាស់ប្ដូរត្រូវបានគាំទ្រតាមរយៈគោលនយោបាយក្នុងការអភិវឌ្ឍជំនាញដែលជាទូទៅផ្ដែកលើតម្រូវការនិងបានដាក់បញ្ចូលទៅគ្រប់ក្រសួង ព្រមទាំងស្ថាប័នពាក់ព័ន្ធទាំងអស់ដែលផ្ដល់ការបណ្ដុះបណ្ដាល ។

ក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលគឺសំដៅធានាថា( យុវជនម្នាក់ មានជំនាញមួយយ៉ាងតិចប្រចាំជីវិត) ពិសេសដើម្បីជំរុញការអភិវឌ្ឍសង្គម សេដ្ឋកិច្ចឱ្យឈានឡើងមួយកម្រិតទៀត។ ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ធ្វើឡើងក្នុងរូបភាពពីរដែលមានការផ្សារភ្ជាប់គ្នា គឺធនធានមនុស្សនៅក្នុងប្រព័ន្ធអប់រំ និងធនធានមនុស្សនៅក្រៅប្រព័ន្ធអប់រំ ឬក្នុងទីផ្សារការងារ។

នៅក្នុងគោលដៅនេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលសំខាន់ៗជាអាទិ៍ បានអនុវត្តគោលនយោបាយជាតិស្ដីពី ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥ ។ ការបន្តជំរុញគឺសំដៅលើកកម្ពស់ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ពិសេសកម្រិតមធ្យមនិងកម្រិតខ្ពស់ដល់យុវជនដោយគ្របដណ្ដប់មុខវិជ្ជាពហុជំនាញ ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម វិស័យឧស្សាហកម្ម និងការចាប់ផ្ដើមធុរកិច្ចថ្មី( Cambodia Goverment, 2019 )។

ការអប់រំបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍធនធានមនុស្ស និងជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការអប់រំតាមគ្រប់រូបភាពទាំងក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ ជាមធ្យោបាយ ស័ក្តិសិទ្ធិក្នុងការធានាឱ្យការសិក្សាមានគុណភាពប្រកបដោយ សមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាស សិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ( Lifelong Learning/Moeys Cambodia, 2019 )។

គោលនយោបាយស្ដីពីការងារអប់រំក្រៅប្រព័ន្ធរបស់រាជរដ្ឋាភិបាលឆ្នាំ ២០០២ បានកំណត់ថាៈ ការងារអប់រំក្រៅប្រព័ន្ធ ជាប្រព័ន្ធអប់រំផ្លូវការមួយនៃព្រះរាជាណាចក្រកម្ពុជាដូចជាការអប់រំក្នុងប្រព័ន្ធដែរ ។

ក្នុងគោលដៅ EFA ឆ្នាំ២០១៥ អប់រំក្រៅប្រព័ន្ធដើរតួនាទីយ៉ាងសំខាន់ ក៏ដូចជាប្រព័ន្ធអប់រំ ផ្លូវការដែរ ហើយដើម្បីបំពេញតម្រូវការ ដល់ប្រជាពលរដ្ឋ ជាពិសេស កុមារ និង យុវជនក្រីក្រ និង ក្រុមមនុស្សងាយរងគ្រោះ ដែលបាត់បង់ឱកាសសិក្សា ដែលគ្មានលទ្ធភាពចូលរៀនក្នុងប្រព័ន្ធ ឱ្យបានទទួល សេវាអប់រំផ្លូវការ ។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០ " ធានាបាននូវការអប់រំ ប្រកបដោយគុណភាព និងសមធម៌ និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់មនុស្សទាំងអស់" ហើយដែល បានកំណត់របៀបវារៈ ការអប់រំសកល ដែលមានរយៈពេលពីឆ្នាំ២០១៥ ដល់ឆ្នាំ២០៣០ ដើម្បីសម្រេចគោលដៅនៅឆ្នាំ២០៣០។

ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់វិស័យអប់រំ ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់កំណើនការងារ សំដៅជំរុញសេដ្ឋកិច្ចកម្ពុជាឱ្យឈានឆ្ពោះទៅរកប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ។ កំណែទម្រង់វិស័យអប់រំបានផ្តោតជាសំខាន់ទៅលើការលើកកម្ពស់គុណភាពអប់រំ ដោយធ្វើយ៉ាងណាឱ្យឆ្លើយតបទៅនឹង គោលដៅអភិឌ្ឍន៍ប្រកបដោយចីរភាព ។ ក្នុងនោះដែរក្រសួងអប់រំបានធ្វើកំណែទម្រង់ជាច្រើនចំណុចក្នុងអាណត្តិនេះមាន កំណែទម្រង់ការប្រឡងនៅមធ្យមសិក្សាទុតិយភូមិ កំណែទម្រង់កម្មវិធីសិក្សា កំណែទម្រង់គុណភាពសិក្សាលើផ្នែកបំណិនវិជ្ជាជីវៈនៅ តាមវិទ្យាល័យវិជ្ជាជីវៈ និង តាមមូលដ្ឋាននានា។ ឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដោយចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ ក្រសួងអប់រំ យុវជន និងកីឡាប្តេជ្ញាសម្រេចឱ្យបាននូវមុំទី១ ស្តីពី "ការពង្រឹងគុណភាពអប់រំវិទ្យាសាស្ត្រ និងបច្ចេកទេស" ។ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ គោលនយោបាយអប់រំ ចំនួនពីរគឺ (១) ធានាការអប់រំ ឱ្យមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងការលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា (២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ និងបានផ្តោតអាទិភាពលើះ (១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន (២). ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត (៣). ការពង្រឹង អធិការកិច្ចគ្រប់ជ្រុងជ្រោយ

លើការគ្រប់គ្រងសាលារៀន (៤).ការជំរុញការអប់រំបច្ចេកទេស នៅមធ្យមសិក្សាទុតិយភូមិ (៥). ការអប់រំបំណិនជីវិតឱ្យស្របតាមទីផ្សារការងារ (៦). ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅគោលគ្រប់ជ្រុងជ្រោយ និង (៧). ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ ២០២៣ ។

កម្ពុជាបានឈានមកដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍន៍វិស័យអប់រំ ដើម្បីឆ្លើយតបនឹងបរិបទសកលលោក តំបន់ ដែលមានមហិច្ឆតា និងវិសាលភាពធំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិតក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើគ្រប់ប្រភេទនិងគ្រប់កម្រិតនៃការអប់រំជាពិសេសស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ។ ស្របពេលដែលកម្ពុជាទទួលបានសមិទ្ធផលអប់រំនិងបទពិសោធន៍ជាច្រើនពីការអនុវត្តគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍ និងផែនការអប់រំសម្រាប់ទាំងអស់គ្នា(EFA) ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ឈានទៅ សម្រេចការអប់រំប្រកបដោយចីរភាពនៅឆ្នាំ២០៣០ខាងមុខ ។ ការអប់រំសម្រាប់ឆ្នាំ២០៣០ ផ្តោតសំខាន់លើការផ្តល់សេវាប្រកបដោយគុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេសការសិក្សាពេញមួយជីវិត ដែលការងារអប់រំក្រៅប្រព័ន្ធជាអ្នកអនុវត្តផ្ទាល់ ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារស្របតាម យុគ្គសម័យបច្ចេកវិទ្យាក្នុងការបង្កើនសេដ្ឋកិច្ចនិងសុខដុមជីវិតបុគ្គលនិងសង្គមជាតិ (Moeys, Roadmap 2030, 2019)។

ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ក្រសួងអប់រំ បានពង្រីកការងារអប់រំក្រៅប្រព័ន្ធ ឱ្យទូលំទូលាយដល់តំបន់ដាច់ស្រយាល ក្រោមកិច្ចសហការជាមួយអាជ្ញាធរដែនដី និង ដៃគូអភិវឌ្ឍន៍ ដើម្បីចូលរួមសកម្មភាពនានាដោយផ្តោតលើ អក្ខរកម្មមនុស្សពេញវ័យ កម្មវិធីបង្កើនប្រាក់ចំណូល (មសស) កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូលបឋមសិក្សា កម្មវិធីក្រោយអក្ខរកម្ម ដែលនាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកទទួលខុសត្រូវ និងអនុវត្តជាមួយមន្ទីរអប់រំយុវជន និងកីឡាតាមបណ្តាខេត្តទាំង ២៥ ក្នុងប្រទេសកម្ពុជា។ គំនិតផ្តួចផ្តើមមួយចំនួនដូចជា គម្រោងមជ្ឈមណ្ឌលសិក្សា

សហគមន៍ មសស ។ មសស បង្កើតឡើងដោយសហគមន៍ គ្រប់គ្រងដោយសហគមន៍ និងទទួលផល ដោយប្រជាពលរដ្ឋក្នុងសហគមន៍ ។ ការគ្រប់គ្រង មសស ជាកម្មសិទ្ធិ របស់ប្រជាជនសហគមន៍ ដែល ដំណើរការ ឬគ្រប់គ្រង ដោយគណៈកម្មការសហគមន៍ និងសកម្មភាពទាំងអស់ដែលផ្តល់ ប្រយោជន៍ដល់ ប្រជាជនសហគមន៍ទាំងអស់។

មសស ដំបូងបង្អស់ត្រូវបានបង្កើតឡើងក្នុងរដ្ឋាភិបាលឆ្នាំ ១៩៩៤ នៅក្នុងខេត្តចំនួនបី (សៀមរាប, បាត់ដំបង, និងខេត្តកណ្តាល) ដែលគាំទ្រដោយ យូណេស្កូភ្នំពេញ និងសហព័ន្ធជាតិ នៃ សមាគមយូណេស្កូនៅប្រទេសជប៉ុន (NFUAJ) ។ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ (DNFE) បន្ទាប់មក បាន ផ្តួចផ្តើមគម្រោងសាកល្បងពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០១ នៅខេត្តចំនួនបីផ្សេងទៀត (តាកែវ កំពង់ស្ពឺ និង កំពង់ធំ) ក្រោមការឧបត្ថម្ភ APPEAL CLCs នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ DNFE បានទទួលយក គម្រោង មសស ហើយបានពង្រីកការគាំទ្រដល់ មសស ជារៀងរាល់ឆ្នាំ (Nipun, 2008)។

នៅឆ្នាំ ២០០៨ ក្រសួងអប់រំ យុវជន និងកីឡា ដែលគាំទ្រដោយអង្គការយូណេស្កូភ្នំពេញ បាន បង្កើតសៀវភៅ ណែនាំសម្រាប់គណៈកម្មាធិការគ្រប់គ្រង មសស សៀវភៅណែនាំនេះកំពុង កែលម្អ ដើម្បី ឆ្លើយតបនឹងតម្រូវការបច្ចុប្បន្ន។ សៀវភៅណែនាំដែលបានកែសម្រួលនេះក៏ រួមបញ្ចូល ទាំងការ អនុវត្តក្នុង ប្រទេសកម្ពុជា និងបណ្តាប្រទេសក្នុងតំបន់ ។

| លំដាប់ឆ្នាំ | ចំនួន មសស | ចំនួនអ្នកសិក្សា | |
|---|---|---|---|
| | | សរុប | ស្រី |
| ២០១៧ | ៣៥០ | ៩ ០១៦ | ៦ ០៧៥ |
| ២០១៨ | ៣៥៦ | ១០ ១៩៩ | ៦ ៦៣៨ |
| ២០១៩ | ៣៥១ | ៩ ៣៧៧ | ៦ ០៦៤ |

តារាង១.១៖ ស្ថិតិ មសស ទូទាំងប្រទេស និង ចំនួនអ្នកសិក្សាជំនាញ (ប្រភព៖ ស្ថិតិ និង សូចនាករអប់រំ ក្រៅប្រព័ន្ធ ឆ្នាំ២០១៨ និង របាយការណ៍សន្និបាតអប់រំឆ្នាំ ២០១៨.២០១៩)

របាយការណ៍សន្និបាតអប់រំឆ្នាំសិក្សា ២០១៨-២០១៩ មសស ទូទាំងប្រទេសមាន ៣៥១កន្លែង និងបានបើកថ្នាក់ជំនាញចំនួន ៦០៩ មុខជំនាញ ដែលគ្រប់គ្រងដោយក្រសួងអប់រំចំនួន

៥៨៣ មុខជំនាញ និងដៃគូអភិវឌ្ឍន៍ចំនួន ២៦ មុខជំនាញ ។ គ្រូជំនាញមានចំនួន ៥៣៨ នាក់ ក្នុងនោះ គ្រូជំនាញ របស់ដៃគូអភិវឌ្ឍន៍ចំនួន ២៦ នាក់ ។ សិស្សរៀនជំនាញចំនួន ៩ ៣៧៧នាក់ ។ គណៈគ្រប់គ្រង មសស សរុបចំនួន ១ ៦៩៤នាក់ ក្នុងនោះដៃគូអភិវឌ្ឍន៍ ១៤៣នាក់ (NFE Indecator, 2018)។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

មសស ជាកម្មវិធីមួយរបស់ការងារអប់រំក្រៅប្រព័ន្ធ ត្រូវបានដាក់ឱ្យអនុវត្តទៅតាមសហគមន៍ ដើម្បីបង្រៀនជំនាញវិជ្ជាជីវៈខ្លីៗ ដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីអាចយកជំនាញទៅប្រកបរបរ ចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃ និងធ្វើឱ្យប្រសើរឡើងនៃគុណភាពរស់នៅរបស់ប្រជាជន។ លើសពីនេះ គឺដើម្បី សម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០១៥ និង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅឆ្នាំ២០៣០។ ទោះបីជា មសស នៅកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការជួយដល់ប្រជាពលរដ្ឋក្នុង សហគមន៍ ដើម្បីកែប្រែគុណភាពរស់នៅប្រចាំថ្ងៃក៏ដោយ ក៏នៅមានបញ្ហាប្រឈមជាច្រើនទៀតដូចជា៖

១. ស្ថានភាព និង ការគ្រប់គ្រងនៅតាម មសស នៅមិនទាន់ទទួលបានលទ្ធផល តាមការរំពឹង ទុក និងម្យ៉ាងទៀតដោយ សមាជិកគណៈកម្មការគ្រប់គ្រងលើការងារដឹកនាំ គ្រប់គ្រង និង សម្របសម្រួល នៅមានកម្រិត ជាងនេះទៅទៀត បច្ចេកទេសនៃការកសាងផែនការ និង ការដាក់ចំណុចដៅនៃសកម្មភាព របស់ មសស នៅតែជួបប្រទះជាញឹកញាប់លើការអនុវត្តកិច្ចការប្រចាំថ្ងៃ។

២. ការបើកថ្នាក់ជំនាញនីមួយៗដែលផ្តល់ទៅសិស្ស មិនសូវស្របនឹងទីផ្សារការងារបច្ចុប្បន្ន ដែលជាកត្តាមួយសំខាន់នាំឱ្យការសិក្សារបស់សិស្ស ពេលបញ្ចប់វគ្គបណ្តុះបណ្តាលពិបាករកការងារ។

៣. តាមរយៈការស្រាវជ្រាវ និងការពិនិត្យឡើងវិញនៃផែនការវិស័យអប់រំនៅប្រទេសចំនួន៧ ក្នុង ឆ្នាំ ២០១៥ របស់អង្គការយូណេស្កូ ទីក្រុងបាងកក បានបង្ហាញអំពីបញ្ហាប្រឈមរបស់ មសស ៖

ក. ការចូលរួមរបស់សហគមន៍និងភាពជាម្ចាស់នៅមានកម្រិត

ខ. ការសិក្សាជំនាញពួកគេមិនឆ្លើយតបទៅនឹង តម្រូវការផ្សេងៗរបស់សហគមន៍

គ. ការគាំទ្រផ្នែកហិរញ្ញវត្ថុធ្លាក់ចុះ និងមិនអាចទាយទុកជាមុន ដែលប៉ះពាល់ឥទ្ធិពលយ៉ាងខ្លាំង លើគុណភាពនៃកម្មវិធីសិក្សារបស់សិស្ស (UNESCO, CLC, 2016)។

សរុបមក មសស នៅកម្ពុជាមានដំណើរការបានត្រូវកំណត់លើកត្តាចំនួន ពីរ ដែលអាចឱ្យ មសស មាននិរន្តរភាពគឺ (១) ការគ្រប់គ្រងត្រូវមានប្រសិទ្ធភាព (២) បញ្ហាប្រឈមរបស់ មសស ពេលដំណើរការ ដែលមិនត្រូវនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ និង តម្រូវការទីផ្សារការងារ។

ដោយសង្កេតឃើញនូវបញ្ហានានាជាច្រើនទាក់ទងនឹងការអនុវត្តការងារគ្រប់គ្រង មសស ទើបអ្នកសិក្សាស្រាវជ្រាវលើកយក ប្រធានបទស្រាវជ្រាវមួយមកសិក្សាគឺ "**ប្រសិទ្ធភាពនៃការគ្រប់គ្រង មជ្ឈមណ្ឌលសិក្សាសហគមន៍ដោយផ្តោតលើការសិក្សារបស់សិស្ស**" **ក្នុងខេត្តកំពង់ស្ពឺ** ។

## ១.៣.គោលបំណងនៃស្រាវជ្រាវ

គោលបំណងនៃការសិក្សានេះធ្វើឡើងដើម្បីទទួលបាននូវការយល់ដឹងកាន់តែច្បាស់ពីការគ្រប់គ្រង មសស លើការងារអប់រំបច្ចេកទេសជំនាញជូនប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព និង សិក្សាពីផលប៉ះពាល់ផ្សេងៗរបស់កម្មវិធី មសស ដោយផ្តោតលើគោលបំណង សំខាន់ៗគឺ៖

**១. សិក្សាពីប្រសិទ្ធភាពនៃការគ្រប់គ្រងការអប់រំបច្ចេកទេស នៅមជ្ឈមណ្ឌលសិក្សាសហគមន៍**

**២. សិក្សាពីបញ្ហាប្រឈម ការអនុវត្តការអប់រំបច្ចេកទេសនៅមជ្ឈមណ្ឌលសិក្សាសហគមន៍**

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីសម្រេចគោលបំណងខាងលើ យើងបានកំណត់សំណួរដូចខាងក្រោម៖

១. តើការគ្រប់គ្រង មសស មានប្រសិទ្ធភាព យ៉ាងដូចម្តេចខ្លះ ដើម្បីប្រយោជន៍សហគមន៍ក្នុងខេត្តកំពង់ស្ពឺ?

២. តើ ការគ្រប់គ្រង មសស មានបញ្ហាប្រឈមអ្វីខ្លះដើម្បីរក្សាប្រយោជន៍សហគមន៍នៅខេត្តកំពង់ស្ពឺ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ក្នុងករណីសិក្សានេះ ក៏ផ្តល់នូវការយល់ដឹងជាក់ស្តែងសំខាន់ៗ ដើម្បីយល់ដឹងឱ្យកាន់តែស៊ីជម្រៅអំពីកម្រិតនៃដំណើរការអនុវត្តលើការងារអប់រំបច្ចេកទេស ដែលពាក់ព័ន្ធនឹង គុណភាព ប្រសិទ្ធភាពនៃការអនុវត្តការងារជាប្រចាំរបស់គណៈគ្រប់គ្រងលើការងារអប់រំបច្ចេកទេសនៅ មសស និងអាចផ្ទៀងផ្ទាត់ពី

កម្រិតជំនាញសិក្សារបស់សិស្សដែលរៀនជំនាញចប់ការអប់រំបច្ចេកទេស ដោយផ្តោតលើគុណភាព និង ប្រសិទ្ធផលនៃការអនុវត្តការងារសំដៅលើកកម្ពស់ប្រសិទ្ធភាពបន្ថែម ដើម្បីធានាផលិតបាននូវធនធានមនុស្សមួយដែលរាជរដ្ឋាភិបាលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ និងអាចដឹងពីផលប៉ះពាល់មួយចំនួនដែលជំរុញឬរាំងស្ទះដល់ដំណើរការអប់រំបច្ចេកទេស និងជាមូលដ្ឋានគ្រឹះដល់អ្នកបង្កើត គោលនយោបាយ ឬ លិខិតបទដ្ឋានគតិយុត្តផ្សេង របស់ការងារអប់រំក្រៅប្រព័ន្ធ។

## **១.៦. វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ**

( **សិក្សាលើ មសស ២៤ ក្នុងខេត្តកំពង់ស្ពឺ** )

ដើម្បីឱ្យការសិក្សាស្រាវជ្រាវទៅលើប្រធានបទបានល្អ និងវិភាគបានគ្រប់ជ្រុងជ្រោយទៅលើប្រធានបទ៖ ប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដោយផ្តោត លើការសិក្សារបស់សិស្សក្នុងខេត្តកំពង់ស្ពឺ ។ ការអប់រំបច្ចេកទេស គឺស្ថិតនៅក្រោមនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា។

ការស្រាវជ្រាវលើទិន្នន័យ មសស ដែលកំពុងដំណើរការបើកថ្នាក់ជំនាញ ទូទាំងខេត្តកំពង់ស្ពឺ ដែលមាន មសស ចំនួន ២៤កន្លែង ចំនួនសំណាកសរុប ១៥១នាក់ គណៈគ្រប់គ្រងចំនួន ៣៥នាក់ គ្រូចំនួន ៣១នាក់ សិស្សចំនួន ៧០នាក់ និងសហគមន៍ចំនួន ១៥នាក់។ អ្នកស្រាវជ្រាវបានកំណត់យកតែអ្នកពាក់ព័ន្ធមួយចំនួនតែប៉ុណ្ណោះគឺ គណៈគ្រប់គ្រង លោកគ្រូ-អ្នកគ្រូ សិស្សអប់រំបច្ចេកទេស និង សហគមន៍ និងមិនបានផ្តោតលើគ្រប់ទិដ្ឋភាពនៃ មសស ទាំងអស់នៅកម្ពុជាទេ។

## **១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវនេះចែកចេញជា៥ ជំពូកដូចខាងក្រោម

- ***ជំពូកទី១៖ សេចក្តីផ្តើម:*** ពណ៌នាដោយសង្ខេបទៅលើលំនាំបញ្ហា បញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- ***ជំពូកទី២៖ រំឭកទ្រឹស្តី:*** ធ្វើការបង្ហាញ និងពន្យល់យ៉ាងលម្អិតទៅលើទ្រឹស្តីទាំងឡាយដែលជាប់

ទាក់ទងទៅនឹងប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់គណៈគ្រប់គ្រង មសស ក្នុងខេត្តកំពង់ស្ពឺ។

- ❖ ***ជំពូកទី៣៖ វិធីសាស្រ្តនៃការស្រាវជ្រាវ:*** ជំពូកនេះលើកឡើងពីគម្រោងនៃការវិភាគ ការប្រមូលទិន្នន័យ ឧបករណ៍ស្រាវជ្រាវ ការជ្រើសរើសភាគសំណាក និងការវិភាគទិន្នន័យ។
- ❖ ***ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា:*** ជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការវិភាគយ៉ាងលម្អិតទៅលើកម្រង សំណួរសម្រាប់យកមកវិភាគទិន្នន័យ ធ្វើការបកស្រាយទិន្នន័យដែលប្រមូលបានជាក់ស្តែង ដើម្បីរកឱ្យឃើញពីប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់គណៈគ្រប់គ្រង មសស ក្នុងខេត្តកំពង់ស្ពឺ បញ្ហាប្រឈមនៃការគ្រប់គ្រង មសស ក្នុងខេត្តកំពង់ស្ពឺ ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ:** ធ្វើសេចក្តីសន្និដ្ឋាន ឆ្លើយតបទៅលើសំណួរស្រាវជ្រាវ ដោយបង្ហាញលទ្ធផលតាមរយៈទិន្នន័យដែលបានពីកម្រងសំណួរ និងការសង្ខេបខ្លឹមសារពិភាក្សា តាមរយៈការឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាន និង ចំណុចត្រូវកែលម្អ។ លើកសំណូមពរតាមរយៈ ប្រធានបទសិក្សា ដល់ភាគីពាក់ព័ន្ធ និងអ្នកសិក្សាស្រាវជ្រាវបន្តនៅថ្ងៃអនាគត ដើម្បីពង្រីកវិសាលភាពនៃលទ្ធផលលើប្រធានបទដែលបានលើកយកមកសិក្សាស្រាវជ្រាវរួច។

# ជំពូកទី២
# រំឭកទ្រឹស្តី
## ២.១. ព័ត៌មានការអប់រំបច្ចេកទេស មសស នៅខេត្តកំពង់ស្ពឺ

ខេត្តកំពង់ស្ពឺមានចម្ងាយ ៤៨ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ ព្រំប្រទល់ខាងកើតជាប់ខេត្តតាកែវ និងខេត្តកណ្តាល ខាងត្បូងជាប់ខេត្តតាកែវ និងខេត្តកំពត ខាងលិចជាប់ខេត្តព្រះសីហនុ និងខេត្តកោះកុង ខាងជើងជាប់ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។ តំបន់រដ្ឋបាលរួមមាន ស្រុក៧ និងក្រុង១ ឃុំ៨២ សង្កាត់៥ និងមានភូមិចំនួន ១.៣៧៩ភូមិ។ ផ្ទៃដីសរុបមានចំនួន៦.៩៦៥,៦៣គ.ម² ដែលមានគ្រួសារ សរុបចំនួន ១៨៧.៨៣៥គ្រួសារ ប្រជាពលរដ្ឋចំនួន ៨៧២.២១៩នាក់ ស្ត្រី ៤២៦.០៥៥នាក់ អាយុ ១៨ឆ្នាំ ឡើងមាន ៥៧៣.៦៤២នាក់ ដង់ស៊ីតេប្រជាពលរដ្ឋជាមធ្យម ១២៣នាក់/គ.ម² ប្រាក់ចំណូលជាមធ្យម ប្រចាំឆ្នាំរបស់ប្រជាជនខេត្តកំពង់ស្ពឺ (GDP) ចំនួន ១.៦៩៣ ដុល្លា (GDP ថ្នាក់ជាតិ ចំនួន ១.៦៤៣,១ ដុល្លា )។ ពលរដ្ឋចំណាកស្រុកទៅក្រៅប្រទេសមានចំនួន ៧.១៩៣នាក់ (ក្រសួងផែនការ, ២០១៩ )។

ឆ្នាំ២០១៩ វិស័យអប់រំក្នុងខេត្តកំពង់ស្ពឺ មានវិទ្យាល័យចំនួន ២៤កន្លែង អនុវិទ្យាល័យ ៧២កន្លែង បឋមសិក្សា ៣១៤កន្លែង និង មត្តេយ្យសិក្សារដ្ឋ ២០៩កន្លែង វិទ្យាស្ថាន ២ ដែលមានបុគ្គលិក ទូទាំងខេត្តសរុបចំនួន ៥.៣៥១នាក់ ស្រី ២.១០១នាក់ និងមានសាកលវិទ្យាល័យឯកជន១។ ឆ្នាំសិក្សា ២០១៩-២០២០ គ្រឹះស្ថានមធ្យមសិក្សារដ្ឋមាន៩៦ ក្នុងនោះមានអនុវិទ្យាល័យ ៧២ និងវិទ្យាល័យ ២៤ (វិទ្យាល័យធនធាន ២កន្លែង)។ វិទ្យាល័យដែលមានកម្រិតថ្នាក់ពី៧ ដល់ទី១២ មាន២២ និងកម្រិតថ្នាក់ ចាប់ពីថ្នាក់ទី១០ ដល់ទី១២ មាន ២កន្លែង។ គ្រឹះស្ថានសិក្សាឯកជនមាន ៨ក្នុងនោះអនុវិទ្យាល័យ៣ និង វិទ្យាល័យ៥។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ទី១២ មាន ៥កន្លែង។ ឃុំសង្កាត់ ២លើ ៨៧ ស្មើ នឹង ២,៣% ពុំទាន់មានអនុវិទ្យាល័យ នៅស្រុកគងពិសី និងស្រុកបរសេដ្ឋ។ អនុវិទ្យាល័យ ៧០កន្លែង ស្មើ នឹង ៩៧,២២% និងវិទ្យាល័យ ២៤ ស្មើនឹង ១០០% មានបង្គន់ និងទឹកស្អាតប្រើប្រាស់។ បុគ្គលិកអប់រំ មាន ២.២៦៦នាក់ ស្រី ៧៤១នាក់ ហើយបុគ្គលិកបង្រៀនមាន ១.៩៧៩នាក់ ស្រី ៦៩៧នាក់។ ក្នុងនោះ បុគ្គលិកមធ្យមសិក្សាបឋមភូមិសរុប ១.៦០៨នាក់ ស្រី៥៣៤នាក់ ហើយបុគ្គលិកបង្រៀនមាន

១.៤០៩នាក់ ស្រី ៥០៦នាក់ សិស្សមានចំនួន ៣៤.១៧៩នាក់ ស្រី ១៧.៩០០នាក់។

ចំពោះការងារអប់រំក្រៅប្រព័ន្ធ មាន ៦កម្មវិធី រួមមានកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីក្រោយអក្ខរកម្ម កម្មវិធីចូលរៀនឡើងវិញ កម្មវិធីបង្កើនប្រាក់ចំណូល(មសស) កម្មវិធីសមមូល និងបំពេញវិជ្ជា។ កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ ដំណើរការ ចំនួន៤៨ថ្នាក់ សិស្សសរុប ១,០៤៦នាក់ ស្រី ៧៧២នាក់។ កម្មវិធីក្រោយអក្ខរកម្ម មាន២កន្លែង មានអ្នកចូលអានសរុប ៩៤៩នាក់ ស្រី ៦០៨នាក់។ កម្មវិធីចូលរៀនឡើងវិញ មានចំនួន ២០ ថ្នាក់ គ្រូសរុប ២០នាក់ ស្រី ១ នាក់ សិស្សសរុប ៣៤៧នាក់ ស្រី ១៦៧នាក់ កម្មវិធីសមមូល និងបំពេញវិជ្ជាសមមូលបឋមសិក្សាមានចំនួន ២៦ថ្នាក់ សិស្សសរុប ៥២៥នាក់ ស្រី ១៨៤នាក់ សមមូលមធ្យមសិក្សាបឋមភូមិ មាន ៣ថ្នាក់ សិស្សសរុប ៦០នាក់។ *កម្មវិធីបង្កើនប្រាក់ចំណូល មជ្ឈមណ្ឌលសិក្សាសហគមន៍មានចំនួន ២៤ កន្លែងក្នុងស្រុកទាំង ៧ មានសិស្សចូលរៀនសរុប ៥៤១ នាក់ ស្រី ២៩៣ នាក់ ដំណើរលើជំនាញ កាត់ដេរ កាត់សក់ សំអាងការ ពេទ្យសត្វ បណ្តុះផ្សិត កុំព្យូទ័រ ចិញ្ចឹមមាន់ ចិញ្ចឹមត្រី ភាសាអង់គ្លេស ស្មូតកំណាព្យ* (មន្ទីរអប់រំ យុវជន និងកីឡា, ២០១៩)។

## ២.២ និយមន័យ

"**ប្រសិទ្ធភាព**" គឺជាអំណាចដើម្បីបង្កើតលទ្ធផលដែលបានរំពឹងទុក (Wilson, A Literature Review on the Effectiveness, 2018)។ "**ប្រសិទ្ធភាពនៃការគ្រប់គ្រង** "គឺជាការចង្អុលបង្ហាញប្រកបដោយប្រសិទ្ធភាព និងជាគន្លឹះ សំខាន់មួយ ដើម្បីទទួលបានភាពជោគជ័យជាក្រុម ឬ បុគ្គល (Alberta Agriculture, Food and Rural Development, 1998)។ "**ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព**" គឺជាលក្ខខណ្ឌចាំបាច់ដែលត្រូវបានកំណត់ដោយស្របច្បាប់ដើម្បីបំពេញតាមវិធីជាច្រើនផ្សេងៗទៀតក្នុងគោលដៅ និងគោលបំណង សម្រេចបានលទ្ធផលតាមការរំពឹងទុក (UNESCO, 1999)។

## ២.៣ ផែនការយុទ្ធសាស្រ្តអប់រំ (ESP) ឆ្នាំ ២០១៩-២០២៣

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ត្រូវបានរៀបចំឡើងក្នុងគោលដៅបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា និងបង្កើតមូលដ្ឋានរឹងមាំសម្រាប់ឆ្ពោះទៅឆ្នាំ២០៣០ ព្រមទាំងឆ្លើយតបនឹងចក្ខុវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋា-

ភិបាលកម្ពុជា។ ការងារអប់រំក្រៅប្រព័ន្ធ មានវត្ថុបំណង បង្កើនចំនួនអក្ខរជន និងការចូលរៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធសម្រាប់កុមារ យុវជនក្រៅសាលា និងអនក្ខរជនពេញវ័យ ទទួលបានសេវាអប់រំក្រៅប្រព័ន្ធពេញលេញ ក្នុងក្របខណ្ឌនៃការសិក្សាពេញមួយជីវិតប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និង ចរិយាសម្បទា។ នៅក្នុងសូចនាករចំណុចដៅអនុវិស័យគឺបង្កើនចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរពីចំនួន ៩ ១៧០នាក់នៅឆ្នាំ២០១៨ ទៅ ៦០ ៥០០នាក់នៅឆ្នាំ២០២៣

( ក្រសួងអប់រំយុវជន និងកីឡា, ២០១៩)។

## ២.៤ គោលនយោបាយស្តីពីការអប់រំបច្ចេកទេស

(ក្រសួងអប់រំ យុវជន និងកីឡា , ២០១៣) គោលនយោបាយនេះគ្របដណ្តប់លើការអប់រំជំនាញ និងមុខរបរដែលជំរុញឱ្យអ្នកសិក្សាទទួល បានចំណេះដឹង សមត្ថភាព និងតម្លៃដើម្បីក្លាយខ្លួនជា ពលករជំនាញ អ្នកបច្ចេកទេសជំនាញ និងពលរដ្ឋថ្លៃថ្នូរចូលរួមដោះស្រាយបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃនិងរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ គោលនយោបាយនេះមានគោលដៅ៖

ក. អភិវឌ្ឍន៍គ្រឹះស្ថានមធ្យមសិក្សាឱ្យមានលក្ខណៈសម្បត្តិពេញលេញជាគ្រឹះស្ថានអប់រំបច្ចេកទេស

ខ. លើកកម្ពស់សមត្ថភាពគ្រូបង្រៀនឱ្យមានជំនាញបច្ចេកទេសពិតប្រាកដ

គ. អភិវឌ្ឍន៍មុខជំនាញអប់រំបច្ចេកទេសស្របតាមតម្រូវការទីផ្សារការងារ និងបរិបទសង្គមកម្ពុជា

ឃ. ផ្តល់ឱកាសសិស្សមធ្យមសិក្សាមានជម្រើសផ្នែកអប់រំបច្ចេកទេស

ង. អភិវឌ្ឍន៍សមត្ថភាពជំនាញបច្ចេកទេសប្រកបដោយគុណភាពដល់សិស្សមធ្យមសិក្សា

ច. កៀរគរធនធានសហគមន៍ ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន ដើម្បីអភិវឌ្ឍន៍ការអប់រំបច្ចេកទេស។

## ២.៥ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្លើយតបបរិបទកម្ពុជាបច្ចុប្បន្ន ការបណ្តុះបណ្តាលកម្មវិធីអប់រំក្រៅប្រព័ន្ធមានកម្មវិធីដូចជា កម្មវិធីអក្ខរកម្ម កម្មវិធីក្រោយអក្ខរកម្ម កម្មវិធីចូលរៀនឡើងវិញ កម្មវិធីបង្កើនប្រាក់ចំណូល (បង្រៀនជំនាញមុខរបរងាយៗនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍) កម្មវិធីសមមូល កម្មវិធីបំពេញវិជ្ជា និងកម្មវិធីកែលម្អគុណភាពនៃជីវិត។

- ❖ **ចក្ខុវិស័យ**

ចក្ខុវិស័យរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ គឺផ្តល់ឱកាសដល់មនុស្សគ្រប់រូប ដែលពុំមានលទ្ធភាពរៀនសូត្រតាមការអប់រំក្នុងប្រព័ន្ធឲ្យទទួលបានចំណេះដឹង បំណិន និងជំនាញវិជ្ជាជីវៈមុខរបរសម្រាប់បង្កើនគុណភាពនៃជីវិតរស់នៅ ។

- ❖ **បេសកកម្ម**

- គ្រប់គ្រងកម្មវិធីអក្ខរកម្ម ក្រោយអក្ខរកម្ម និងសមមូល ដោយផ្តល់ចំណេះដឹងទូទៅជំនាញវិជ្ជាជីវៈជំនាញមុខរបរ
- កសាងកម្មវិធីសិក្សា ឯកសាររៀននិងបង្រៀនសម្រាប់កម្មវិធីអក្ខរកម្ម ក្រោយអក្ខរកម្មនិងសមមូល
- បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងមុខរបរដល់ប្រជាពលរដ្ឋគ្រប់រូប គ្រប់វ័យ តាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍
- ផ្សព្វផ្សាយព័ត៌មាន និងសម្របសម្រួលសកម្មភាពអប់រំក្រៅប្រព័ន្ធជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍នានា។
- ពិនិត្យតាមដានដំណើរការសិក្សាក្នុងសាលារៀន និងថ្នាក់រៀនអប់រំក្រៅប្រព័ន្ធគ្រប់ប្រភេទ និងរៀបចំប្រព័ន្ធទិន្នន័យអប់រំក្រៅប្រព័ន្ធ។

- ❖ **ភារកិច្ច/មុខងារ និងរចនាសម្ព័ន្ធអង្គភាព**

នាយកដ្ឋានមានភារកិច្ចចំនួន០៦៖

១. គ្រប់គ្រងការងារអក្ខរកម្មក្រោយអក្ខរកម្មនិងកម្មវិធីសមមូលដោយផ្តល់ចំណេះដឹងទូទៅជំនាញវិជ្ជាជីវៈនិងជំនាញមុខរបរ

២. កសាងកម្មវិធីសិក្សាឯកសាររៀននិងបង្រៀនសម្រាប់កម្មវិធីអក្ខរកម្មក្រោយអក្ខរកម្មនិងកម្មវិធី សមមូលគ្រប់ភូមិសិក្សា។

៣. បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងមុខរបរជូនប្រជាពលរដ្ឋគ្រប់រូបគ្រប់ភេទគ្រប់វ័យតាមរយៈ

មជ្ឈមណ្ឌលសិក្សាសហគមន៍

៤. ពិនិត្យតាមដានដំណើរការសិក្សាក្នុងសាលារៀននិងថ្នាក់រៀនអប់រំក្រៅប្រព័ន្ធគ្រប់ប្រភេទ

៥. រៀបចំប្រព័ន្ធទិន្នន័យអប់រំក្រៅប្រព័ន្ធ

៦. ផ្សព្វផ្សាយព័ត៌មាននិងសម្របសម្រួលសកម្មភាពអប់រំក្រៅប្រព័ន្ធជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងអង្គការនានា។

នាយកដ្ឋានដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធាននាយកដ្ឋានពីររូប។ នាយកដ្ឋានចែកចេញជា០៧ការិយាល័យរួមមាន៖ ការិយាល័យរដ្ឋបាល ការិយាល័យផែនការនិងគ្រប់គ្រងទិន្នន័យព័ត៌មាន ការិយាល័យអក្ខរកម្ម ការិយាល័យអភិវឌ្ឍន៍កម្មវិធីក្រោយអក្ខរកម្ម ការិយាល័យបំពេញវិជ្ជា ការិយាល័យអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ និងការិយាល័យព័ត៌មាននិងផ្សព្វផ្សាយ។

## ២.៦ គោលនយោបាយការអប់រំក្រៅប្រព័ន្ធ

(ក្រសួងអប់រំយុវជន និងកីឡា, ២០០២)

រាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជាបានកំណត់ថា ការងារអប់រំក្រៅប្រព័ន្ធជា ប្រព័ន្ធអប់រំផ្លូវការមួយ រួមចំណែកសម្រេចនូវការងារអប់រំសម្រាប់ទាំងអស់គ្នា និងបង្កលទ្ធភាពឱ្យប្រជាពលរដ្ឋមានឱកាសទទួលបាននូវ ការអប់រំពេញមួយជីវិត កសាងសង្គមសិក្សា ប្រកបដោយសមធម៌ យុត្តិធម៌ និងអភិវឌ្ឍន៍សង្គម។ គោលនយោបាយបានកំណត់ជាយុទ្ធសាស្ត្រដូចខាងក្រោម៖

ក. ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋគ្រប់រូបមានលទ្ធភាព រៀនសូត្រពេញមួយជីវិត

ខ. លើកកម្ពស់ការងារអក្ខរកម្ម និងអប់រំបន្តដោយផ្សារភ្ជាប់ជាមួយការផ្តល់ឥណទានការផ្តល់មុខរបរវិជ្ជាជីវៈ សម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយសុភមង្គល

គ. ផ្តល់ជាប្រចាំព័ត៌មានស្តីពីចំណេះដឹងវិជ្ជាជីវៈ បច្ចេកទេស វិទ្យាសាស្ត្រដល់ប្រជាពលរដ្ឋ ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋគ្រប់ជនជាតិទាំងពីរភេទរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលពុំមានលទ្ធភាពទទួលការអប់រំក្នុងប្រព័ន្ធបានទទួលការអប់រំក្រៅប្រព័ន្ធ។

## ២.៧ ផែនការគោលសម្រាប់ការអប់រំបច្ចេកទេស

(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៥)បានបង្កើតក្របខណ្ឌគតិយុត្ត និងគោលនយោបាយសម្រាប់គាំទ្រសេវាកម្មអប់រំបច្ចេកទេស ការបង្កើនគុណភាពវិស័យអប់រំ និងគាំទ្រអំពីសារៈសំខាន់នៃការបង្កើត និងដាក់ឱ្យដំណើរការវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស។ ក្នុងផែនការគោលផ្តោតទៅលើ ៦ ចំណុចសំខាន់៖

ក. ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារបរិក្ខា

ខ. ការចូលរៀនផ្នែកអប់រំបច្ចេកទេស

គ. គ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស

ឃ. ការវិភាគស្ថានភាពបច្ចុប្បន្ន

ង. ការប្រើប្រាស់ធនធាន និងការចូលរួមពីអ្នកពាក់ព័ន្ធ

ច. ក្របខណ្ឌគតិយុត្តគាំទ្រ និងយុទ្ធសាស្រ្តសម្រាប់ការអប់រំបច្ចេកទេស។

## ២.៨ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

ការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ រយៈពេល១ឆ្នាំនេះ ប្រកបដោយជោគជ័យស្របតាមផែនការគួរជាទីមោនៈ និងវាយតម្លៃខ្ពស់ចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍នានា អង្គការវិជ្ជាជីវៈ និងវិស័យឯកជន ដែលតែងតែគាំទ្រ និងផ្តល់កិច្ចសហការល្អជាមួយក្រសួង ក្នុងការរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាពេលកន្លងមក ដែលធ្វើឱ្យសម្រេចបានជោគជ័យ ក្នុងការបង្កើតឱកាសការងារ និងធានាបាននូវសុខដុមនីយកម្មរវាងកម្មករនិយោជិតនិងនិយោជក។

សន្និបាតស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺរៀបចំឡើងក្នុង គោលបំណងដើម្បីពិនិត្យមើលអំពីវឌ្ឍនភាពការងារប្រចាំឆ្នាំ២០១៩ នៃការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ ដែលផ្តោតលើយុទ្ធសាស្រ្តអាទិភាពទាំង ៥ រួមមាន ទី១-ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃ ទំនាក់ទំនងវិជ្ជាជីវៈ, ទី២-ការធ្វើទំនើបកម្មប្រព័ន្ធ

អប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ, ទី៣-ការរក្សានិងបង្កើន មុខរបរ និងការងារនៅក្នុងនិងក្រៅប្រទេស, ទី៤-ការអភិវឌ្ឍរបបសន្តិសុខសង្គម និងទី៥-ការពង្រឹងសេវាគាំទ្រទូទៅ និងបញ្ហាប្រឈមមួយចំនួន ដើម្បីដាក់ចេញនូវទិសដៅអាទិភាពសម្រាប់អនុវត្តការងារបន្តនៅឆ្នាំ ២០២០ សំដៅបង្កើនប្រសិទ្ធភាពការងារ ឱ្យស្របទៅនឹងកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ ព្រមទាំងខិតខំ សម្រេចឱ្យបានជាលទ្ធផលផ្លែផ្កានូវរាល់ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយនានា ដែលបានដាក់ចេញ ជាពិសេសគោលនយោបាយជាតិស្ដីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ និងគោលនយោបាយជាតិ ស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥។ សមិទ្ធផលដែលសម្រេចបានពេញ១ឆ្នាំនេះ បានធ្វើឱ្យវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈកាន់តែដើរតួនាទីយ៉ាងសំខាន់ដល់ការគាំទ្រនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងបន្តជំរុញកំណើនសេដ្ឋកិច្ច ការបន្តភាពប្រកួតប្រជែងរបស់កម្ពុជា ការបន្តនិរន្តភាពពាណិជ្ជកម្ម អាជីវកម្ម ផលិតកម្ម និងវិនិយោគ។

យោងតាម ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (២០១៧) គោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ មានគោលបំណងលើកកម្ពស់ប្រព័ន្ធអភិវឌ្ឍន៍ជំនាញ ផ្អែកលើគុណភាពដែលឆ្លើយតបតាមតម្រូវការកម្លាំងពលកម្ម សម្រាប់ការងារ សមរម្យ ដើម្បីអភិវឌ្ឍន៍ឧស្សាហ៍កម្មឈានទៅរកកំណើនសេដ្ឋកិច្ច និងផលិតភាពខ្ពស់ ដែលបានកំណត់គោលបំណង៖

- ពង្រឹងគុណភាពអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ឱ្យស្របតាមតម្រូវការទីផ្សារការងារក្នុងនិងក្រៅប្រទេស។
- បង្កើនលទ្ធភាពទទួលបានការបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ប្រកបដោយសមធម៌សម្រាប់បង្កើតការងារ។
- លើកទឹកចិត្តភាពជាដៃគូរវាងរដ្ឋ និងឯកជន និងកៀរគរធនធានពីភាគីពាក់ព័ន្ធឱ្យចូលរួម ក្នុងការអភិវឌ្ឍ និងធានានិរន្តរភាពនៃប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ។
- លើកកម្ពស់អភិបាលកិច្ចក្នុងប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ។

## ២.៩ ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ របស់មជ្ឈមណ្ឌលសិក្សាសហគមន៍

ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡាបានពង្រីកការងារអប់រំក្រៅប្រព័ន្ធ ឱ្យទូលំទូលាយ ដល់តំបន់ដាច់ស្រយាល ក្រោមកិច្ចសហការជាមួយអាជ្ញាធរដែនដី និង ដៃគូអភិវឌ្ឍន៍ ដើម្បីចូលរួមសកម្មភាពនានា ដោយផ្តោតលើ អក្ខរកម្មមនុស្សពេញវ័យ កម្មវិធីបង្កើនប្រាក់ចំណូល (CLCs) កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូលបឋមសិក្សា កម្មវិធីក្រោយអក្ខរកម្ម ដែលនាយកដ្ឋាន អប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកទទួលខុសត្រូវ និងអនុវត្តជាមួយមន្ទីរអប់រំយុវជន និងកីឡា តាមបណ្តាខេត្តទាំង ២៥ ក្នុងប្រទេសកម្ពុជា។ គំនិតផ្តួចផ្តើមមួយចំនួនដូចជា គម្រោងមជ្ឈមណ្ឌលសិក្សាសហគមន៍ (CLCs)។

ការអនុវត្តផែនការប្រតិបត្តិ មសស យុំញ្ញាយ ២០១៩-២០២០ មសស យុំញ្ញាយ សម្រេច បានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការបង្កើនឱកាសសម្រាប់កុមារកម្ពុជាគ្រប់រូបទទួលបានសេវាអប់រំ ការលើកកម្ពស់គុណភាពនៃការសិក្សារបស់សិស្ស និងការផ្តល់សេវាអប់រំប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ក្នុងគោលបំណងឱ្យមានសង្គតិភាពជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ស្តីពីការអប់រំនៅកម្ពុជា ដោយគោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងគោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមចម្បងផ្តោតលើ៖ ការចូលរៀន គុណភាពសិក្សា និង ការគ្រប់គ្រង និងដឹកនាំ មសស៖ ការគ្រប់គ្រង និងដឹកនាំ មានគណៈគ្រប់គ្រងចំនួន ៥នាក់ និងគណៈកម្មការទ្រទ្រង់ បានប្រជុំធ្វើ ផែនការអភិវឌ្ឍ និងការអនុវត្ត ការប្រជុំ ឬទប់ស្កាត់បាតុភាពមិនប្រក្រតី។ បញ្ហាប្រឈមចម្បង៖ ពិបាករកសិស្ស សិស្សនៅឆ្ងាយពី មសស ក្នុងមូលដ្ឋានគ្រូមិនសូវមានជំនាញច្បាស់លាស់ ទៀមទារប្រាក់ឧបត្ថម្ភខ្ពស់ ជំនាញមិនតម្រូវតាមទីផ្សារ ការរៀនមានរយៈពេលខ្លី សិស្សរៀនចប់គ្មានលទ្ធភាពបើកមុខរបរ។

## ២.១០. មុខងារ និង តួនាទី របស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ( មសស )

មសស គឺជាទីកន្លែងអប់រំក្រៅប្រព័ន្ធមួយដែលទីតាំងនៅភូមិ តំបន់ប្រជុំជន វត្តអារាម ត្រូវបានបង្កើតឡើងដោយប្រជាពលរដ្ឋ គ្រប់គ្រងដោយប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីផ្តល់ឱកាសរៀនសូត្រសម្រាប់ការអភិវឌ្ឍសហគមន៍ និងការកែប្រែគុណភាពរស់នៅនៃជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ តាមរយៈគោលបំណង និងការផ្តល់ជាប្រយោជន៍ដល់សហគមន៍ពិតមែន ប៉ុន្តែ មសស ផ្តោតសំខាន់ចំពោះប្រជាពលរដ្ឋជាស្ត្រី កុមារ និងយុវជនក្រៅសាលា ដើម្បីផ្តល់ឱកាសដល់ពួកគេក្នុងការទទួលយកចំណេះដឹងការអប់រំបច្ចេកទេស សម្រាប់យកទៅប្រកបរបរចិញ្ចឹមជីវិតក្នុងជីវិតរស់នៅប្រចាំថ្ងៃ (UNESCO, 2003)។

**តួនាទី និង មុខងារ** សំខាន់ៗរបស់ មសស មានចំនួន ៤សំខាន់ៗ គឺៈ ១). ជាកន្លែងអប់រំ និងបណ្តុះបណ្តាលជំនាញ និងការអប់រំ ២). ជាកន្លែងផ្តល់ព័ត៌មាន សហគមន៍ និងសេវាកម្មផ្សេងៗ អាចជាមជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មាន និងមជ្ឈមណ្ឌលប្រឹក្សាយោបល់ ៣). ជាកន្លែងសម្រាប់សកម្មភាពអភិវឌ្ឍន៍សហគមន៍ លើការលើកកម្ពស់ "សកម្មភាពសហគមន៍ទូទៅ" " គម្រោងអភិវឌ្ឍន៍សហគមន៍" ៤).ជាកន្លែងសម្រាប់សម្របសម្រួល និងបណ្តាញដើម្បីបង្កើតទំនាក់ទំនងរវាងអង្គការរដ្ឋាភិបាល (GOs) និងអង្គការក្រៅរដ្ឋាភិបាល (NGOs) និងជាកន្លែង សម្រាប់ការសិក្សាពេញមួយជីវិត (UNESCO, CLCs in APPEAL, 2006)។

### ២.១១.១ កម្មវិធីសិក្សាសម្រាប់ មសស ឆ្នាំ២០១៨ បានកំណត់លើៈ

**១. ចក្ខុវិស័យៈ** ធានាឱ្យប្រជាពលរដ្ឋទទួលបាននូវតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីលើកកម្ពស់ជីវភាពរស់នៅបានល្អប្រសើរនិងថ្លៃថ្នូរ ។

**២. គោលបំណង និងគោលដៅៈ** ផ្តល់ជំនាញមុខរបរងាយៗដល់ប្រជាលរដ្ឋសហគមន៍ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ។ ហើយមានគោលដៅឱ្យក្លាយជា មសស ស្តង់ដានិងលើកកម្ពស់ជំនាញនីមួយៗ ឱ្យស្របតាមទីផ្សារការងារ ។

**៣. វិសាលភាពៈ** (ក) កំណត់មុខសញ្ញាច្បាស់លាស់(ប្រជាពលរដ្ឋសហគមន៍)(ខ)ពេលវេលា សម្រាប់បណ្តុះបណ្តាល(រយៈពេលជំនាញនីមួយៗ ពី១ខែ ដល់៦ខែ) (គ)ទីកន្លែង គ្រប់ការបណ្តុះបណ្តាលគឺនៅ

ក្នុង មសស ដែលគ្រប់គ្រងដោយរដ្ឋ ដៃគូអភិវឌ្ឍន៍ផ្នែកឯកជននិងទីកន្លែងសមស្រប ។

**៤. សមត្ថភាពដែលអ្នកសិក្សាទទួលបានៈ**(១) ការអនុវត្តចំណេះដឹង និងជំនាញមុខរបរ (២) ការអភិវឌ្ឍន៍បុគ្គល គ្រួសារ និងសហគមន៍(៣ )ការប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម (៤) សហគ្រិនភាព ភាពជាអ្នកដឹកនាំ និងជំនាញទន់(៥)ការអភិវឌ្ឍជំនាញ និងការបង្កើតថ្មី (៦) បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(៧) ភាសាបរទេស។

**៥. ជំនាញមុខរបរនិងម៉ោងសិក្សា៖**(១) បណ្តុំមុខជំនាញសិប្បកម្ម និងសេវាកម្ម (២)បណ្តុំមុខជំនាញកសិកម្ម(៣)បណ្តុំមុខជំនាញអេឡិចត្រូនិច (៤)បណ្តុំមុខជំនាញអប់រំទូទៅ
(ក្រសួងអប់រំយុវជន និងកីឡា, ២០១៨)។

### ២.១១.២ អត្ថន័យរវាង សាលារៀន និង មសស

ការអប់រំត្រូវបានគេទទួលស្គាល់ ជាឥទ្ធិពលដ៏ខ្លាំងក្លាមួយដើម្បីឆ្លើយតបទៅនឹងការទាមទារផ្សេងៗរបស់សង្គមដែលកំពុងអភិវឌ្ឍន៍។ ហើយប្រជាជនដែលចេះអក្សរ គឺជាគ្រឹះសម្រាប់ការអភិវឌ្ឍន៍ប្រទេស។

សាលារៀនត្រូវបានគេស្គាល់ថាជាស្ថាប័នអប់រំតែមួយគត់ នៃការអប់រំមនុស្សគ្រប់រូប។ ដោយសារសាលាមិនអាចឆ្លើយតបទៅនឹងតម្រូវការរៀនសូត្រ របស់មនុស្សគ្រប់រូប រាជរដ្ឋាភិបាលបានបង្កើតការងារអប់រំក្រៅប្រព័ន្ធ ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ ។ ក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អប់រំក្រៅប្រព័ន្ធ បានផ្តល់សេវាអប់រំជាច្រើនដល់មនុស្សទាំងអស់ ដែលមិនមានឱកាសសិក្សាក្នុងប្រព័ន្ធអប់រំ (សាលារៀន) ជាពិសេសកុមារ ឬមនុស្សធំដែលជួបការលំបាក និងក្រុមក្មេងស្រី ... ។ល។

មជ្ឈមណ្ឌលសិក្សាសហគមន៍ មសស ត្រូវបានបង្កើតដើម្បីបំពេញតម្រូវការសិក្សារបស់ប្រជាពលរដ្ឋដែលត្រូវបានរៀបចំនិងគ្រប់គ្រងដោយសហគមន៍មូលដ្ឋានដោយខ្លួនឯងហើយ មសស បានចូលរួមលើកកម្ពស់ការរៀនសូត្រពេលមួយជីវិតតាមរយៈ មសស នៅថ្នាក់អក្ខរកម្ម ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។ ដើម្បីបង្កើនអត្រាអក្ខរកម្មនៅក្នុងប្រទេស សាលារៀន(អប់រំក្នុងប្រព័ន្ធ) គឺមិនអាចជួយបានទាំងស្រុងឡើយគឺតម្រូវឱ្យការអប់រំក្រៅប្រព័ន្ធ ដើរតួនាទីសំខាន់ក្នុងការកាត់បន្ថយក្នុងនោះ មាន មសស បានចូលរួមចំណែកយ៉ាងសំខាន់ដែលជាជំនួយដល់ក្រុមគោលដៅទាំងអស់ (Nipun, 2008)។

### គំនូសប្រៀបធៀប ២.១៖ រវាងសាលារៀន និងមសស




( NIPUN, 2008 )

## ២.១១ ក្របខណ្ឌវាយតម្លៃស្ថានភាពដំណើរការរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍

**ស្វ័យវាយតម្លៃដោយសមាសភាពខាងក្នុង៖** ទម្រង់បំពេញព័ត៌មានត្រូវប្រើដោយគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងគ្រូជំនាញមុខរបរ ឬគ្រូបង្រៀនកម្មវិធីអប់រំក្រៅប្រព័ន្ធ ស្វ័យវាយតម្លៃដោយលើកឡើងពីស្ថានភាព និងការចូលរួមក្នុងដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍។ ខ្លឹមសារនៃការវាយតម្លៃមជ្ឈមណ្ឌលសិក្សាសហគមន៍ឈរលើកត្តាដូចខាងក្រោម៖

- ទិដ្ឋភាពទូទៅនៃមជ្ឈមណ្ឌលសិក្សាសហគមន៍
- ការបង្រៀនរបស់គ្រូជំនាញមុខរបរ ឬគ្រូកម្មវិធីអប់រំក្រៅប្រព័ន្ធ

- ការផ្តល់ការយកចិត្តទុកដាក់ពីការចូលរួម និងគាំទ្ររបស់សហគមន៍

**សូចនាករគោលទី១៖** ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមជ្ឈមណ្ឌលសិក្សាសហគមន៍

ពិនិត្យទិដ្ឋភាពទូទៅរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ចាប់ពីក្លោងទ្វារខាងមុខមជ្ឈមណ្ឌល ដល់បរិវេណខាងក្នុង និងរហូតដល់ខាងក្នុងអាគារ ដោយផ្តោតលើ ក្លោងទ្វារ ស្លាកសញ្ញាសម្គាល់ទីតាំង ស្លាកសញ្ញាសម្គាល់ថ្នាក់ជំនាញ ក្តារព័ត៌មាន បន្ទប់រៀន បន្ទប់ប្រជុំ ជ្រុងអាន/បណ្ណាល័យ ទូ/ធ្នើរដាក់សៀវភៅ បណ្តាញអគ្គិសនី/ម៉ាស៊ីនភ្លើង បង្គន់អនាម័យ/ទឹកស្អាត និងឧបករណ៍សោតទស្សន៍...។

**សូចនាករគោលទី២៖** ការគ្រប់គ្រង និងដឹកនាំ

ពិនិត្យលើការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ ដោយផ្តោតលើការរៀបចំឈ្មោះនៃសូចនាករគោលគណៈកម្មការគ្រប់គ្រងនិងដឹកនាំ និងការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ ដូចជាការរៀបចំផែនការ ការគ្រប់គ្រងបញ្ជីឈ្មោះអ្នកសិក្សា បញ្ជីសារពើភ័ណ្ឌ លទ្ធផលដំណើរការ បទបញ្ជាផ្ទៃក្នុងសម្រាប់បុគ្គលិក គ្រូបង្រៀន អ្នកសិក្សា ចំនួនអ្នកបានបង្កើតមុខរបរផ្ទាល់ខ្លួន ការប្រជុំតាមការណែនាំ ការផ្តល់ទិន្នន័យ និងរបាយការណ៍ទៅអ្នកគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធតាមលំដាប់ថ្នាក់និងតាមពេលវេលាកំណត់។

**សូចនាករគោលទី៣៖** ការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ

ពិនិត្យលើការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ដោយផ្តោតលើចំនួនកម្មវិធីអប់រំក្រៅប្រព័ន្ធដែលបានដំណើរការ រយៈពេលដំណើរការក្នុងមួយឆ្នាំ ចំនួនជំនាញមុខរបរ ស្នាដៃរបស់អ្នកសិក្សា ចំនួនវគ្គសិក្សា ការបញ្ជ្រាបបន្ថែមចំណេះដឹងពាក់ព័ន្ធនិងបំណិនជីវិតដូចជា ការអប់រំពលរដ្ឋសកល អប់រំសុខភាព អប់រំអំពីជំងឺឆ្លង ច្បាប់ចរាចរណ៍ ប្រពៃណី វប្បធម៌...។ល។

**សូចនាករគោលទី៤៖** ការរៀនសូត្ររបស់ក្រុមមុខសញ្ញា

ពិនិត្យជាសំខាន់លើលទ្ធផលនៃការសិក្សារបស់ក្រុមមុខសញ្ញាតាមជំនាញមុខរបរ ឬកម្មវិធីអប់រំក្រៅប្រព័ន្ធដែលបានដំណើរការ ដូចជាចំនួនអ្នកចូលសិក្សា ចំនួនអ្នកបញ្ចប់ការសិក្សា ចំនួនអ្នកបានធ្វើតេស្តបញ្ចប់ជាប់ ចំនួនសិស្សបោះបង់ការសិក្សា។

**សូចនាករគោលទី៥៖** សម្ភារៈដំណើរការ

ពិនិត្យលើការផ្គត់ផ្គង់សម្ភារបរិក្ខារ គុណភាពសម្ភារដំណើរការ និង ឯកសាររៀននិងបង្រៀន។

**សូចនាករគោលទី៦៖** ការគ្រប់គ្រង និងប្រើប្រាស់ថវិកា

ពិនិត្យលើលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃចំនួន៥ រួមមាន ផែនការថវិកា ទំហំថវិកាសម្រាប់អនុវត្ត ចំនួនដងនៃការទទួលប្រាក់ ភាគរយនៃទំហំទឹកប្រាក់ដែលបានទទួល និងការប្រើប្រាស់ថវិកា។

**សូចនាករគោលទី៧៖** កិច្ចសហការជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ

ពិនិត្យលើលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃចំនួន៥ រួមមាន ការផ្សព្វផ្សាយ គណៈកម្មការប្រមូលសិស្ស ការចូលរួមរបស់អាជ្ញាធរដែនដី ការចូលរួមរបស់ប្រជាពលរដ្ឋសហគមន៍ និងការកៀរគរធនធាន។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី″ ប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដោយផ្តោតលើការសិក្សារបស់សិស្សក្នុងខេត្តកំពង់ស្ពឺ″ មានគោលបំណងសិក្សាស្វែងយល់ពីប្រសិទ្ធភាពនៃការគ្រប់គ្រង មសស ដោយផ្តោតលើលទ្ធផលការសិក្សារបស់សិស្សក្នុងខេត្តកំពង់ស្ពឺនិងដំណោះស្រាយ ដែលមានប្រសិទ្ធភាព ក្នុងការលើកកម្ពស់គុណភាពការសិក្សាជំនាញអប់រំបច្ចេកទេសឱ្យកាន់តែប្រសើរឡើងស្របនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន។ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យ។

## ៣.១. គម្រោងវិភាគ

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរ ៤ប្រភេទ តាមបែបបរិមាណវិស័យដោយបន្សុំគ្នាជាមួយសំណួរស្រាវជ្រាវទាំងពីរ នៃប្រធានបទដែលលើកយកមកសិក្សា។ ស្របតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចការស្រាវជ្រាវនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០ តាមផែនការគ្រោងទុក។ ការចុះប្រមូលទិន្នន័យ គឺធ្វើនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន ២៤ មសស ក្នុងខេត្តកំពង់ស្ពឺ និងក្រុមគោលដៅបំពេញទិន្នន័យកម្រងសំណួរមាន ៤ប្រភេទ គឺ គណៈគ្រប់គ្រង គ្រូបង្រៀន សិស្ស និង សហគមន៍។

## ៣.២ ការប្រមូលទិន្នន័យ

ក្នុងអំឡុងពេលបិទសាលារៀនដោយសារការកើតមានជំងឺកូវីដ-១៩ គ្រូបង្រៀនតាមសាលារដ្ឋ ក៏ដូចជា មសស បានចាប់ផ្តើមបង្រៀន និងដឹកនាំសិស្សឲ្យរៀនតាមអនឡាញ។ លិខិតឧទ្ទេសនាមពីក្រសួងអប់រំ យុវជន និងកីឡា លេខ ១៩៧ វជអ.ផក ចុះថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ ឱ្យចុះប្រមូលទិន្នន័យតាមប្រពន្ធអនឡាញ ( ONLINE Google Form ) ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក

គ្រប់គ្រងអប់រំ។

ក្រោយពីបានឆ្លងយោបល់ក្នុងក្របខណ្ឌបច្ចេកទេស ជាមួយគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំវង្សរួចមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យអ្នកសិក្សាស្រាវជ្រាវ មានភាពសហការល្អជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត អាជ្ញាធរដែនដី គណៈគ្រប់គ្រង មសស គ្រូបង្រៀន សិស្ស និងសហគមន៍ ដើម្បីចែកកម្រងសំណួរទៅតាមការជ្រើសរើសចំនួនសំណាកដែលបានគ្រោងទុក។

អ្នកសិក្សាស្រាវជ្រាវ បានចុះទៅជួបមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីជូនលិខិតឧទ្ទេសនាម និងសុំការអនុញ្ញាត ជួបក្រុមគោលដៅដើម្បីផ្តល់កម្រងសំណួរ ដល់គណៈគ្រប់គ្រង គ្រូបង្រៀន សិស្ស និងសហគមន៍ ដោយមានកំណត់ពេលវេលាជាក់លាក់។ ការចុះប្រមូលទិន្នន័យ គឺមានភាពបត់បែនទៅតាមទីតាំងភូមិសាស្ត្ររបស់ មសស និងផ្តល់អាទិភាពដល់អ្នកផ្តល់ទិន្នន័យ តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមនានា៖ Google form, តេឡេក្រាម, ទូរស័ព្ទ និង Facebook ជាដើម។

ការបំពេញទិន្នន័យក្នុងកម្រងសំណួរ មានរយៈពេលមួយសប្តាហ៍ អ្នកសិក្សាស្រាវជ្រាវ បានប្រមូលកម្រងសំណួរពីអ្នកឆ្លើយតប ទៅតាមពេលកំណត់ជាក់លាក់។ ក្នុងអន្តរកាល នៃការរក្សាគម្លាតសង្គម ការចុះប្រមូលទិន្នន័យបានជួបបញ្ហាមួយចំនួនផងដែរ ទាំងផ្នែកបច្ចេកទេស បណ្តាញទំនាក់ទំនងសង្គម និងកិច្ចសហការពីអ្នកឆ្លើយតប។ ក្នុងការចុះប្រមូល ទិន្នន័យបានប្រើប្រាស់ពេលវេលាសរុបចំនួន៣០ថ្ងៃ គិតចាប់ពីចាប់ផ្តើម រហូតដល់ថ្ងៃដែលបានទទួលកម្រងសំណួរទាំងអស់ពី គណៈគ្រប់គ្រង មសស គ្រូបង្រៀន សិស្ស និងសហគមន៍។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "ប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដោយផ្តោតលើការសិក្សារបស់សិស្សក្នុងខេត្តកំពង់ស្ពឺ" បានរៀបចំកម្រងសំណួរដែលមានសូចនាករ នីមួយៗ ដោយយោងលើ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គោលនយោបាយស្តីពីការអប់រំក្រៅប្រព័ន្ធ គោលនយោបាយស្តីពីការអប់រំបច្ចេកទេស សៀវភៅជំនួយ

សម្រាប់អភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ ក្របខណ្ឌវាយតម្លៃស្ថានភាពដំណើរការរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ទ្រឹស្ដីពាក់ព័ន្ធការអប់រំបច្ចេកទេស និងការប្រឹក្សាជាមួយគ្រូដឹកនាំ ដើម្បីប្រើប្រាស់សូចនាករនៅក្នុងកម្រងសំណួរប្រកបដោយសង្គតិភាព។ អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្រតាមបែបបរិមាណវិស័យ ក្នុងការចុះប្រមូលទិន្នន័យ ដោយមានកម្រងសំណួរ ៤ប្រភេទផ្សេងគ្នា គណៈគ្រប់គ្រង គ្រូបង្រៀន សិស្ស និងសហគមន៍ ដើម្បីសិក្សាពីប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងដំណោះស្រាយ ការលើកកម្ពស់គុណភាពការសិក្សាជំនាញអប់រំបច្ចេកទេសឱ្យកាន់តែប្រសើរឡើង ស្របនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន ក្នុងខេត្តកំពង់ស្ពឺ។

### ៣.៣.១ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញ គឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតប ក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញ អាចបំពេញតាមរយៈអនឡាញ និង/ឬ គូសដោយផ្ទាល់នៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale គឺនិយមចូលចិត្ត ប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករ វាយតម្លៃទៅលើកម្រិតនៃការអនុវត្ត និងដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស។ ក្នុងការសិក្សាស្រាវជ្រាវនេះកម្រិតចង្អុលបង្ហាញនៃកម្រងសំណួរ នីមួយៗមានចំនួន៥កម្រិត ពីទាបបំផុត(១) ទៅខ្ពស់បំផុត (៥)។ រូបមន្តនៃកម្រិតចង្អុលបង្ហាញមានដូចខាងក្រោម៖

| | | |
|---|---|---|
| ១ | គឺ | មិនយល់ស្របទាល់តែសោះ |
| ២ | គឺ | មិនយល់ស្រប |
| ៣ | គឺ | ពុំមានយោបល់ |
| ៤ | គឺ | យល់ស្រប |
| ៥ | គឺ | យល់ស្របខ្លាំង |

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើ ពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម (Best, 1981)៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត-ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{5-1}{5} = \frac{4}{5} = 0.80$$

| | | |
|---|---|---|
| 1.00 — 1.80 | មានន័យថា | ខ្សោយខ្លាំង |
| 1.81 — 2.60 | មានន័យថា | ខ្សោយ |
| 2.61 — 3.40 | មានន័យថា | មធ្យម |
| 3.41 — 4.20 | មានន័យថា | ល្អ |
| 4.21 — 5.00 | មានន័យថា | ល្អណាស់ |

### ៣.៣.២ កម្រងសំណួរ

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីសិក្សាស្វែងយល់ពីប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍និងដំណោះស្រាយការលើកកម្ពស់គុណភាពការសិក្សាជំនាញអប់រំបច្ចេកទេសឱ្យកាន់តែប្រសើរឡើង ស្របនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន ក្នុងខេត្តកំពង់ស្ពឺ។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះ មានគោលបំណងយកទៅប្រើប្រាស់ដើម្បីវិភាគកែលម្អ និងលើកកម្ពស់គុណភាពការសិក្សាជំនាញអប់រំបច្ចេកទេសឱ្យកាន់តែប្រសើរឡើង។ ទិន្នន័យដែលប្រមូលបាន គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះ តែប៉ុណ្ណោះ។

### ៣.៣.២.១ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង មសស

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ដែលត្រូវប្រើប្រាស់សម្រាប់ប្រធាន អនុប្រធាន និងសមាជិក មសស ដែលចែកចេញជា ៣ផ្នែកគឺ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ** មាន៨សំណួរ ទាក់ទងទៅនឹងតួនាទី កន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ មុខវិជ្ជាឯកទេស បទពិសោធន៍ការងារ និងភាសាបរទេស។

**ផ្នែកទី២៖ ប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍**

មានសមាសភាគចំនួន៦ គឺការរៀបចំផែនការ (១០សំណួរ) កសាងសមត្ថភាពគ្រូ (៩សំណួរ) កសាងសមត្ថភាពសិស្ស (៦សំណួរ) ភាគីពាក់ព័ន្ធ (៥សំណួរ) ធនធានរូបវន្ត (៦សំណួរ) និង ការធានាគុណភាព(៧សំណួរ)ជាឧបករណ៍សម្រាប់វាស់ពីកម្រិតនៃប្រសិទ្ធភាពរបស់គណៈគ្រប់គ្រង មសស និង ដំណោះស្រាយការលើកកម្ពស់គុណភាពការសិក្សាជំនាញអប់រំបច្ចេកទេសឱ្យកាន់តែប្រសើរឡើង ស្របនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន ក្នុងខេត្តកំពង់ស្ពឺ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែម ពីការឆ្លើយតបរបស់គណៈគ្រប់គ្រង នៅផ្នែកទី២ ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

**ផ្នែកទី៣៖ បញ្ហាប្រឈមនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍**

មានសមាសភាគចំនួន១ គឺកត្តាគណៈគ្រប់គ្រង (១១សំណួរ) ជាឧបករណ៍សម្រាប់ឆ្លុះបញ្ចាំងពីដំណោះស្រាយការលើកកម្ពស់គុណភាពការសិក្សាជំនាញអប់រំបច្ចេកទេសឱ្យកាន់តែប្រសើរឡើង ស្របនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន ក្នុងខេត្តកំពង់ស្ពឺ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គណៈគ្រប់គ្រងនៅផ្នែកទី៣ ស្តីពី ទី១ "តើលោក-លោកស្រី ជួបប្រទះការលំបាកអ្វីខ្លះ ក្នុងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ នៅខេត្តកំពង់ស្ពឺ" ទី២ "ពេលជួបការលំបាកខាងលើ តើលោក-លោកស្រី បានដោះស្រាយយ៉ាងដូចម្តេចខ្លះ?" ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

### ៣.៣.២.២ កម្រងសំណួរសម្រាប់គ្រូបង្រៀន

កម្រងសំណួរគ្រូ គឺប្រើប្រាស់សម្រាប់ការប្រមូលទិន្នន័យ ពីគ្រូបង្រៀនអប់រំបច្ចេកទេស ដែលកំពុងបង្រៀននៅក្នុង មសស ដែលចែកចេញជា ៣ផ្នែកគឺ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ** មាន៨សំណួរ ទាក់ទងទៅនឹងស្ថានភាពដែលជាគ្រូបង្រៀន កំពុងបង្រៀននៅ មសស ទាក់ទងនឹង តួនាទី មុខវិជ្ជាឯកទេស ទីកន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ បង្រៀនជំនាញឯកទេស បទពិសោធន៍ការងារ និង ភាសាបរទេស។

**ផ្នែកទី២៖ ប្រសិទ្ធភាព នៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍**

មានសមាសភាគចំនួន៦ គឺការងារគ្រប់គ្រងនិងដឹកនាំ(៨សំណួរ) ការងារកសាងសមត្ថភាពគ្រូរបស់ថ្នាក់ដឹកនាំ(៩សំណួរ) ការងាររបស់ថ្នាក់ដឹកនាំ លើលទ្ធផលសិក្សាសិស្ស(៦សំណួរ) ភាគីពាក់ព័ន្ធ(៥សំណួរ)ធនធានរូបវន្ត(៦សំណួរ) និងការធានាគុណភាព របស់ថ្នាក់ដឹកនាំ(៧សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍និងដំណោះស្រាយការលើកកម្ពស់គុណភាពការសិក្សាជំនាញអប់រំបច្ចេកទេសឱ្យកាន់តែប្រសើរឡើង ស្របនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន ក្នុងខេត្តកំពង់ស្ពឺ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គ្រូបង្រៀននៅផ្នែកទី២ ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់និងគ្រប់ជ្រុងជ្រោយ។

**ផ្នែកទី៣៖ បញ្ហាប្រឈមនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍**

មានសមាសភាគចំនួន១ គឺកត្តាគ្រូបង្រៀន (១១សំណួរ) ជាឧបករណ៍សម្រាប់ឆ្លុះបញ្ចាំងពីដំណោះស្រាយការលើកកម្ពស់គុណភាពការសិក្សាជំនាញអប់រំបច្ចេកទេសឱ្យកាន់តែប្រសើរឡើង ស្របនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន ក្នុងខេត្តកំពង់ស្ពឺ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គ្រូបង្រៀននៅផ្នែកទី៣ ស្តីពី ទី១ "តើលោកគ្រូ-អ្នកគ្រូ ជួបប្រទះការលំបាកអ្វីខ្លះក្នុងការបំពេញការងារនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ នៅខេត្តកំពង់ស្ពឺ?" ទី២ " ពេលជួបការលំបាកខាងលើ តើលោកគ្រូ-អ្នកគ្រូ បានដោះស្រាយយ៉ាងដូចម្តេចខ្លះ?" ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

### ៣.៣.២.៣ កម្រងសំណួរសម្រាប់សិស្ស

កម្រងសំណួរសិស្ស គឺប្រើសម្រាប់ប្រមូលទិន្នន័យពីសិស្សដែលកំពុងរៀនអប់រំបច្ចេកទេសនៅមសស ដែលចែកចេញជា ២ផ្នែកគឺ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ** មាន៣សំណួរ ទាក់ទងទៅនឹង ភេទ សិក្សាឯកទេសផ្នែក ទីកន្លែងសិក្សា កម្រិតវប្បធម៌។

**ផ្នែកទី២៖ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនៅមជ្ឈមណ្ឌលសិក្សាសហគមន៍**

មានសមាសភាគចំនួន៣ គឺអំពីមេរៀន (៦សំណួរ) ការបង្រៀនរបស់គ្រូ (៥សំណួរ) និងការសិក្សារៀនសូត្រ(៨សំណួរ)ជាឧបករណ៍សម្រាប់វាស់ពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនៅ មសស។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់សិស្សនៅផ្នែកទី២ ស្តីពីមេរៀន ការបង្រៀន និងការសិក្សាការអប់រំបច្ចេកទេស ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

### ៣.៣.២.៤ កម្រងសំណួរសម្រាប់អាគីពាក់ព័ន្ធ

កម្រងសំណួរសិស្ស គឺប្រើសម្រាប់ប្រមូលទិន្នន័យពីសិស្សដែលកំពុងរៀនអប់រំបច្ចេកទេសនៅ មសស ដែលចែកចេញជា ២ផ្នែកគឺ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ** មាន៤សំណួរ ទាក់ទងទៅនឹង ទីកន្លែង ភេទ អាយុ និងកម្រិតវប្បធម៌។

**ផ្នែកទី២៖ ការយល់ឃើញ លើឥរិយាបថបំពេញការងាររបស់អតីតសិស្សបានទទួលការអប់រំបច្ចេកទេសជាមួយមជ្ឈមណ្ឌលសិក្សាសហគមន៍**

មានសមាសភាគចំនួន១ គឺការយល់ឃើញ លើឥរិយាបថបំពេញការងាររបស់អតីតសិស្សជាឧបករណ៍សម្រាប់វាស់ពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនៅ មសស។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់សិស្សនៅផ្នែកទី២ ស្តីពីការយល់ឃើញ លើឥរិយាបថបំពេញការងាររបស់សិស្ស ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

## ៣.៤ ការជ្រើសរើសភាគសំណាក

ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរក្នុងចំនួន២៤ មសស នៅខេត្តកំពង់ស្ពឺ ដែលមានចំនួនសំណាកសរុប ១៥១នាក់ គណៈគ្រប់គ្រងចំនួន ៣៥នាក់ គ្រូចំនួន ៣១នាក់ សិស្សចំនួន ៧០នាក់ និងសហគមន៍ចំនួន ១៥នាក់។ ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។ ស្ថានភាពនៅពេលចុះប្រមូលទិន្នន័យគឺ ស្ថិតក្នុងបរិបទនៃការរក្សាគម្លាតសង្គម ដោយសារជំងឺ

កូវីដ-១៩។ មសស មួយចំនួននៅក្នុងខេត្តកំពង់ស្ពឺ មានស្ថានភាពទីតាំងភូមិសាស្ត្រខុសគ្នា ទៅតាមស្រុកនីមួយៗ ដោយ មសស ក្នុងស្រុកខ្លះមានភាពរីកចម្រើន មសស ខ្លះមានកម្រិតមធ្យម ហើយក៏មាន មសស ខ្លះទៀតស្ថិតនៅក្នុងតំបន់ជួបការលំបាក។ ចំនួនសំណាកក្នុងការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរ បានជ្រើសរើសក្រុង/ស្រុកចំនួន៧ ក្នុងខេត្តកំពង់ស្ពឺ គឺៈ ស្រុកសំរោងទង គងពិសី បរសេដ្ឋ ថ្ពង ភ្នំស្រួច ឱរ៉ាល់ និងឧដុង្គ។ ការចុះប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរនៅ មសស ចំនួន២៤ មានសំណាកសរុបចំនួន ១៥១នាក់ ដែលបែងចែកជា គណៈគ្រប់គ្រងចំនួន ៣៥នាក់ គ្រូចំនួន ៣១នាក់សិស្សចំនួន ៧០នាក់ និង សហគមន៍ចំនួន ១៥នាក់។

**តារាង ៣.១ៈ ៈចំនួនភាគសំណាកដែលបានទទួលទិន្នន័យពីកម្រងសំណួរ**

| ល.រ | ស្រុក | ចំនួន មសស | គណៈ គ្រប់គ្រង | ចំនួនគ្រូ | ចំនួនសិស្ស | ភាគីពាក់ព័ន្ធ |
|---|---|---|---|---|---|---|
| ១ | សំរោងទង | ៥ | ៥ | ៥ | ១០ | ៥ |
| ២ | គងពិសី | ២ | ៥ | ៤ | ១០ | |
| ៣ | បរសេដ្ឋ | ៥ | ៥ | ៦ | ១០ | |
| ៤ | ថ្ពង | ២ | ៥ | ៥ | ១០ | ៥ |
| ៥ | ភ្នំស្រួច | ៣ | ៥ | ៤ | ១០ | |
| ៦ | ឱរ៉ាល់ | ២ | ៥ | ២ | ១០ | |
| ៧ | ឧដុង្គ | ៥ | ៥ | ៥ | ១០ | ៥ |
| | **សរុប** | **២៤** | **៣៥** | **៣១** | **៧០** | **១៥** |

## ៣.៥ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរ ដែលមានលក្ខណៈជាពហុជ្រើសរើស ទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗក្នុងទម្រង់បិទ និងការផ្តល់មតិយោបល់សម្រាប់ស្វែងរកទិន្នន័យជាធាតុចូលបន្ថែម។

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ Microsoft Excel ដើម្បីសិក្សាពីភាគរយ

ពិន្ទុមធ្យមភាគ និងគម្លាតស្តង់ដារ ដើម្បីបកស្រាយទិន្នន័យតាមសូចនាករនីមួយៗ។ ការវិភាគលើមតិយោបល់បន្ថែម គឺអ្នកសិក្សាបានចាប់ក្រុមពាក្យទៅតាមទស្សនៈយល់ឃើញនីមួយៗ ពីការបំពេញកម្រងសំណួររធ្វើការផ្ទុះបញ្ចាំងទៅនិងមធ្យមភាគដែលទទួលបាន ព្រមទាំងស្រង់ជាតុចូលមួយចំនួនពីអ្នកឆ្លើយតប ដាក់ក្នុងសំណូមពរ។

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

ក្នុងជំពូកទី៤នេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយ និងពិភាក្សានូវអ្វីដែលត្រូវបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ លើក្រុមគោលដៅដែលពាក់ព័ន្ធ រួមមាន គណៈគ្រប់គ្រង មសស លោកគ្រូ-អ្នកគ្រូ សិស្សជំនាញ និង សហគមន៍។ រាល់ចំណុចសំខាន់ៗមួយចំនួនដែលទាក់ទងនឹងប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងបញ្ហាប្រឈមនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ នៅក្នុងខេត្តកំពង់ស្ពឺនាពេលកន្លងមកត្រូវបានលើកយកមកបកស្រាយ និងពិភាក្សា។

## ៤.១. ទិន្នន័យព័ត៌មានទូទៅពីគណៈគ្រប់គ្រង គ្រូជំនាញ សិស្ស និង សហគមន៍

### ៤.១.១.ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់យក មសស ក្នុងក្រុង/ស្រុក ចំនួន ៧ ក្នុងខេត្តកំពង់ស្ពឺ ជាគោលដៅនៃការសិក្សាស្រាវជ្រាវ ដែលមាន ស្រុកសំរោងទង ៥ ស្រុកភ្នំស្រួច ៤ ស្រុកគងពិសី ២ ស្រុកបរសេដ្ឋ ៣ ស្រុកថ្ពង ២ ស្រុកឧដុង្គ ៥ ស្រុក ។

នៅក្នុងផ្នែកនេះ មានបង្ហាញព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង លោកគ្រូ អ្នក ដែលជាសំណាកស្រាវជ្រាវទាំងអស់ ដែលមានព័ត៌មានលម្អិតពី កម្រិតថ្នាក់ ភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍បង្រៀន និងមុខវិជ្ជាឯកទេសដូចក្នុងតារាងខាងក្រោម៖

តាមទិន្នន័យ*(តារាងឧបសម្ព័ន្ធ ក)* ដែលទទួលបានពី គណៈគ្រប់គ្រង បានបង្ហាញថា គណៈគ្រប់គ្រង មានភេទ ប្រុសមានចំនួន ៨០% នៃចំនួនសរុប ៣៥នាក់ ក្រៅពីនោះជាស្ត្រី។ អាយុនៃគណៈគ្រប់គ្រងភាគច្រើនលើសពី ៤០ឆ្នាំ។ ហើយគណៈគ្រប់គ្រងអាយុតិចមានអាយុចន្លោះពី ២៥ ដល់ ៣០ឆ្នាំ និង ៣១ ដល់ ៥០ឆ្នាំ។ ក្រៅពីនេះគឺ អាយុចន្លោះពី ៣៦ ដល់ ៤០ឆ្នាំ។ សម្រាប់កម្រិតសញ្ញាបត្រគណៈគ្រប់គ្រងភាគច្រើនមានសញ្ញាបត្រចប់ថ្នាក់ទី១២។ ហើយគណៈគ្រប់គ្រងភាគតិចមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់។ ក្រៅពីនេះគឺគណៈគ្រប់គ្រងគឺមានសញ្ញាបត្រត្រឹមបរិញ្ញាបត្រ។ ចំណែកជំនាញ

ឯកទេស ភាគច្រើន មានឯកទេសផ្សេងៗ មានចំនួន ៩៧% នៃចំនួនសរុប ៣៥នាក់។ ក្រៅពីនេះមាន ជំនាញគ្រប់គ្រង មានតែ ១ % នៃចំនួនសរុបខាងលើ ។ ចំពោះបទពិសោធន៍ការងារ គណៈគ្រប់គ្រងភាគច្រើនសុទ្ធតែមានបទពិសោធន៍លើសពី ១៥ឆ្នាំ មានចំនួន៤៩%នៃចំនួនសរុប ៣៥នាក់។ គណៈគ្រប់គ្រងដែលមានភាគតិចលើបទពិសោធន៍ការងារគឺចន្លោះពី៦ដល់១០ឆ្នាំ។ក្រៅពីនេះគឺមានបទពិសោធន៍ការងារចន្លោះពី ១ ដល់ ៥ ឆ្នាំ និង ៦ ដល់ ១០ឆ្នាំ ។ សម្រាប់ភាសាបរទេស គណៈគ្រប់គ្រងភាគច្រើន មិនចេះភាសាបរទេស រហូតដល់ ៨៣% នៃចំនួន គណៈគ្រប់គ្រងសរុប ៣៥ នាក់ ហើយមានត្រឹមតែ ១៤% ដែលចេះភាសាអង់គ្លេស និង ១% ចេះភាសាបារាំង ។

### ៤.១.២.ព័ត៌មានទូទៅរបស់គ្រូ

តាមទិន្នន័យដែលទទួលបានពី លោកគ្រូ អ្នកគ្រូ( *តារាងឧបសម្ព័ន្ធ ខ)* បានបង្ហាញថា គ្រូជំនាញ មុខវិជ្ជាឯកទេស ពេទ្យសត្វ ចំនួន ២៦% និង ជំនាញកុំព្យូទ័រ ២៦% នៃចំនួនសរុប ៣១នាក់ ហើយជំនាញតិចជាងគេ គឺ ភ្លេងប្រពៃណីខ្មែរ, ពិណពាទ្យ និង ស្ទូត មានត្រឹមតែ ១% នៃចំនួនគ្រូសរុបខាងលើ ។ ចំណែកឯភេទ គ្រូជំនាញជាបុរសមានចំនួន ៥៨% នៃចំនួនសរុប ៣១នាក់ ក្រៅពីនេះជាស្ត្រីទាំងអស់។ អាយុ គ្រូជំនាញភាគច្រើនចន្លោះពី ២៥ ដល់៣០ឆ្នាំ។ ហើយគ្រូជំនាញ ភាគតិចមានអាយុចន្លោះពី៣៦ ដល់ ៤០ឆ្នាំ។ ចំពោះកម្រិតសញ្ញាបត្រ ជំនាញភាគច្រើនមានសញ្ញាបត្រចប់ថ្នាក់ទី១២។ រីឯសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ មិនមានទេ។ ក្រៅពីនេះគឺគ្រូជំនាញដែលមានសញ្ញាបត្របរិញ្ញាបត្រ និងបញ្ចប់សញ្ញាបត្រកម្រិតផ្សេងៗទៀត។ ចំពោះបទពិសោធន៍បង្រៀន គ្រូជំនាញភាគច្រើនសុទ្ធតែមានបទពិសោធន៍បង្រៀនចន្លោះពី១ ដល់ ៥ឆ្នាំមានចំនួន ៦១% នៃចំនួនសរុប ៣១នាក់ គ្រូជំនាញភាគតិចដែលមានបទពិសោធន៍បង្រៀនគឺចន្លោះពី១១ ដល់ ១៥ឆ្នាំ និង លើស ១៥ឆ្នាំ។ ភាសាបរទេស គ្រូជំនាញភាគច្រើន មិនចេះភាសាបរទេស រហូតដល់ ៧១% នៃចំនួនគ្រូជំនាញសរុប ៣១ នាក់ ហើយមានត្រឹមតែ ២៩% ដែលចេះភាសាអង់គ្លេស និង ១% ចេះភាសាបារាំង ។

### ៤.១.៣ ព័ត៌មានទូទៅរបស់សិស្ស

តាមទិន្នន័យដែលទទួលបានពី សិស្សជំនាញវិជ្ជាជីវៈ *( តារាងឧបសម្ព័ន្ធ គ)* បានបង្ហាញថា

សិស្សជំនាញមានភេទភេទស្រីមានចំនួន ៥៩% នៃចំនួនសរុប៧០នាក់ ក្រៅពីនេះជាបុរស។ ចំពោះមុខវិជ្ជាឯកទេសដែលសរុបមានមុខជំនាញ ៧ មុខ ( ពេទ្យសត្វ,កាត់សក់,កុំព្យូទ័រ,កាត់ដេរ, ភ្លេងប្រពៃណីខ្មែរភ្លេងពិណពាទ្យ,ផាត់មុខ) សិស្សភាគច្រើនចូលចិត្តរៀន ឯកទេសពេទ្យសត្វ ច្រើនជាងគេ មានចំនួន ២៦% នៃចំនួនសរុប ៧០នាក់ ជំនាញកុំព្យូទ័រ ២៣% និង ជំនាញទី ៣ គឺផាត់មុខ មាន ១០% នៃចំនួនសរុបសិស្ស ៧០ នាក់ ។ ចំណែកកម្រិតសញ្ញាបត្រ សិស្សភាគច្រើន មានសញ្ញាបត្រត្រឹមកម្រិត បឋមភូមិ ចំនួន ៧៩% កម្រិតបឋមសិក្សា ១៧% និង កម្រិតវិទ្យាល័យ ៤% ។

### ៤.១.៤.ព័ត៌មានទូទៅរបស់សហគមន៍

តាមទិន្នន័យដែលទទួលបានពី សហគមន៍ *(តារាងឧបសម្ព័ន្ធ យ)* បានបង្ហាញថា ភាគីពាក់ព័ន្ធជាម្ចាស់ហាង ឬ សិប្បកម្ម សរុបមានចំនួន ៧ ហាង( ចិញ្ចឹមមាន់,កាត់សក់,បោះពុម្ព,កាត់ដេរ,សំអាងការ, ភ្លេងខ្មែរ,ពិណពាណ្យ )សិស្សរៀនហើយទៅ ធ្វើការចិញ្ចឹមសត្វខ្លួនឯងមានច្រើនជាងគេ មានចំនួន ២៧% ចូលធ្វើការក្នុងរោងពុម្ពកុំព្យូទ័រ និងហាងកាត់ដេរ ចំនួន ២០% និងជំនាញទី ៣ គឺកាត់សក់ មាន ១៣% នៃចំនួនភាគីពាក់ព័ន្ធដែលបានឆ្លើយសំណួរចំនួន ១៥ នាក់។ចំពោះភេទ ភាគីពាក់ព័ន្ធ ភេទប្រុសមានចំនួន ៦០% នៃចំនួនសរុប១៥នាក់ ក្រៅពីនេះជាស្ត្រី។ ចំណែកអាយុ ភាគីពាក់ព័ន្ធភាគច្រើន មានអាយុចន្លោះពី ៣១ ដល់ ៣៥ ឆ្នាំនិង លើសពី ៤០ឆ្នាំ។ ហើយភាគីពាក់ព័ន្ធអាយុតិចមានអាយុចន្លោះពី ៣៦ ដល់ ៤០ឆ្នាំ ។ ពីកម្រិតសញ្ញាបត្រះភាគីពាក់ព័ន្ធភាគច្រើន មានសញ្ញាបត្រត្រឹមកម្រិត ផ្សេងៗដល់ទៅ ចំនួន ៦០% កម្រិតចប់ទី១២ មាន៤០% ។

## ៤.២ ប្រសិទ្ធភាពគ្រប់គ្រងការអប់រំបច្ចេកទេស នៅសហគមន៍ មសស ខេត្តកំពង់ស្ពឺ

### ៤.២.១ ទិន្នន័យគណៈគ្រប់គ្រងឆ្លើយតបពីប្រសិទ្ធភាពនៃការគ្រប់គ្រង មសស

ការអនុវត្តលើការងារគ្រប់គ្រង ការអប់រំបច្ចេកទេសគឺជាចលករក្នុងការជំរុញ ការសិក្សាជំនាញបច្ចេកទេសឱ្យទទួលបានចំណេះដឹង ជំនាញ ដែលមានសមត្ថភាពក្លាយខ្លួនជា បុគ្គលិកជំនាញបច្ចេកទេសពិតប្រាកដ និងស្របតាមបទដ្ឋាន នៃការដឹកនាំគ្រប់គ្រង ដែលក្រសួងអប់រំ យុវជន និងកីឡា កំពុងធ្វើកំណែទម្រង់ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលអាណត្តិទី៦ ។

ក្នុងតារាងទិន្នន័យនេះបានបង្ហាញពីមធ្យមភាគសរុប នៃ**ការរៀបចំផែនការ** របស់គណៈគ្រប់គ្រង មសស ក្នុងខេត្តកំពង់ស្ពឺ ។

**តារាង៤.១៖ ៖ ការរៀបចំផែនការរបស់គណៈគ្រប់គ្រង**

| ល.រ | ការរៀបចំផែនការ | មធ្យម ភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | មានទស្សនៈវិស័យ និងគោលដៅដឹកនាំគ្រប់គ្រងច្បាស់លាស់ | 4.03 | 0.57 | ល្អ |
| ២ | អភិវឌ្ឍន៍កម្លាំងពលកម្មទៅតាមតម្រូវការទីផ្សារការងារ | 3.74 | 0.82 | ល្អ |
| ៣ | បានអនុវត្តការងារឆ្លើយតបទៅតាមគោលនយោបាយជាតិ | 4.00 | 0.59 | ល្អ |
| ៤ | ផ្តល់សេវាកម្មការអប់រំបច្ចេកទេស នូវមុខវិជ្ជាសំខាន់ៗដល់ពលរដ្ឋ | 4.31 | 0.47 | ល្អណាស់ |
| ៥ | រៀបចំកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស ទៅតាមតម្រូវការសហគមន៍ | 4.23 | 0.55 | ល្អណាស់ |
| ៦ | បានរៀបចំគោលការណ៍ស្តីពីអភិបាលកិច្ចល្អ | 4.11 | 0.53 | ល្អ |
| ៧ | មានបំណែងចែកភារកិច្ច និងការទទួលខុសត្រូវការងារច្បាស់លាស់ | 4.31 | 0.63 | ល្អណាស់ |
| ៨ | មានផែនការប្រកបដោយនិរន្តរ៍ ផ្នែកអប់រំបច្ចេកទេស | 4.09 | 0.61 | ល្អ |
| ៩ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់ ផ្នែកអប់រំបច្ចេកទេស | 3.71 | 0.96 | ល្អ |
| ១០ | បង្កើនយន្តការចុះឈ្មោះចូលរៀន | 4.14 | 0.36 | ល្អ |
| សរុប | | 4.07 | 0.61 | ល្អ |

តារាងទិន្នន័យ ៤.១ ខាងលើបានបង្ហាញពីមធ្យមភាគសរុប **ការរៀបចំផែនការ** របស់គណៈគ្រប់គ្រង មសស ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ"(មធ្យមភាគពិន្ទុ= ៤.០៧)។ សូចនាករ "មានបំណែងចែកភារកិច្ច និងការទទួលខុសត្រូវការងារច្បាស់លាស់" " រៀបចំកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស ទៅតាមតម្រូវការសហគមន៍ "និងសូចនាករ " ផ្តល់សេវាកម្មការអប់រំបច្ចេកទេស នូវមុខវិជ្ជាសំខាន់ៗដល់ពលរដ្ឋ" ទទួលបានការយល់ស្របខ្ពស់ជាងគេ "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៣១) ហើយ សូចនាករ " មានសៀវភៅសិក្សាគោលគ្រប់គ្រាន់ ផ្នែកអប់រំបច្ចេកទេស " ល្អ " (មធ្យមភាគពិន្ទុ =៣.៧១)។

**តារាង៤.២៖ កសាងសមត្ថភាពគ្រូ របស់គណៈគ្រប់គ្រង**

| ល.រ | កសាងសមត្ថភាពគ្រូ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | បានអភិវឌ្ឍន៍គុណភាព និងសមត្ថភាពជំនាញបច្ចេកទេសដល់គ្រូ | 3.74 | 0.78 | ល្អ |
| ២ | ទាក់ទាញបេក្ខជនដែលមានសមត្ថភាពជំនាញច្បាស់លាស់ចូលធ្វើជាគ្រូ | 4.23 | 0.43 | ល្អណាស់ |
| ៣ | បានអនុវត្តការផ្តល់ប្រព័ន្ធលាភការដល់គ្រូបង្រៀន | 3.71 | 0.86 | ល្អ |
| ៤ | បានរៀបចំអន្តេវាសិកដ្ឋាន និងបំពាក់សម្ភារបរិក្ខារគ្រប់គ្រាន់សម្រាប់គ្រូ | 3.06 | 1.16 | មធ្យម |
| ៥ | មានកំណត់លក្ខណវិនិច្ឆ័យគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស | 3.91 | 0.66 | ល្អ |
| ៦ | គ្រូ បានបង្រៀនតាមកាលវិភាគ និងបំណែងចែកកម្មវិធីសិក្សា | 4.31 | 0.53 | ល្អណាស់ |
| ៧ | គ្រូបង្រៀន បានចូលរួមធ្វើបច្ចុប្បន្នភាព ជាប្រចាំនូវកម្មវិធីសិក្សា | 4.09 | 0.51 | ល្អ |
| ៨ | គ្រូបង្រៀន មានគុណវុឌ្ឍិសមស្របតាមនិយាម និងគោលការណ៍ | 4.00 | 0.54 | ល្អ |
| ៩ | គ្រូបង្រៀន បានប្រើប្រាស់សៀវភៅវិធីសាស្រ្ត និងរៀនដោយច្នៃប្រឌិត | 4.06 | 0.54 | ល្អ |
| | **សរុប** | **3.90** | **0.67** | **ល្អ** |

តារាងទិន្នន័យ ៤.២ បានបង្ហាញពីមធ្យមភាគសរុប នៃ**ការកសាងសមត្ថភាពគ្រូ** របស់គណៈគ្រប់គ្រង ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ =៣.៩០)។ សូចនាករ " គ្រូបានបង្រៀនតាមកាលវិភាគ និងបំណែងចែកកម្មវិធីសិក្សា" និងសូចនាករ " ទាក់ទាញបេក្ខជនដែលមានសមត្ថភាពជំនាញច្បាស់លាស់ ចូលធ្វើជាគ្រូ" ទទួលបានការយល់ស្របខ្ពស់ជាងគេ "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៣១)ហើយសូចនាករ " បានរៀបចំអន្តេវាសិកដ្ឋាន និងបំពាក់សម្ភារបរិក្ខារគ្រប់គ្រាន់សម្រាប់គ្រូ"ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "មធ្យម"(មធ្យមភាគពិន្ទុ=៣.០៦)។

**តារាង៤.៣៖ កសាងសមត្ថភាពសិស្សរបស់គណៈគ្រប់គ្រង**

| ល.រ | ការកសាងសមត្ថភាពសិស្ស | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | បានផ្តល់ចំណេះដឹងជំនាញរឹង និង ការត្រិះរិះពិចារណាដល់សិស្ស | 3.97 | 0.38 | ល្អ |
| ២ | សិស្សដែលបានបញ្ចប់ការសិក្សា អាចស្វែងរកការងារបាន | 3.57 | 0.88 | ល្អ |
| ៣ | បានផ្តល់សេវាតម្រង់ទិសវិជ្ជាជីវៈដល់សិស្ស | 3.94 | 0.54 | ល្អ |
| ៤ | ផ្តល់តម្លាភាព ក្នុងការវាយតម្លៃលទ្ធផលសិក្សា របស់សិស្ស | 4.20 | 0.41 | ល្អ |
| ៥ | សិស្សមានសមត្ថភាពចំណេះដឹង លើជំនាញដែលបានបណ្តុះបណ្តាល | 3.94 | 0.42 | ល្អ |
| ៦ | មានប្រព័ន្ធលើកទឹកចិត្តសិស្ស ទៅតាមលំដាប់ពិន្ទុ | 3.83 | 0.75 | ល្អ |
| | **សរុប** | **3.91** | **0.56** | **ល្អ** |

តារាងទិន្នន័យ ៤.៣ បានបង្ហាញពីមធ្យមភាគសរុបនៃ**ការកសាងសមត្ថភាពសិស្ស** របស់គណៈគ្រប់គ្រង ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៩១)។ សូចនាករ " ផ្តល់តម្លាភាព ក្នុងការវាយតម្លៃលទ្ធផលសិក្សា របស់សិស្សទទួលបានការយល់ស្របខ្ពស់ជាងគេ "ល្អ" (មធ្យមភាគពិន្ទុ=៤.២០) ហើយសូចនាករ "សិស្សដែលបានបញ្ចប់ការសិក្សា អាចស្វែងរកការងារបាន" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " ល្អ" (មធ្យមភាគពិន្ទុ=៣.៥៧)។

**តារាង៤.៤៖ ភាគីពាក់ព័ន្ធរបស់គណៈគ្រប់គ្រង**

| ល.រ | ភាគីពាក់ព័ន្ធ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | ជំនាញក្នុងការផ្សព្វផ្សាយ និង សម្របសម្រួល ក្នុងក្របខណ្ឌការអប់រំបច្ចេកទេស | 3.83 | 0.57 | ល្អ |
| ២ | ជំរុញកិច្ចការប្រកួតប្រជែងថ្នាក់ជាតិ ក្នុងក្របខណ្ឌការអប់រំបច្ចេកទេស | 3.49 | 0.89 | ល្អ |
| ៣ | ប្រមូលផ្តុំធនធានសហគមន៍ ក្នុងការចូលរួមអភិវឌ្ឍន៍ការអប់រំបច្ចេកទេស | 3.91 | 0.70 | ល្អ |

| | | | | |
|---|---|---|---|---|
| ៤ | ប្រមូលផ្តុំដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងការចូលរួមអភិវឌ្ឍន៍ការអប់រំបច្ចេកទេស | 3.66 | 0.91 | ល្អ |
| ៥ | ផ្តល់វគ្គបណ្តុះបណ្តាលជំនាញ សម្របសម្រួល ជាមួយអង្គការដៃគូនានា | 3.37 | 1.03 | មធ្យម |
| | **សរុប** | **3.41** | **0.82** | **ល្អ** |

តារាងទិន្នន័យ៤.៤ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី**ភាគីពាក់ព័ន្ធ** របស់គណៈគ្រប់គ្រង ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៤១)។ សូចនាករប្រមូលផ្តុំធនធានសហគមន៍ ក្នុងការចូលរួមអភិវឌ្ឍន៍ការអប់រំបច្ចេកទេសទទួលបានការយល់ស្របខ្ពស់ជាងគេ "ល្អ" (មធ្យមភាគពិន្ទុ =៣.៩១) ហើយសូចនាករ "ផ្តល់វគ្គបណ្តុះបណ្តាលជំនាញ សម្របសម្រួល ជាមួយអង្គការដៃគូនានា" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " មធ្យម" (មធ្យមភាគពិន្ទុ=៣.៣៧)។

**តារាង៤.៥៖ ធនធានរូបវន្តរបស់គណៈគ្រប់គ្រង**

| ល.រ | ធនធានរូបវន្ត | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | ធនធានរូបវន្ត សម្ភារបរិក្ខារ គាំទ្រដល់ការបង្រៀន និង រៀន | 3.89 | 0.96 | ល្អ |
| ២ | ធនធានសម្ភារបរិក្ខារ រោងជាង គាំទ្រដល់ការសិក្សា | 3.31 | 1.16 | មធ្យម |
| ៣ | បានអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | 3.37 | 1.00 | មធ្យម |
| ៤ | បានបំពាក់សម្ភារបរិក្ខារផ្នែកអប់រំបច្ចេកទេស | 3.83 | 0.89 | ល្អ |
| ៥ | មានកញ្ចប់ថវិកាគ្រប់គ្រាន់ សម្រាប់ដំណើរការផ្នែកអប់រំបច្ចេកទេស | 3.34 | 1.08 | មធ្យម |
| ៦ | ធនធានរូបវន្ត ធានាបាននូវស្តង់ដារសុវត្ថិភាព | 3.34 | 0.87 | មធ្យម |
| | **សរុប** | **3.51** | **0.99** | **ល្អ** |

តារាងទិន្នន័យ៤.៥ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី **ធនធានរូបវន្ត** របស់គណៈគ្រប់គ្រង ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៥១)។ សូចនាករ

″ធនធានរូបវន្ត សម្ភារបរិក្ខារ គាំទ្រដល់ការបង្រៀន និង រៀន″ ទទួលបានការយល់ស្របខ្ពស់ជាងគេ "ល្អ″ (មធ្យមភាគពិន្ទុ=៣.៨៩) ហើយសូចនាករ "ធនធានសម្ភារបរិក្ខារ រោងជាង គាំទ្រដល់ការសិក្សា″ ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "មធ្យម″ (មធ្យមភាគពិន្ទុ ៣.៣១)។

**តារាង៤.៦ ៖ ការដឹកនាំគុណភាពរបស់គណៈគ្រប់គ្រង**

| ល.រ | ការដឹកនាំគុណភាព | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | បានពិនិត្យតម្រូវការ និងការផ្តត់ផ្គង់ដល់បុគ្គលិក និងគ្រូបង្រៀន | 3.97 | 0.57 | ល្អ |
| ២ | បានពង្រឹងការអនុវត្តគោលការណ៍ ស្តីពីការដឹកនាំគុណភាពសិក្សា | 4.09 | 0.37 | ល្អ |
| ៣ | មានការវាយតម្លៃ និងត្រួតពិនិត្យដំណើរការបង្រៀនរបស់គ្រូ | 4.20 | 0.41 | ល្អ |
| ៤ | បានរៀបចំគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស | 3.89 | 0.68 | ល្អ |
| ៥ | ផែនការបណ្តុះបណ្តាល ស្របតាមលទ្ធផលរំពឹងទុក | 3.77 | 0.65 | ល្អ |
| ៦ | បានរៀបចំការវាស់ស្ទង់សមត្ថភាពសិស្ស | 4.03 | 0.45 | ល្អ |
| ៧ | បានបង្កើតការស្រាវជ្រាវ ផ្នែកអប់រំបច្ចេកទេស ដើម្បីលើកកម្ពស់ការអនុវត្តគោលនយោបាយ | 3.71 | 0.79 | ល្អ |
| | **សរុប** | **3.95** | **0.56** | **ល្អ** |

តារាងទិន្នន័យ៤.៦ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី **ការដឹកនាំគុណភាព** របស់គណៈគ្រប់គ្រង ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ″ (មធ្យមភាគពិន្ទុ =៣.៩៥)។ សូចនាករ "មានការវាយតម្លៃ និងត្រួតពិនិត្យដំណើរការបង្រៀនរបស់គ្រូ″ ទទួលបានការយល់ស្របខ្ពស់ជាងគេ "ល្អ″(មធ្យមភាគពិន្ទុ =៤.២០)ហើយសូចនាករ "បានបង្កើតការស្រាវជ្រាវផ្នែកអប់រំបច្ចេកទេស ដើម្បីលើកកម្ពស់ការអនុវត្តគោលនយោបាយ″ ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " ល្អ″ (មធ្យមភាគពិន្ទុ=៣.៧១)។

តារាង៤.៧៖ សរុបគណៈគ្រប់គ្រងពីប្រសិទ្ធភាពនៃការគ្រប់គ្រង

| ល.រ | បរិយាយ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ក | ការរៀបចំផែនការ | 4.07 | 0.61 | ល្អ |
| ខ | កសាងសមត្ថភាពគ្រូ | 3.90 | 0.67 | ល្អ |
| គ | កសាងសមត្ថភាពសិស្ស | 3.91 | 0.56 | ល្អ |
| ឃ | ភាគីពាក់ព័ន្ធ | 3.41 | 0.82 | ល្អ |
| ង | ធនធានរូបវន្ត | 3.41 | 0.99 | ល្អ |
| ច | ការជានាគុណភាព | 3.51 | 0.56 | ល្អ |
| **សរុប** | | **3.70** | **0.70** | **ល្អ** |

យោងតាមតារាងទិន្នន័យ ៤.៧ បានបង្ហាញពីប្រសិទ្ធភាពនៃការគ្រប់គ្រង របស់គណៈគ្រប់គ្រង មានកម្រិត "ល្អ"(មធ្យមភាគពិន្ទុ=៣.៧០)។ សូចនាករ "ការរៀបចំផែនការ" ទទួលបានការយល់ស្របខ្ពស់ជាងគេ"ល្អ" (មធ្យមភាគពិន្ទុ =៤.០៧) ហើយសូចនាករ "ភាគីពាក់ព័ន្ធ" និង"ធនធានរូបវន្ត"ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " ល្អ" (មធ្យមភាគពិន្ទុ=៣.៤១)។

ក្នុងន័យនេះគណៈគ្រប់គ្រងបានអនុវត្តផែនការសម្រាប់ ដំណើរការកិច្ចការងារប្រចាំថ្ងៃនៅក្នុងអង្គភាពទៅតាមផែនការដែលបានរៀបចំទុកនិងកំណត់បានច្បាស់លាស់។ ដោយឡែកទាក់ទងទៅនឹងផ្នែកកិច្ចការងារជាមួយភាគីពាក់ព័ន្ធនិងការកសាងធនធានរូបវន្តតម្រូវឱ្យគណៈគ្រប់គ្រងបំពេញបន្ថែមសំដៅលើកកម្ពស់កិច្ចការងារអប់រំបច្ចេកទេសកាន់តែមានប្រសិទ្ធផលនិងប្រសិទ្ធភាព ។

### ៤.២.២ ទិន្នន័យពីលោកគ្រូ អ្នកគ្រូឆ្លើយតបនឹង ប្រសិទ្ធភាពនៃការគ្រប់គ្រង

កិច្ចការបង្រៀន និងដំណើរការផ្ទេរចំណេះដឹង បទពិសោធន៍វិជ្ជាជីវៈលើការអប់រំបច្ចេកទេសដល់សិស្សគ្រប់រូប គឺតម្រូវអោយអ្នកសិក្សាមានជំនាញមួយពិតប្រាកដ ជានាបាននូវគុណភាពការងារ ឆ្លើយតបតម្រូវការដាក់ស្តែងលើជំនាញ។ លទ្ធផលនៃការសិក្សារបស់សិស្ស លើការអប់រំបច្ចេកទេស ឆ្លុះបញ្ចាំងតាមរយៈកិច្ចការងារដែលអាចបំពេញបានលើជំនាញរបស់សិស្សម្នាក់ៗ។

តារាង៤.៨៖ ការងារគ្រប់គ្រង និងដឹកនាំ ឆ្លើយតបពីគ្រូបង្រៀន

| ល.រ | ការងារគ្រប់គ្រង និងដឹកនាំ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | មានទស្សនៈវិស័យ និងគោលដៅដឹកនាំគ្រប់គ្រងច្បាស់លាស់ | 3.94 | 0.73 | ល្អ |
| ២ | បានអនុវត្តការងារឆ្លើយតបទៅតាមគោលនយោបាយជាតិ | 4.00 | 0.56 | ល្អ |
| ៣ | ផ្តល់សេវាកម្មការអប់រំបច្ចេកទេស នូវមុខវិជ្ជាសំខាន់ៗដល់ពលរដ្ឋ | 4.23 | 0.47 | ល្អណាស់ |
| ៤ | រៀបចំកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស ទៅតាមតម្រូវការសហគមន៍ | 4.10 | 0.48 | ល្អ |
| ៥ | គណៈគ្រប់គ្រង អនុវត្តការងារឈរលើគោលការណ៍អភិបាលកិច្ចល្អ | 4.19 | 0.37 | ល្អ |
| ៦ | មានបំណែងចែកភារកិច្ច និងការទទួលខុសត្រូវការងារច្បាស់លាស់ | 4.16 | 0.45 | ល្អ |
| ៧ | មានផែនការប្រកបដោយនិរន្តរ ផ្នែកអប់រំបច្ចេកទេស | 4.16 | 0.76 | ល្អ |
| ៨ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់ ផ្នែកអប់រំបច្ចេកទេស | 3.77 | 0.68 | ល្អ |
| **សរុប** | | **4.07** | **0.56** | **ល្អ** |

តារាងទិន្នន័យ៤.៨ បានបង្ហាញពីមធ្យមភាគសរុបដែលបង្ហាញពី **ការងារគ្រប់គ្រង និងដឹកនាំ** របស់លោកគ្រូ អ្នកគ្រូ ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ =៤.០៧)។ សូចនាករ "ផ្តល់សេវាកម្មការអប់រំបច្ចេកទេស នូវមុខវិជ្ជាសំខាន់ៗដល់ពលរដ្ឋទទួលបានការយល់ស្របខ្ពស់ជាងគេ" "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.២៣) ហើយសូចនាករ " មានទស្សនៈវិស័យ និងគោលដៅដឹកនាំគ្រប់គ្រងច្បាស់លាស់" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " ល្អ" (មធ្យមភាគពិន្ទុ =៣.៩៤)។

**តារាង៤.៩ ៖ការងារកសាងសមត្ថភាពគ្រូ ឆ្លើយតបពីគ្រូបង្រៀន**

| ល.រ | ការងារកសាងសមត្ថភាពគ្រូ របស់ថ្នាក់ដឹកនាំ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | បានអភិវឌ្ឍន៍គុណភាព និងសមត្ថភាពជំនាញបច្ចេកទេសដល់គ្រូ | 3.48 | 0.81 | ល្អ |
| ២ | ទាក់ទាញបេក្ខជនដែលមានសមត្ថភាពជំនាញច្បាស់លាស់ ចូលធ្វើជាគ្រូ | 4.10 | 0.54 | ល្អ |

| | | | | |
|---|---|---|---|---|
| ៣ | បានអនុវត្តការផ្តល់ប្រព័ន្ធលាភការដល់គ្រូបង្រៀន | 3.71 | 0.69 | ល្អ |
| ៤ | បានរៀបចំអន្តេវាសិកដ្ឋាន និងបំពាក់សម្ភារបរិក្ខារគ្រប់គ្រាន់សម្រាប់គ្រូ | 2.61 | 0.99 | មធ្យម |
| ៥ | មានកំណត់លក្ខណវិនិច្ឆ័យគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស | 3.81 | 0.54 | ល្អ |
| ៦ | គ្រូ បង្រៀនតាមកាលវិភាគ និងបំណែងចែកកម្មវិធីសិក្សា | 4.16 | 0.37 | ល្អ |
| ៧ | គ្រូបង្រៀន បានចូលរួមធ្វើបច្ចុប្បន្នភាព ជាប្រចាំនូវកម្មវិធីសិក្សា | 3.87 | 0.88 | ល្អ |
| ៨ | គ្រូបង្រៀន មានគុណវុឌ្ឍិសមស្របតាមនិយាម និងគោលការណ៍ | 3.68 | 0.75 | ល្អ |
| ៩ | គ្រូបង្រៀន ប្រើប្រាស់ សៀវភៅវិធីសាស្រ្ត និងរៀនដោយច្នៃប្រឌិត | 4.26 | 0.63 | ល្អណាស់ |
| **សរុប** | | **3.74** | **0.69** | **ល្អ** |

តារាងទិន្នន័យ៤.៩ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី **ការងារកសាងសមត្ថភាពគ្រូរបស់ថ្នាក់ដឹកនាំ របស់**លោកគ្រូ អ្នកគ្រូ ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៧៤)។ សូចនាករ "គ្រូបង្រៀនប្រើប្រាស់សៀវភៅវិធីសាស្រ្តនិងរៀនដោយច្នៃប្រឌិត" ទទួលបានការយល់ស្របខ្ពស់ជាងគេ "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.២៦)ហើយសូចនាករ " បានរៀបចំអន្តេវាសិកដ្ឋាន និងបំពាក់សម្ភារបរិក្ខារគ្រប់គ្រាន់សម្រាប់គ្រូ"ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " មធ្យម"(មធ្យមភាគពិន្ទុ=២.៦១)។

**តារាង៤.១០ ៖តារាងទិន្នន័យ ការងាររបស់ថ្នាក់ដឹកនាំ ឆ្លើយតបពីគ្រូបង្រៀន**

| ល.រ | ការងាររបស់ថ្នាក់ដឹកនាំ លើលទ្ធផលសិក្សាសិស្ស | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | បានផ្តល់ចំណេះដឹងជំនាញរឹង និង ការត្រិះរិះពិចារណាដល់សិស្ស | 4.10 | 0.40 | ល្អ |
| ២ | សិស្សដែលបានបញ្ចប់ការសិក្សា អាចស្វែងរកការងារបាន | 3.81 | 0.79 | ល្អ |
| ៣ | បានផ្តល់សេវាតម្រង់ទិសវិជ្ជាជីវៈដល់សិស្ស | 3.84 | 0.73 | ល្អ |

| | | | | |
|---|---|---|---|---|
| ៤ | ផ្តល់តម្លាភាព ក្នុងការវាយតម្លៃលទ្ធផលសិក្សា របស់សិស្ស | 4.19 | 0.40 | ល្អ |
| ៥ | សិស្សមានសមត្ថភាពចំណេះដឹង លើជំនាញដែលបានបណ្តុះបណ្តាល | 4.13 | 0.34 | ល្អ |
| ៦ | មានប្រព័ន្ធលើកទឹកចិត្តសិស្ស ទៅតាមលំដាប់ពិន្ទុ | 3.90 | 0.70 | ល្អ |
| | **សរុប** | **3.99** | **0.56** | **ល្អ** |

តារាងទិន្នន័យ៤.១០ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី **ការងាររបស់ថ្នាក់ដឹកនាំ លើលទ្ធផលសិក្សាសិស្ស របស់**លោកគ្រូ អ្នកគ្រូ ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៩៩)។ សូចនាករ "ផ្តល់តម្លាភាព ក្នុងការវាយតម្លៃលទ្ធផលសិក្សា របស់សិស្ស" ទទួលបានការយល់ស្របខ្ពស់ជាងគេ"ល្អណាស់" (មធ្យមភាគពិន្ទុ=៤.១៩) ហើយសូចនាករ " សិស្សដែលបានបញ្ចប់ការសិក្សា អាចស្វែងរកការងារបាន" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " ល្អ" (មធ្យមភាគពិន្ទុ =៣.៨១)។

**តារាង៤.១១៖ ភាគីពាក់ព័ន្ធឆ្លើយតបពីគ្រូបង្រៀន**

| ល.រ | ភាគីពាក់ព័ន្ធ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | ជំនាញក្នុងការផ្សព្វផ្សាយ និងសម្របសម្រួល ក្នុងក្របខណ្ឌការអប់រំបច្ចេកទេស | 3.68 | 0.70 | ល្អ |
| ២ | ជំរុញកិច្ចការប្រកួតប្រជែងថ្នាក់ជាតិ ក្នុងក្របខណ្ឌការអប់រំបច្ចេកទេស | 3.23 | 0.84 | មធ្យម |
| ៣ | ប្រមូលផ្តុំធនធានសហគមន៍ ក្នុងការចូលរួមអភិវឌ្ឍន៍ការអប់រំបច្ចេកទេស | 3.65 | 0.75 | ល្អ |
| ៤ | ប្រមូលផ្តុំដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងការចូលរួមអភិវឌ្ឍន៍ការអប់រំបច្ចេកទេស | 3.58 | 0.67 | ល្អ |
| ៥ | ផ្តល់វគ្គបណ្តុះបណ្តាលជំនាញ សម្របសម្រួល ជាមួយអង្គការដៃគូនានា | 3.32 | 0.83 | មធ្យម |
| | **សរុប** | **3.28** | **0.76** | **មធ្យម** |

តារាងទិន្នន័យ៤.១១ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី **ភាគីពាក់ព័ន្ធ របស់**លោកគ្រូអ្នកគ្រូ ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត ″ មធ្យម″ (មធ្យមភាគពិន្ទុ= ៣.២៨)។ សូចនាករ ″ជំនាញក្នុងការផ្សព្វផ្សាយ និងសម្របសម្រួល ក្នុងក្របខណ្ឌការអប់រំបច្ចេកទេស″ទទួលបានការយល់ស្របខ្ពស់ជាងគេ ″ល្អ″ (មធ្យមភាគពិន្ទុ=៣.៦៨) ហើយសូចនាករ ″ ជំរុញកិច្ចការប្រកួតប្រជែងថ្នាក់ជាតិ ក្នុងក្របខណ្ឌការអប់រំបច្ចេកទេស″ ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត ″ មធ្យម″ (មធ្យមភាគពិន្ទុ=៣.២៨)។

**តារាង៤.១២៖ ធនធានរូបវន្តឆ្លើយតបពីគ្រូបង្រៀន**

| ល.រ | ធនធានរូបវន្ត | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | ធនធានរូបវន្ត សម្ភារបរិក្ខារ គាំទ្រដល់ការបង្រៀន | 3.77 | 0.56 | ល្អ |
| ២ | ធនធានសម្ភារបរិក្ខារ រោងជាង គាំទ្រដល់ការសិក្សា | 3.19 | 0.83 | មធ្យម |
| ៣ | បានអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | 3.29 | 0.78 | មធ្យម |
| ៤ | បានបំពាក់សម្ភារបរិក្ខារផ្នែកអប់រំបច្ចេកទេស | 3.16 | 0.78 | មធ្យម |
| ៥ | មានកញ្ចប់ថវិកាគ្រប់គ្រាន់ សម្រាប់ដំណើរការផ្នែកអប់រំបច្ចេកទេស | 3.58 | 0.67 | ល្អ |
| ៦ | ធនធានរូបវន្ត ធានាបាននូវស្តង់ដារសុវត្ថិភាព | 3.19 | 0.54 | មធ្យម |
|  | **សរុប** | **3.37** | **0.70** | **មធ្យម** |

តារាងទិន្នន័យ៤.១២ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី **ធនធានរូបវន្ត** របស់លោកគ្រូអ្នកគ្រូ ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត ″ មធ្យម″ (មធ្យមភាគពិន្ទុ =៣.៣៧)។ សូចនាករ ″ធនធានរូបវន្ត សម្ភារបរិក្ខារ គាំទ្រដល់ការបង្រៀន″ទទួលបានការយល់ស្របខ្ពស់ជាងគេ ″ល្អ″ (មធ្យមភាគពិន្ទុ= ៣.៧៧) ហើយសូចនាករ ″ ″ បានបំពាក់សម្ភារបរិក្ខារផ្នែកអប់រំបច្ចេកទេស″ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត ″ ″មធ្យម″ (មធ្យមភាគពិន្ទុ =៣.១៦)។

**តារាង៤.១៣៖ ការធានាគុណភាព របស់ថ្នាក់ដឹកនាំឆ្លើយតបពីគ្រូបង្រៀន**

| ល.រ | បរិយាយ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | បានពិនិត្យតម្រូវការ និងការផ្គត់ផ្គង់ដល់បុគ្គលិក និងគ្រូបង្រៀន | 3.94 | 0.44 | ល្អ |
| ២ | បានពង្រឹងការអនុវត្តគោលការណ៍ ស្តីពីការធានាគុណភាពសិក្សា | 4.00 | 0.26 | ល្អ |
| ៣ | មានការវាយតម្លៃ និងត្រួតពិនិត្យដំណើរការបង្រៀនរបស់គ្រូ | 4.13 | 0.43 | ល្អ |
| ៤ | បានរៀបចំគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស | 3.90 | 0.54 | ល្អ |
| ៥ | ផែនការបណ្តុះបណ្តាល ស្របតាមលទ្ធផលរំពឹងទុក | 3.81 | 0.54 | ល្អ |
| ៦ | បានរៀបចំការវាស់ស្ទង់សមត្ថភាពសិស្ស | 4.13 | 0.43 | ល្អ |
| ៧ | បានបង្កើតការស្រាវជ្រាវ ផ្នែកអប់រំបច្ចេកទេស ដើម្បីលើកកម្ពស់ការអនុវត្តគោលនយោបាយ | 3.65 | 0.71 | ល្អ |
| **សរុប** | | **3.94** | **0.48** | **ល្អ** |

តារាងទិន្នន័យ៤.១៣ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី **ការធានាគុណភាព របស់ថ្នាក់ដឹកនាំ** របស់លោកគ្រូ អ្នកគ្រូក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត " មធ្យម" (មធ្យមភាគពិន្ទុ=៣.៩៤)។ សូចនាករ "មានការវាយតម្លៃ និងត្រួតពិនិត្យដំណើរការបង្រៀនរបស់គ្រូ" និង "បានរៀបចំការវាស់ស្ទង់សមត្ថភាពសិស្ស" ទទួលបានការយល់ស្របខ្ពស់ជាងគេ"ល្អ" (មធ្យមភាគពិន្ទុ=៤.១៣) ហើយសូចនាករ " ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " បានបង្កើតការស្រាវជ្រាវផ្នែកអប់រំបច្ចេកទេសដើម្បីលើកកម្ពស់ការអនុវត្តគោលនយោបាយ "ល្អ" (មធ្យមភាគពិន្ទុ=៣.៦៥)។

**តារាង៤.១៤ ៖ សរុប លោកគ្រូ អ្នកគ្រូ ឆ្លើយតបនឹងប្រសិទ្ធភាពនៃការគ្រប់គ្រង**

| ល.រ | បរិយាយ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ក | ការងារគ្រប់គ្រង និងដឹកនាំ | 4.07 | 0.56 | ល្អ |
| ខ | ការងារកសាងសមត្ថភាពគ្រូ របស់ថ្នាក់ដឹកនាំ | 3.74 | 0.69 | ល្អ |
| គ | ការងាររបស់ថ្នាក់ដឹកនាំ លើលទ្ធផលសិក្សាសិស្ស | 3.99 | 0.56 | ល្អ |

| | | | | |
|---|---|---|---|---|
| ឃ | ភាគីពាក់ព័ន្ធ | 3.28 | 0.76 | មធ្យម |
| ង | ធនធានរូបវន្ត | 3.37 | 0.70 | មធ្យម |
| ច | ការជានាគុណភាព របស់ថ្នាក់ដឹកនាំ | 3.94 | 0.48 | ល្អ |
| **សរុប** | | **3.73** | **0.62** | **ល្អ** |

យោងតាមតារាងទិន្នន័យ៤.១៤ បានបង្ហាញពីសកម្មភាពរបស់លោកគ្រូ អ្នកគ្រូ មានកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៧៣)។សូចនាករ "ការងារគ្រប់គ្រង និងដឹកនាំ" ទទួលបានការយល់ស្របខ្ពស់ជាងគេ"ល្អ" (មធ្យមភាគពិន្ទុ =៤.០៧) ហើយសូចនាករ "ភាគីពាក់ព័ន្ធ" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " មធ្យម" (មធ្យមភាគពិន្ទុ=៣.២៨)។ ក្នុងន័យនេះលោកគ្រូ អ្នកគ្រូ បានចូលរួមអនុវត្តការងារដឹកនាំ និងគ្រប់គ្រងការបង្រៀនរបស់ខ្លួនស្របតាមកម្មវិធី ជាប្រចាំនិងគោរពការចាត់តាំងលើការងាររបស់មសស។ ចំណែកទាក់ទងនឹងការទំនាក់ទំនងជាមួយ ភាគីពាក់ព័ន្ធ និង ការកសាងសម្ភាររូបវន្ត ក៏តម្រូវឱ្យលោកគ្រូ អ្នកគ្រូចូលរួមក្នុងការបង្កើនលើការងារទំនាក់ទំនងបន្ថែមឱ្យកាន់តែប្រសើរឡើង ជាមួយភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការចូលរួមគាំទ្រធនធានរូបវន្ត លើការងារបង្រៀនបច្ចេកទេសឱ្យកាន់តែទទួលបានលទ្ធផល និងប្រសិទ្ធភាពនៃការបង្រៀននៅ មសស។

### ៤.២.៣ ទិន្នន័យឆ្លើយតបពីសិស្ស លើការអប់រំបណ្តុះបណ្តាលបច្ចេកទេស

តាមរយៈកម្មវិធីសិក្សាលើការអប់រំបច្ចេកទេស ការក្រេបយកចំណេះវិជ្ជា ជំនាញពីគ្រូ បទពិសោធន៍ពីគ្រូ និង ការរៀនសូត្រពីការអនុវត្តជាក់ស្តែង បានជំរុញលទ្ធភាព អោយសិស្ស មានចំណេះ ជំនាញពិតប្រាកដ។

**តារាង៤.១៥៖ អំពីមេរៀន ឆ្លើយតបពីសិស្ស**

| ល.រ | អំពីមេរៀន | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | មុខវិជ្ជាដែលបានរៀន ងាយស្រួលយល់ និងចងចាំ | 3.79 | 0.72 | ល្អ |
| ២ | មុខវិជ្ជាដែលបានរៀន គឺស្របតាមការរំពឹងទុករបស់សិស្ស | 3.94 | 0.51 | ល្អ |
| ៣ | ឯកសារមេរៀន បានជួយដល់ការ សិក្សារៀនសូត្រ | 3.87 | 0.76 | ល្អ |
| ៤ | មានសម្ភារៈឧបទ្ទេស ឆ្លើយតបនឹងវិធីសាស្ត្របង្រៀន | 3.57 | 0.88 | ល្អ |

| | | | | |
|---|---|---|---|---|
| ៥ | បានចូលរួម ក្នុងដំណើរការពិសោធន៍ | 3.90 | 0.64 | ល្អ |
| ៦ | មានការណែនាំ និងលើកទឹកចិត្តប្រើប្រាស់សៀវភៅពុម្ពសិក្សា | 3.94 | 0.61 | ល្អ |
| | **សរុប** | **3.84** | **0.69** | **ល្អ** |

តារាងទិន្នន័យ៤.១៥ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី **អំពីមេរៀន** របស់សិស្ស ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត " ល្អ"(មធ្យមភាគពិន្ទុ=៣.៨៤)។ សូចនាករ "គ្រូមុខវិជ្ជាដែលបានរៀន គឺស្របតាមការរំពឹងទុករបស់សិស្ស"និង "មានការណែនាំ និងលើកទឹកចិត្តប្រើប្រាស់សៀវភៅពុម្ពសិក្សា" ទទួលបានការយល់ស្របខ្ពស់ជាងគេ "ល្អ"(មធ្យមភាគពិន្ទុ=៣.៩៤) ហើយសូចនាករ " មាន សម្ភារៈឧបទ្ទេស ឆ្លើយតបនឹងវិធីសាស្ត្របង្រៀនទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " ល្អ"(មធ្យមភាគពិន្ទុ=៣.៥៧)។

**តារាង៤.១៦៖ ការបង្រៀនរបស់គ្រូឆ្លើយតបពីសិស្ស**

| ល.រ | ការបង្រៀនរបស់គ្រូ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | គ្រូមានវិធីសាស្ត្របង្រៀនបានល្អ | 4.06 | 0.29 | ល្អ |
| ២ | គ្រូបានពន្យល់ច្បាស់លាស់អំពីមេរៀននីមួយៗ | 4.20 | 0.44 | ល្អ |
| ៣ | គ្រូ មានចំណេះដឹងច្បាស់លាស់លើមេរៀនបង្រៀន | 4.31 | 0.47 | ល្អណាស់ |
| ៤ | ផ្តល់ពេលវេលាសមស្រប ក្នុងដំណើរការបង្រៀន | 3.99 | 0.40 | ល្អ |
| ៥ | លើកទឹកចិត្តសិស្សឱ្យចូលរួមបញ្ចេញមតិយោបល់ តាមរយៈការឆ្លើយសំណួរ ការអនុវត្ត/ការសង្កេតផ្ទាល់ និងការពិភាក្សាក្រុមជាដើម | 4.00 | 0.42 | ល្អ |
| | **សរុប** | **4.11** | **0.40** | **ល្អ** |

តារាងទិន្នន័យ៤.១៦ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី **ការបង្រៀនរបស់គ្រូ** ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត" ល្អ"(មធ្យមភាគពិន្ទុ=៤.១១)។ សូចនាករ "គ្រូ មានចំណេះដឹងច្បាស់លាស់លើមេរៀនបង្រៀន"ទទួលបានការយល់ស្របខ្ពស់ជាងគេ"ល្អណាស់"(មធ្យមភាគពិន្ទុ=៤.៣១)

ហើយសូចនាករ"ផ្តល់ពេលវេលាសមស្របក្នុងដំណើរការបង្រៀន" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត" ល្អ"(មធ្យមភាគពិន្ទុ =៤.០០)។

**តារាង៤.១៧៖ ការសិក្សារៀនសូត្រឆ្លើយតបពីសិស្ស**

| ល.រ | ការសិក្សារៀនសូត្រ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | បង្កបរិយាយឱ្យសិស្ស បានអនុវត្តផ្ទាល់លើជំនាញ | 4.07 | 0.31 | ល្អ |
| ២ | បង្កលក្ខណៈឱ្យសិស្សចេះរិះរក និងចេះបង្កើតថ្មី | 4.06 | 0.34 | ល្អ |
| ៣ | ជួយសម្រួលដល់ជំនាញដោះស្រាយបញ្ហាដល់សិស្ស លើជំនាញសិក្សា | 4.09 | 0.33 | ល្អ |
| ៤ | បានជំរុញ និងលើកទឹកចិត្តសិស្សក្នុងជំនាញវិជ្ជាជីវៈ | 4.07 | 0.43 | ល្អ |
| ៥ | បានបង្កើនភាពសហការគ្នាក្នុងដំណើរការបង្រៀន និងរៀន | 4.24 | 0.43 | ល្អណាស់ |
| ៦ | បានផ្តល់តម្លាភាពក្នុងការបង្រៀន និងលទ្ធផលសិក្សា | 4.07 | 0.35 | ល្អ |
| ៧ | មានជំនឿចិត្តខ្ពស់ ក្នុងការសិក្សាលើមុខវិជ្ជាវិជ្ជាជីវៈឯកទេស | 4.17 | 0.42 | ល្អ |
| ៨ | សិស្សមករៀនទៀងទាត់ និងគោរពវិន័យ | 4.07 | 0.55 | ល្អ |
| | **សរុប** | 4.11 | 0.39 | ល្អ |

តារាងទិន្នន័យ៤.១៧ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី **ការសិក្សារៀនសូត្រ** ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត " ល្អ"(មធ្យមភាគពិន្ទុ=៤.១១)។ សូចនាករ "បានបង្កើនភាពសហការគ្នាក្នុងដំណើរការបង្រៀន និងរៀន" ទទួលបានការយល់ស្របខ្ពស់ជាងគេ"ល្អណាស់" (មធ្យមភាគពិន្ទុ=៤.២៤) ហើយសូចនាករ "បង្កលក្ខណៈឱ្យសិស្សចេះរិះរក និងចេះបង្កើតថ្មីទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត" " ល្អ"(មធ្យមភាគពិន្ទុ=៤.០៦)។

**តារាង៤.១៨៖ សរុបរបស់សិស្ស លើការអប់រំបណ្តុះបណ្តាលបច្ចេកទេស**

| ល.រ | បរិយាយ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ក | អំពីមេរៀន | 3.84 | 0.69 | ល្អ |

| | | | | |
|---|---|---|---|---|
| ខ | ការបង្រៀនរបស់គ្រូ | 4.11 | 0.40 | ល្អ |
| គ | ការសិក្សារៀនសូត្រ | 4.11 | 0.39 | ល្អ |
| **សរុប** | | **4.02** | **0.49** | **ល្អ** |

យោងតាមតារាងទិន្នន័យ៤.១៨ បានបង្ហាញពីការយល់ឃើញរបស់សិស្ស លើការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស មានកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.០២)។ ក្នុងន័យនេះសិស្សបានចូលរួមក្នុងការរៀនសូត្រ និង ឱ្យតម្លៃពីការបង្រៀនរបស់គ្រូជំនាញបច្ចេកទេសស្របតាមចំណេះដឹង និងទទួលបានជំនាញពិត និងប្រសិទ្ធភាពតាមរយៈការសិក្សាទាំងទ្រឹស្ដី និងការអនុវត្តផ្ទាល់។ ប៉ុន្តែក្នុងនោះដែរក៏មានចំណុចមួយទាក់ទងនឹងមេរៀនដែលត្រូវសិក្សាស្វែងយល់ បន្ថែមឱ្យកាន់តែច្បាស់ ដើម្បីបង្កើនការរៀនតាមរយៈការបង្រៀនរបស់គ្រូ ឱ្យសម្រេចបានទាំងទ្រឹស្ដី និងការអនុវត្តមានប្រសិទ្ធភាព ពេលបញ្ចប់មេរៀន។

### ៤.២.៤ ទិន្នន័យឆ្លើយតបពីសហគមន៍ លើឥរិយាបថបំពេញការងាររបស់សិស្ស

ការពេញចិត្តបំពេញការងារ មានគុណភាព និងប្រសិទ្ធភាពខ្ពស់ គឺជាចំណុចនៃការចង់បានរបស់សហគមន៍ លើការប្រើប្រាស់កម្លាំងពលកម្ម ឆ្លើយតបទៅនឹងលទ្ធកម្មការងារ ក៏ដូចជាផលកម្រៃក្នុងអាជីវកម្មផងដែរ។ សមត្ថភាពជំនាញរបស់សិស្សដែលមកបំពេញការងារតាមកន្លែងណាមួយ មានភាពសកម្ម ឬអសកម្ម អាចវាស់វែងទៅបានលើកម្រិតសមត្ថភាពពិត ដែលសិស្សឬក្នុងនាមជាបុគ្គលិកនោះបានបំពេញ តាមចំណេះដឹងដែលទទួលបានពីការអប់រំបច្ចេកទេស។

**តារាង៤.១៩៖ ឆ្លើយតបពីសហគមន៍ លើឥរិយាបថបំពេញការងាររបស់អតីតសិស្សក្នុងការអប់រំបច្ចេកទេស**

| ល.រ | បរិយាយ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | អតីតសិស្សបានបំពេញការងារមានជំនាញច្បាស់លាស់ | 4.33 | 0.49 | ល្អណាស់ |
| ២ | អតីតសិស្សជាមនុស្សមានឥរិយាបថល្អ និងអាចទុកចិត្តបាន | 4.27 | 0.46 | ល្អណាស់ |
| ៣ | អតីតសិស្សបានជំរុញប្រសិទ្ធភាពការងារ ឱ្យមានការរីកចម្រើន | 4.13 | 0.35 | ល្អ |
| ៤ | អតីតសិស្សមានគំនិតច្នៃប្រឌិតខ្ពស់ លើការបំពេញការងារ | 4.20 | 0.68 | ល្អ |

| | | | | |
|---|---|---|---|---|
| ៥ | បានទទួលព័ត៌មានពីការផ្សព្វផ្សាយរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ | 4.27 | 0.46 | ល្អណាស់ |
| ៦ | បានចូលរួមកម្មវិធីប្រជុំរបស់សាលាជាមួយភាគីពាក់ព័ន្ធ | 3.93 | 0.80 | ល្អ |
| ៧ | មានទំនាក់ទំនងល្អជាមួយថ្នាក់ដឹកនាំមជ្ឈមណ្ឌលសិក្សាសហគមន៍ | 4.40 | 0.51 | ល្អណាស់ |
| ៨ | គាំទ្រផ្តល់ទីកន្លែងការងារ សម្រាប់ការចុះកម្មសិក្សារបស់សិស្ស | 4.20 | 0.41 | ល្អ |
| ៩ | ជារួម ពេញចិត្តចំពោះការបណ្តុះបណ្តាលជំនាញ របស់មជ្ឈមណ្ឌលសិក្សាសហគមន៍ | 4.53 | 0.52 | ល្អណាស់ |
| | **សរុប** | **4.25** | **0.52** | **ល្អណាស់** |

តារាងទិន្នន័យ៤.១៩ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី ការយល់ឃើញលើឥរិយាបថបំពេញការងាររបស់អតីតសិស្សបានទទួលការអប់រំបច្ចេកទេសជាមួយមជ្ឈមណ្ឌលសិក្សាសហគមន៍ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត ″ល្អណាស់″(មធ្យមភាគពិន្ទុ =៤.២៥)។ ក្នុងន័យនេះ បង្ហាញពី ការពេញចិត្តរបស់សហគមន៍ លើការងារបណ្តុះបណ្តាលជំនាញបច្ចេកទេសនៅ មសស ការទំនាក់ទំនងល្អរវាង គណៈគ្រប់គ្រង មសសជាមួយសហគមន៍ ព្រមទាំងពេញចិត្តលើការបំពេញការងាររបស់សិស្សពេលបំពេញការងារដោយច្បាស់លាស់ និងមានគុណភាពលើការងារ។ ប៉ុន្តែទន្ទឹមនឹងចំណុចពេញចិត្តខាងលើ ក៏សហគមន៍ត្រូវពង្រឹងដល់ការទំនាក់ទំនងជាមួយគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ ដើម្បីទទួលបានចំណុច ដែលត្រូវការរបស់ខ្លួន ព្រមទាំងអាចផ្តល់ផលប្រយោជន៍បំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីលើកកម្ពស់គុណភាពជំនាញសិស្ស និង ការទទួលបានគុណភាពនៃការងាររបស់សិស្ស ឬបុគ្គលិក ដែលអាចបង្កើនផលិតកម្ម និង លទ្ធផលអាជីវកម្មរបស់ខ្លួនល្អប្រសើរ។

## ៤.៣ ការពិភាក្សាពីប្រសិទ្ធភាពគ្រប់គ្រងការអប់រំបច្ចេកទេស នៅសហគមន៍ មសស

ក្រោមគោលដៅអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងការងារបណ្តុះបណ្តាលនិងវិជ្ជាជីវៈ ក៏ដូចជានាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ដែលត្រូវកសាង និងអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈការផ្តល់ជំនាញបច្ចេកទេសជាក់លាក់ ហេតុដូចនេះនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ សម្រេចដាក់ចេញនូវកម្មវិធីបណ្តុះបណ្តាល ដើម្បីបណ្តុះបណ្តាលការអប់រំបច្ចេកទេស ឱ្យក្លាយទៅជាគ្រូបច្ចេកទេស

វិជ្ជាជីវៈអាជីព។ កាតព្វកិច្ចបណ្ដុះបណ្ដាលបច្ចេកទេសនេះ គឺសំដៅឆ្លើយតបតម្រូវការទីផ្សារការងារ ដែលកំពុងត្រូវការអ្នកបច្ចេកទេសមានវិជ្ជាជីវៈជំនាញ ពិសេសដើម្បីរកចំណូលសម្រាប់គ្រួសារ និងសហគមន៍ ដែលជាការរួមចំណែកក្នុងការអភិវឌ្ឍ និងការសាងប្រទេសជាតិ និងអភិវឌ្ឍន៍ធនធានមនុស្សជាក់លាក់ ដែលប្រកបដោយសមត្ថភាពលទ្ធភាព និងគុណភាពក្នុងការស្វែងរកការងារ។ ការងារគ្រប់គ្រងការអប់រំបច្ចេកទេសគ្របដណ្ដប់លើការអប់រំជំនាញ និងមុខរបរ គឺបានជំរុញឱ្យអ្នកសិក្សាទទួលបានចំណេះដឹងជំនាញបច្ចេកទេសពិតប្រាកដ ដើម្បីក្លាយខ្លួនជា បុគ្គលិកជំនាញទាំងគុណភាពនៃជំនាញ និងប្រសិទ្ធភាពនៃការអនុវត្តការងារ ដើម្បីបំពេញតម្រូវការគ្រួសារនៃរស់នៅប្រចាំថ្ងៃ។ ដើម្បីឱ្យមានការផ្លាស់ប្ដូរនិងការកែលម្អគុណភាពនៃជំនាញដែលបណ្ដុះបណ្ដាលក្នុង មសស គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍ គឺជាកត្តាជំរុញដ៏សំខាន់ ដែលធ្វើឱ្យកម្លាំង មសស អាចឆ្លើយតបនឹងកម្រិតនៃតម្រូវការក្នុងមូលដ្ឋានដើម្បីដោះស្រាយជូនប្រជាជន និងមានការចូលរួមក្នុងសង្គមទាំង សេដ្ឋកិច្ច និងវប្បធម៌ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងសហគមន៍។ ប្រសិទ្ធភាពទាំងអស់ អាចជួយឱ្យពួកគេអាចទទួលបាននូវ ចំណេះដឹង ជំនាញ និង អកប្បកិរិយាល្អ ដែលធ្វើឱ្យពួកអាចកែស្ថានភាពគ្រួសារបានប្រសើរជាងមុន និងចូលរួមក្នុងកំណែទម្រង់ជីវភាពប្រជាជនជាមួយរាជរដ្ឋាភិបាលអាណត្តិទី៦។

**តារាង៤.២០៖ សរុបពីគណៈគ្រប់គ្រង គ្រូបង្រៀន សិស្ស និងសហគមន៍**

| ល.រ | បរិយាយ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | ទិន្នន័យសរុបពីគណៈគ្រប់គ្រង លើប្រសិទ្ធភាពនៃការគ្រប់គ្រង មសស | 3.70 | 0.70 | ល្អ |
| ២ | ទិន្នន័យសរុបពីគ្រូបង្រៀន លើប្រសិទ្ធភាពនៃការគ្រប់គ្រង មសស | 3.73 | 0.62 | ល្អ |
| ៣ | ទិន្នន័យសរុបពីលើសិស្ស លើការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស | 4.02 | 0.49 | ល្អ |
| ៤ | ទិន្នន័យសរុបពីសហគមន៍ លើឥរិយាបថបំពេញការងាររបស់អតីតសិស្ស | 4.25 | 0.52 | ល្អណាស់ |
| | **សរុប** | **3.90** | **0.60** | **ល្អ** |

តាមតារាងទិន្នន័យ៤.២០ បង្ហាញពីការឆ្លើយតបជារួមពី គណៈគ្រប់គ្រង គ្រូបង្រៀន សិស្ស និង សហគមន៍ យល់ស្របព្រមគ្នាលើការគ្រប់គ្រងមសស ដើម្បីប្រយោជន៍សហគមន៍នៅខេត្តកំពង់ស្ពឺក្នុង កម្រិត "ល្អ" សំដៅលើកកម្ពស់ការងារអប់រំបច្ចេកទេស លើជំនាញផ្សេងៗ និងមុខរបរ ជំរុញឱ្យអ្នកសិក្សា ទទួលបានចំណេះដឹង សមត្ថភាព និងតម្លៃ ដើម្បីចូលរួមជាកម្លាំងចលករមួយ ក្នុវិស័យសេដ្ឋកិច្ចជាតិ ក៏ដូច ជាកំណែទម្រង់របស់រាជរដ្ឋាភិបាល លើវិស័យអប់រំ ដូចដែលបានកំណត់នៅក្នុងមុំទី៤នៃយុទ្ធសាស្រ្ត ចតុកោណ។ ការអប់រំបច្ចេកទេស គឺចូលរួមដោះស្រាយបានមួយផ្នែកនៃពលករដែលមានជំនាញបច្ចេកទេស ត្រឹមត្រូវ និងបានចូលរួមក្នុងកម្មវិធីនៃការអប់រំពលរដ្ឋពេញលេញ ធ្វើឱ្យជីវភាពរស់នៅប្រចាំថ្ងៃក្នុងនាមជា ពលរដ្ឋថ្លៃថ្នូរ និងរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍សង្គមជាតិ និងកំណើនសេដ្ឋកិច្ចជាតិ។

ឆ្លងតាមទិន្នន័យសរុបតាមរយៈសំណាក ដែលបានពី គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្ស និង សហគមន៍បានឆ្លុះបញ្ចាំងពីកម្រិតនៃការគ្រប់គ្រងរបស់គណៈគ្រប់គ្រងទទួលបានកម្រិតល្អ តាមរយៈកម្រង សំណួរដែលមាន ៦ សូចនាករដោយផ្តោតលើការងារគ្រប់គ្រងក្នុង មសស ដើម្បីសំដៅលើចំណុចវិជ្ជមាន នៃការគ្រប់គ្រង និងចំណុចត្រូវពង្រឹងបន្ថែមដែលអាចឆ្លើយតបនឹងលទ្ធផលការងារក្នុង មសស។ ក្នុងសូចនាករ សរុបពីកម្រងសំណួររបស់សិស្សក៏បានឆ្លុះបញ្ចាំងផងដែរពីការងារបង្រៀនរបស់គ្រូ និង ការងារគ្រប់គ្រង និង ផ្គត់ផ្គង់សម្ភារសម្រាប់ថ្នាក់អប់រំបច្ចេកទេស ដែលបានបង្ហាញពីកត្តាជាច្រើន ក្នុងការគ្រប់គ្រងរបស់ គណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូអប់រំបច្ចេកទេស។ នៅក្នុងសូចនាករសរុបចុងក្រោយពីសហគមន៍ បានឆ្លុះបញ្ចាំងពីការពេញចិត្តនិងការទទួលស្គាល់កម្រិតជំនាញ និងលទ្ធផលការងាររបស់សិស្ស ក្នុងអនុវត្ត ការងាររបស់ពួកគេពេលបំពេញភារកិច្ចក្នុងនាមជា បុគ្គលិក ដែលស្តែងចេញពីលទ្ធផលនៃការងារគ្រប់គ្រង និង ប្រសិទ្ធភាពនៃការងារបង្រៀនបច្ចេកទេសរបស់គ្រូ នៅតាម មសស ។

តាមទិន្នន័យសិក្សាស្រាវជ្រាវ បង្ហាញថា លើការរៀបចំផែនការ របស់គណៈគ្រប់គ្រង មសស ដែល ទទួលបានកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.០៧) ស្តែងថាសកម្មភាពល្អដែលគណៈគ្រប់គ្រង បានរៀបចំ ផែនការ ដើម្បីអនុវត្តក្នុងដំណើរការ មសស របស់ខ្លួន។ នេះបានបញ្ជាក់ថា គណៈបានរៀបចំនូវសកម្មភាព នៃដំណើរការទាំងការគ្រប់គ្រងរដ្ឋបាលនិងការគ្រប់គ្រងថ្នាក់ជំនាញ ដែលនាំឱ្យសិស្សដែលរៀនជំនាញ

វិជ្ជាជីវៈនៅក្នុង មសស ទទួលបានទាំងគុណភាពនិងប្រសិទ្ធភាពពេលរៀនចប់។ គណៈគ្រប់គ្រង មសស ភាគច្រើនបានឆ្លងកាត់ វគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការ ដោយមន្ទីរអប់រំយុវជន និងកីឡា ដោយក្រសួងអប់រំ យុវជន និងកីឡា( នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ) ដែលតែងតែជួយពង្រឹងសមត្ថភាព គណៈគ្រប់គ្រងឱ្យមានភាពច្បាស់លាស់ នឹងការធ្វើផែនការ សម្រាប់ដំណើរការ មសស ដោយផ្តោតលើអ្វីដែលជាប្រយោជន៍ សម្រាប់សិស្សជំនាញ ពេលបញ្ចប់ជំនាញនីមួយៗ និងសម្រាប់សហគមន៍ទាំងមូល។

ជារួមប្រសិទ្ធភាពនៃការគ្រប់គ្រង គឺមានសារៈសំខាន់ណាស់ដែលសំដៅជួយឱ្យ មសស អាចសម្រេចសមិទ្ធផល ឬស្នាដៃ និងការទទួលបាននូវ អ្វីដែលប្រជាពលរដ្ឋក្នុងសហគមន៍ចង់បាន។

ដោយឡែក តាមទិន្នន័យសិក្សាស្រាវជ្រាវ បង្ហាញថាផ្នែកភាគីពាក់ព័ន្ធ និង ធនធានរូបវន្ត នៅពុំទាន់មានការចូលរួមពីភាគីពាក់ព័ន្ធក្នុងការជួយដល់ដំណើរការ មសស (មធ្យមភាគពិន្ទុ=៣.៤១)។ នេះបញ្ជាក់ឱ្យឃើញពីសហគមន៍មិនទាន់គិតថា មសស ជារបស់សហគមន៍ ដើម្បីប្រយោជន៍សហគមន៍រួមនៅឡើយ។ បើទៅសូចនាករដែល មានកម្រិតពិន្ទុដូចគ្នានេះដែរគឺពាក់ព័ន្ធនឹង ធនជានរូបវន្តនៅតែមិនទាន់ឆ្លើយតប និងតម្រូវការសម្រាប់អ្នកសិក្សាជំនាញវិជ្ជាជីវៈក៏ដូចជាការបង្រៀនរបស់គ្រូជំនាញដែរ។ នៅក្នុងសូចនាករទាំងពីរខាងលើគឺបង្ហាញពី មសស ដែលដំណើរការហើយ នៅពុំទាន់មាននូវធនជានរូបវន្តគ្រប់គ្រាន់ និងការចូលរួមពីភាគីពាក់ព័ន្ធសម្រាប់ជួយដល់ មសស ជាប្រយោជន៍ដល់សហគមន៍នៅមានកម្រិត។ កង្វះធនជានមនុស្ស ដែលនឹងត្រូវបានអប់រំ និង បណ្តុះបណ្តាល ឱ្យចំជំនាញដែលត្រូវជាមួយនិងការងាររបស់ពួកគេ ដែលបានមកពីការ វិនិយោគផ្ទាល់ពីបរទេស (FDI) ដែលក្នុងនោះបានអនុញ្ញាតឱ្យជំនាញការនិងកម្មករជំនាញមកពីបរទេសមកធ្វើការនៅក្នុងប្រទេសកម្ពុជានៅក្នុងផ្នែកផ្សេងៗមួយចំនួន ហើយពលរដ្ឋកម្ពុជាមិនអាចប្រកួតប្រជែងជាមួយពួកគេបានទេ ដោយសារកម្មករគ្មានជំនាញមានចំនួនច្រើន (Kate 2013)។

តំណាងសហគមន៍ មសស បានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងទៅលើអតុល្យភាពនៃការផ្គត់ផ្គង់ជំនាញដែលទាក់ទងនឹងកង្វះខាតនៃអ្នកដែលបញ្ចប់ការសិក្សានៅសាលាបណ្តុះបណ្តាលអប់រំបច្ចេកទេស បើប្រៀបធៀបនឹងអ្នកបញ្ចប់ការសិក្សានៅឧត្តមសិក្សា។ ក្នុងន័យនេះ ការងារគ្រប់គ្រង មសស តែងតែជួបប្រទះនូវបញ្ហាប្រឈមនានា ដែលក្នុងអាចជាបញ្ហាប្រឈមទៅលើ បច្ចេកទេស ការចូលរួមរបស់សហគមន៍

និងតម្រូវការកម្លាំងពលកម្មដែល ផលិតដោយ មសស ឆ្លើយតបតម្រូវការការងារប្រទេសពីសំណាក់អ្នកវិនិយោគទុន។ តាមទិន្នន័យដែលទទួលបានពី គ្រូ ពីគណៈគ្រប់គ្រង ពីសិស្ស ពីសហគមន៍ ឆ្លុះបញ្ចាំងឱ្យឃើញថា ការគ្រប់គ្រង មសស នៅកំពង់ស្ពឺមាន ចំណុចវិជ្ជមានទាក់ទងទៅនឹងធនធានមនុស្សដោយផ្តោតទាំង ការដឹកនាំ គ្រូបង្រៀន និង បុគ្គលិកគាំទ្រសេវា។ ដោយឡែកកត្តាធនធានគឺជាចំណុចសំខាន់ ដែលគាំទ្រដល់ការបណ្តុះបណ្តាល អប់រំបច្ចេកទេស និងដំណើរការប្រព្រឹត្តទៅប្រចាំថ្ងៃរបស់ មសស ។ ក្នុងន័យនេះធនធានពុំគ្រប់គ្រាន់ បានធ្វើឱ្យប៉ះពាល់ទាំងគុណភាព ចំណេះដឹង ជំនាញ របស់សិស្សានុសិស្ស ដែលទទួលការអប់រំបច្ចេកទេស។ នៅក្នុងស្ថានភាពបែបនេះអាចធ្វើឱ្យ មសស ដែលបណ្តុះបណ្តាលជំនាញដល់សហគមន៍ ទាំងមូលមិនអាចទទួល បានលទ្ធផលបានល្អ និងមានគុណភាពគ្រប់គ្រាន់តាមតម្រូវការទីផ្សារការងារ ដែលរាជរដ្ឋាភិបាលបានកំណត់ទុក។ ទោះជាយ៉ាងនេះក្តី ដោយមើលទៅលើកម្មករគ្មានជំនាញថាជាបញ្ហាចម្បង ដែលត្រូវគិតគូរជាមួយនិងការចូលរៀននៅក្នុងសាលាក្រៅប្រព័ន្ធ មិនទាន់គ្រប់គ្រាន់នៅឡើយ រដ្ឋាភិបាលបានផ្តួចផ្តើមឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអង្គការក្រៅរដ្ឋាភិបាលដើម្បីធ្វើការសម្របសម្រួលក្នុងការរៀបចំនិងលើកកម្ពស់កម្មករជំនាញតាមរយៈការផ្តល់ ឱ្យនូវការបណ្តុះបណ្តាលជំនាញផ្សេងៗ រួមមាន កុំព្យូទ័រ, ភាសាអង់គ្លេស ជំនាញកាត់ដេរសម្លៀកបំពាក់ ជំនាញធ្វើម្ហូបនិងនំ ជំនាញកាត់សក់ និងតុបតែង សិល្បៈតម្បាញ ការរៀបចំដាំបន្លែ ចិញ្ចឹមសត្វឬត្រី ការជួសជុលកង់, អគ្គិសនី, ម៉ាស៊ីនត្រជាក់, ទូរស័ព្ទចល័តនិងការជួសជុលទូរទឹកកក, គ្រឿងម៉ាស៊ីនរថយន្ត, សិល្បៈគំនូរ ជំនាញជាងឈើនិងគ្រឿងសង្ហារឹមជាដើម ( Lay, Chhum et al. 2013 )។

ក្នុងរបាយការណ៍ថវិកាកម្មវិធីការិយាល័យអប់រំក្រៅប្រព័ន្ធប្រចាំឆ្នាំ មានការថយចុះពីមួយឆ្នាំលើការផ្គត់ផ្គង់សម្ភារទៅតាម មសស ដែលកំពុងដំណើរការ។ ផ្នែកមួយទៀតដែលជាកត្តាធ្វើឱ្យ មសស ពុំមានធនធានសម្ភារគ្រប់គ្រាន់ និងចំនួនសិស្សចូលរៀនមានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ។ តាមការវិភាគលើទិន្នន័យ ដែលទទួលបានពីការសិក្សាស្រាវជ្រាវ មសស ខេត្តកំពង់ស្ពឺ មានកិច្ចដំណើរការ បានល្អដោយមានគណៈគ្រប់គ្រងដែលមានផែនការច្បាស់លាស់ពេលធ្វើសកម្មភាពបើកថ្នាក់ជំនាញវិជ្ជាជីវៈ ដែលគណៈគ្រប់គ្រងនីមួយៗ ធ្វើផែនការ និង បានឆ្លងការអនុវត្តនេះទៅដល់ថ្នាក់ខេត្តមុននិងបើកដំណើរការ

ថ្នាក់ជំនាញ។ ប៉ុន្តែទោះជាមានផែនការច្បាស់លាស់ ទាំងផែនការសកម្មភាព និង ថវិកាក៏ដោយ ក៏មិនអាចបំពេញតម្រូវការបានទាំងស្រុងដល់សហគមន៍បានដែរ ដោយផ្នែកធនធានសម្ភារ និង ធនធានថវិកាពុំទាន់គ្រប់គ្រាន់សម្រាប់បំពេញតម្រូវការតាម មសស បាននៅឡើយ។

ឆ្លើយតបទៅនឹងចំណោទបញ្ហានានា ដំណោះស្រាយដើម្បីផ្តល់កិច្ចគាំទ្រលើដំណើរការគ្រប់គ្រង មសស នៅខេត្តកំពង់ស្ពឺ គឺគួរបង្កើតគោលនយោបាយ និងគោលបំណងនៃកម្មវិធីអប់រំក្រៅប្រព័ន្ធដោយផ្អែកលើតម្រូវការនៃកម្មករគ្មានជំនាញ និងតំរូវការទីផ្សារការងារ ដើម្បីធានាបាននូវការរួមចំណែករបស់កម្មករជំនាញនៅក្នុងសង្គមអោយកាន់តែល្អ និងទទួលបាននូវលទ្ធផលល្អប្រសើរពីការបណ្តុះបណ្តាលការអប់រំក្រៅប្រព័ន្ធ សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជា។ ផ្តល់អោយនូវកម្មវិធីសិក្សាដែលអាចបត់បែនបានជាមួយវេលា មាតិកា និងទីកន្លែងដែលត្រូវរៀន ដើម្បីផ្តល់ភាពងាយស្រួលចំពោះការអប់រំក្រៅប្រព័ន្ធ សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈដល់សិស្ស ឬកម្មករដែលគ្មានជំនាញនៅក្នុងប្រទេសកម្ពុជា ដូច្នេះសិស្ស ឬកម្មករដែលគ្មានជំនាញទាំងប្រុសទាំងស្រី ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ អាស្រ័យទៅតាមពេលវេលាទំនេរនិងការលំបាករបស់ពួកគេ។

## ៤.៤. បញ្ហាប្រឈមក្នុងការគ្រប់គ្រង មសស នៅសហគមន៍ខេត្តកំពង់ស្ពឺ

### ៤.៤.១ ទិន្នន័យពីការឆ្លើយតបរបស់គណៈគ្រប់គ្រង

**តារាង៤.២១៖ ដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រង**

| ល.រ | បរិយាយ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | ទទួលបាន ចំនួនសិស្សចុះឈ្មោះចូលរៀនច្រើន | 3.80 | 0.68 | ល្អ |
| ២ | មានគ្រូគ្រប់គ្រាន់ ទៅតាមឯកទេសបណ្តុះបណ្តាល | 3.69 | 0.93 | ល្អ |
| ៣ | ប្រព័ន្ធហិរញ្ញវត្ថុមជ្ឈមណ្ឌលសិក្សាសហគមន៍មានកិច្ចគាំទ្ររឹងមាំ | 3.29 | 0.86 | មធ្យម |
| ៤ | មជ្ឈមណ្ឌលសិក្សាសហគមន៍មានធនធានរូបវន្តគ្រប់គ្រាន់ លើការងារបណ្តុះបណ្តាល | 3.29 | 0.83 | មធ្យម |
| ៥ | មានភាពច្បាស់លាស់ លើរបាយម៉ោងមុខវិជ្ជានីមួយៗ ស្របតាមកម្មវិធីសិក្សា | 3.97 | 0.71 | ល្អ |

| | | | | |
|---|---|---|---|---|
| ៦ | គ្រូបង្រៀនបានបំពេញការងារដោយពេញចិត្ត | 4.09 | 0.45 | ល្អ |
| ៧ | បានអនុវត្តប្រព័ន្ធធានាគុណភាពការអប់រំបច្ចេកទេសទៅតាមគោលការណ៍ | 3.97 | 0.38 | ល្អ |
| ៨ | ការផ្សារភ្ជាប់រវាងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងទីផ្សារការងារនៅមានកម្រិត | 3.91 | 0.45 | ល្អ |
| ៩ | មានការចូលរួម ការផ្តល់តម្លៃខ្ពស់ពីភាគីពាក់ព័ន្ធ និងសហគមន៍ | 3.74 | 0.70 | ល្អ |
| ១០ | បានពង្រឹងការផ្សព្វផ្សាយពីគោលនយោបាយអប់រំបច្ចេកទេស | 3.89 | 0.58 | ល្អ |
| ១១ | បានអនុវត្តការងារ ទៅតាមតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវ | 4.09 | 0.51 | ល្អ |
| | **សរុប** | **3.79** | **0.34** | **ល្អ** |

តារាងទិន្នន័យ៤.២១ បានបង្ហាញពីមធ្យមភាគសរុប ដែលបង្ហាញពី ដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រង គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៧៩)។ ក្នុងន័យនេះគឺគ្រូបង្រៀនបច្ចេកទេសពេញចិត្តនឹងការងារបង្រៀនរបស់ខ្លួនស្របតាមកម្មវិធីដែលបានកំណត់ និងគណៈគ្រប់គ្រងបានអនុវត្តការងារប្រចាំថ្ងៃ ទៅតាមតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវ សម្រាប់ការងារបណ្តុះបណ្តាលសិស្សជំនាញបច្ចេកទេសដែលអាចបង្កើនប្រសិទ្ធភាពនៃការបង្រៀន និងដឹកនាំដំណើរការនៅ មសស បានល្អប្រសើរ។ កម្មករដែលគ្មានជំនាញទាំងអស់ ជាពិសេសអ្នកដែលផ្លាស់ទៅទីក្រុងដើម្បីរកប្រាក់ចិញ្ចឹមជីវិត និងអ្នកដែលមានអាយុចាប់ពី ១៨ ឆ្នាំដល់ ៤៥ ឆ្នាំគួរតែត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងការអប់រំក្រៅប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ ព្រោះពួកគេគឺជាអ្នកដែលចូលរួមសកម្មនៅគ្រប់វិស័យផលិតកម្ម សំណង់ និងផ្នែកផ្តល់សេវាកម្ម។ ទោះជាមានការពេញចិត្តនឹងការងារបង្រៀនរបស់លោកគ្រូ អ្នកគ្រូ និងការអនុវត្តតាមតួនាទី ភារកិច្ចរបស់គណៈគ្រប់គ្រងយ៉ាងណាក៏ដោយ ប្រព័ន្ធគាំទ្រហិរញ្ញវត្ថុក៏ត្រូវតែផ្តល់តាមលក្ខខណ្ឌ និងតាមតម្រូវការចាំបាច់របស់ មសស តាមរយៈផែនការ មសស ដែលបានកំណត់ ដើម្បីលើកកម្ពស់ភាពស័ក្តិសិទ្ធិ នៃការងារបង្រៀន និងរៀន ព្រមទាំងប្រសិទ្ធភាពក្នុងការដឹកនាំ និងគ្រប់គ្រង មសស ឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ក្នុងចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច

គ្រួសារ និង សង្គមជាតិ។

## ៤.៤.២.ទិន្នន័យពីការឆ្លើយតបរបស់លោកគ្រូ អ្នកគ្រូបង្រៀនបច្ចេកទេស

**តារាង៤.២២៖ ពីការយល់ឃើញរបស់គ្រូបង្រៀនចំពោះការងារគ្រប់គ្រង**

| ល.រ | បរិយាយ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | ទទួលបាន ចំនួនសិស្សចុះឈ្មោះចូលរៀនច្រើន | 3.94 | 0.77 | ល្អ |
| ២ | មានគ្រូគ្រប់គ្រាន់ ទៅតាមឯកទេសបណ្តុះបណ្តាល | 3.90 | 0.75 | ល្អ |
| ៣ | ប្រព័ន្ធហិរញ្ញវត្ថុមជ្ឈមណ្ឌលសិក្សាសហគមន៍ មានកិច្ចគាំទ្ររឹងមាំ | 3.48 | 0.72 | ល្អ |
| ៤ | សាលារៀនមានធនធានរូបវន្តគ្រប់គ្រាន់ លើការងារបណ្តុះបណ្តាល | 3.29 | 0.74 | មធ្យម |
| ៥ | មានភាពច្បាស់លាស់ លើរបាយម៉ោងមុខវិជ្ជានីមួយៗ ស្របតាមកម្មវិធីសិក្សា | 4.03 | 0.75 | ល្អ |
| ៦ | គ្រូបង្រៀន បានបំពេញការងារដោយពេញចិត្ត | 4.26 | 0.44 | ល្អណាស់ |
| ៧ | បានអនុវត្ត ប្រព័ន្ធធានាគុណភាពការអប់រំបច្ចេកទេសទៅតាមគោលការណ៍ | 3.97 | 0.55 | ល្អ |
| ៨ | ការផ្សារភ្ជាប់រវាងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងទីផ្សារការងារនៅមានកម្រិត | 3.77 | 0.72 | ល្អ |
| ៩ | មានការចូលរួម ការផ្តល់តម្លៃខ្ពស់ពីភាគីពាក់ព័ន្ធ និងសហគមន៍ | 3.71 | 0.74 | ល្អ |
| ១០ | បានពង្រឹងការផ្សព្វផ្សាយពីគោលនយោបាយអប់រំបច្ចេកទេស | 3.94 | 0.57 | ល្អ |
| ១១ | បានអនុវត្តការងារ ទៅតាមចំពោះតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវ | 4.23 | 0.43 | ល្អណាស់ |
| | **សរុប** | **3.87** | **0.65** | **ល្អ** |

តារាងទិន្នន័យ៤.២២ បានបង្ហាញពីមធ្យមភាគសរុប ការយល់ឃើញរបស់គ្រូបង្រៀន លើដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រង ក្នុងខេត្តកំពង់ស្ពឺ គឺទទួលបានការយល់ស្របក្នុងកម្រិត ″ ល្អ″( មធ្យមភាគពិន្ទុ=៣.៨៧ )។ ក្នុងន័យនេះបញ្ជាក់ពីការពេញចិត្តរបស់លោកគ្រូ អ្នកគ្រូបង្រៀនក្នុងការបំពេញការងារ

របស់ខ្លួន ដែលអាចឆ្លើយតបនឹងតម្រូវការអ្នកសិក្សា និងទទួលបាននូវលទ្ធផលសិក្សាមួយដ៏ជាក់លាក់ ដែលអាចជំរុញឱ្យការបណ្តុះបណ្តាលជំនាញបច្ចេកទេស មានគុណភាព និងប្រសិទ្ធភាពពេលសិស្សបញ្ចប់ការសិក្សា។ ចំណែកឯការផ្គត់ផ្គង់លើសម្ភារូបវន្តក្នុងការបណ្តុះបណ្តាល ក៏ត្រូវតែផ្តល់ឱ្យបានទាន់ពេល និងតាមតម្រូវការប្រើប្រាស់សម្រាប់បណ្តុះបណ្តាល ដើម្បីស្របតាមនិយាមបច្ចេកទេសជំនាញនីមួយៗ និងសំដៅលើកកម្ពស់គុណភាពនៃការអប់រំបច្ចេកទេស នឹងអាចសម្រេចតាមផែនការនៃការងាររបស់ មសស និងដើម្បីធានាភាពស័ក្តិសិទ្ធិនៃការគ្រប់គ្រង ស្របនូវអ្វីដែលក្រសួងអប់រំ យុវជន និងកីឡាកំពុងធ្វើកំណែទម្រង់។

### ៤.៤.៣ ទិន្នន័យគុណវិស័យពីសហគមន៍ និង ពីសិស្ស

ការជំរុញកិច្ចការបណ្តុះបណ្តាលជំនាញអប់រំបច្ចេកទេស តម្រូវឱ្យមានកិច្ចសហប្រតិបត្តិការរវាងអ្នករៀបចំការអប់រំក្រៅប្រព័ន្ធ ជាមួយក្រុមហ៊ុនរដ្ឋ និងឯកជនដែលពាក់ព័ន្ធ ដើម្បីរៀបចំសកម្មភាពរៀនជាមួយនឹងការអនុវត្តជាក់ស្តែង ព្រមទាំងបទពិសោធន៍ ដែលនិងផ្តល់ជូនទាំងអ្នកដែលមាននិងគ្មានការងារធ្វើ។ ការរៀនសូត្រផ្អែកលើសហគមន៍(CBL) ដោយបញ្ចូលកម្មករដែលគ្មានជំនាញដើម្បីរៀនពីរបៀបប្រើប្រាស់ធនធានធម្មជាតិដែលមានស្រាប់នៅក្នុងភូមិដើម្បីដូច្នេះពួកគេអាចរកប្រាក់ចំណូលបានច្រើនជាងមុនតាមរយៈការផលិតនូវផលិតផលផ្សេងៗ ដែលធ្វើពីធនធានធម្មជាតិនៅក្នុងភូមិ ឬសហគមន៍។ នៅក្នុងសកម្មភាពរៀន ដែលផ្សារភ្ជាប់ទៅនឹងការវាយតម្លៃតម្រូវការរៀន ដោយរៀបចំប្រព័ន្ធផែនការសកម្មភាព ដោយផ្តោតលើការរៀនជាក្រុម ដែលអ្នកសិក្សាអាចមានលទ្ធភាពរៀននិងចូលរួមនៅក្នុងសកម្មភាពរៀនជាមួយគ្នាដូច្នេះពួកគេថែមទាំងអាចរៀនពីរបៀបនៃការរៀន រស់នៅនិងធ្វើការជាមួយគ្នានៅក្នុងសង្គម។ មួយវិញទៀតសកម្មភាពទាំងនេះ និងបើកឱកាសដល់កម្មករដែលគ្មានជំនាញ ដើម្បីពិភាក្សានិងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ដែលពួកគេជួបប្រទះទាំងក្នុងការរស់នៅនិងការងារ ដូច្នេះពួកគេអាចពង្រីកដែនសិក្សារបស់ពួកគេបានយ៉ាងច្រើន។ សកម្មភាពគ្រប់គ្រងនៃការរៀនដោយយកចិត្តទុកដាក់ លើការលើកកម្ពស់ការរៀនសូត្រ សម្រាប់គុណភាពនៃការរស់នៅអោយបានប្រសើរជាងមុន រួមទាំងការបង្កើនប្រាក់ចំណូលអោយកាន់តែច្រើន សុខភាពរាងកាយនិងផ្លូវចិត្តអោយកាន់តែប្រសើរ ក៏ដូចជាការយល់ដឹងពីរបៀបរស់នៅជាមួយគ្នានៅក្នុងសង្គមប្រកបដោយនិរន្តរភាព ជាអ្នកសិក្សាពេញមួយជីវិត។

ក្នុងអំឡុងពេលបិទសាលារៀនដោយសារការកើតមានជំងឺកូវីដ ការអប់រំបច្ចេកទេស បានចាប់ផ្ដើមបង្រៀន និងដឹកនាំសិស្សជាបណ្ដុំតូចៗ ឬ រៀនតាមអនឡាញ។ មានបញ្ហាជាច្រើន ក្នុងការបង្រៀនសិស្សលើការអប់រំបច្ចេកទេស ដែលក្នុងនោះគ្រូបង្រៀនភាគច្រើនបានលើកឡើងថា៖ "ការអប់រំបច្ចេកទេសគឺទាមទារការអនុវត្តផ្សារភ្ជាប់ទ្រឹស្តី ឲ្យសិស្សយកចិត្តទុកដាក់ខ្លាំងពេលអនុវត្ត ជាពិសេសត្រូវស្ដាប់គ្រូពន្យល់ឲ្យបានច្បាស់ពេលគ្រូបង្ហាញលើការអនុវត្តជាក់ស្ដែង"។ នៅក្នុងយោបល់បន្ថែមពេលចុះប្រមូលទិន្នន័យ គ្រូបង្រៀនបានបញ្ជាក់ថា៖ "បើសិនជាសិស្សដែលបានអនុវត្តវាអត់បញ្ហាទេ ព្រោះអាចសង្កេតបាន តែសម្រាប់ការសិក្សាតាមអនឡាញគឺពិបាកហើយ ព្រោះអីសិស្សមិនអាចអនុវត្តផ្ទាល់បាន គឺបានតែមើលវីដេអូពីការអនុវត្តតែប៉ុណ្ណោះលើជំនាញមួយចំនួន បើបានអនុវត្តផ្ទាល់វិញល្អជាងយើងអាចពន្យល់បានច្រើន។

សិស្សអាចចូលរួមក្នុងដំណើរការនៃការបណ្ដុះបណ្ដាលការអប់រំបច្ចេកទេសនៅ មសស ទៅបានយ៉ាងហោចណាស់ក៏ត្រូវចប់ថ្នាក់អក្ខរកម្ម ដោយស្មើថ្នាក់ទី៤ នៅកម្រិតបឋមសិក្សា។ ភាគច្រើនការបណ្ដុះបណ្ដាលវិជ្ជាជីវៈ មានរយៈពេលខ្លីចន្លោះ ពី២ខែ ទៅ ៣ខែ លើវគ្គជំនាញកាត់ដេរ, ជាងម៉ាស៊ីនគោយន្ត, ជាងផាត់មុខជាដើម។ ជាទូទៅ ទិន្នន័យដែលទទួលបានពីការសម្ភាសន៍ជាមួយសិស្សភាគច្រើន បានលើកឡើងថា៖

"វគ្គបណ្ដុះបណ្ដាល គួរមានរយៈពេល ៦ខែ ព្រោះដំណើរការនៃការសិក្សាគឺទាំងទ្រឹស្តី និងការអនុវត្តជំនាញព្រមជាមួយគ្នា។ រយៈពេល៦ខែ អាចអោយសិស្សមានចំណេះដឹង លើជំនាញច្បាស់ លាស់ និងអាចយកជំនាញទៅរកការងារធ្វើមានភាពងាយស្រួល"

(សិស្ស មសស-៤៥)

"ស្នើសុំ គ្រូបង្រៀនមានបទពិសោធន៍ច្បាស់លាស់លើជំនាញមកបង្រៀន និងការបណ្ដុះបណ្ដាលគួរមានរយៈពេលវែង ស្នើសុំបំពាក់សម្ភារៈឱ្យបានគ្រប់គ្រាន់ និងមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាដើម្បីអាចយក ទៅរកការងារធ្វើមានភាពងាយស្រួល"

(សិស្ស មសស-១៨)

"បង្កើនកិច្ចសហប្រតិបត្តិការបន្ថែមទៀតចំពោះម្ចាស់ជំនួយឬអង្គការដែលពាក់ព័ន្ធទាំងក្នុងស្រុក និងក្រៅស្រុក ដើម្បីជួយក្នុងការគាំទ្រថវិកាបន្ថែមទៀត ដើម្បីដំណើរការកម្មវិធីបណ្ដុះបណ្ដាលជំនាញ

ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមួយនឹងសម្ភារៈសិក្សាគ្រប់គ្រាន់កម្មវិធីបណ្តុះបណ្តា គ្រូ និង បរិក្ខារចាំបាច់ក៏ដូចជាបរិយាកាសល្អប្រសើរ ដើម្បីធានាអោយបាននូវប្រសិទ្ធភាពនៃការរៀបចំកម្មវិធី"

(សហគមន៍ មសស-១២)

"ពេលរៀន សិស្សបានឆ្លងកាត់វគ្គបណ្តុះបណ្តាលខ្លីពេក ការអនុវត្តលើជំនាញបានតិច នាំឱ្យមាន ការលំបាកមួយចំនួន ក្នុងពេលចេញមកបំពេញការងារជាក់ស្តែង"

(សហគមន៍ មសស-៩)

"ការធ្វើបច្ចុប្បន្នភាពលើសម្ភារៈសម្រាប់បណ្តុះបណ្តាលនៅ មសស មិនទាន់ឆ្លើយតបទៅឧបករណ៍ នៅកន្លែងអាជីវកម្ម ឬនៅហាងសិប្បកម្មនានា។ បុគ្គលិកដែលជាសិស្ស ចេញពី មសស ត្រូវចំណាយ ពេល ដើម្បីរៀនសូត្រលើការប្រើប្រាស់សម្ភារៈ ឬឧបករណ៍ទាំងនោះមួយរយៈពេលខ្លីទៀត"

(សហគមន៍ មសស-១១)

"ក្នុងពេលធ្វើការ គាត់មិនសូវយល់ពីរបៀបធ្វើការងារជាក្រុម ឬសមូហភាពនោះទេ គិតប្រយោជន៍ បុគ្គលច្រើនជាង។ គាត់ភាគច្រើនប្រចាំការងារគ្នា ពុំសូវមានចិត្តអំណត់ ឧស្សាហ៍ព្យាយាមនឹងការ ធ្វើការងារនោះទេ"

(សហគមន៍ មសស-៩)

ក្នុងទិន្នន័យគុណវិស័យដែលទទួលបាន ពីកម្រងសំណួរសិស្ស និងសហគមន៍ក៏បានស្នើសុំលើ ការ ជ្រើសរើស មុខវិជ្ជាសម្រាប់បណ្តុះបណ្តាល ត្រូវតែសមស្របទៅតាមតម្រូវការសិស្សជាក់លាក់រួមមាន៖ ពេលវេលា ទីកន្លែង មុខវិជ្ជាសិក្សា មាតិកា បរិយាកាសរៀននិងបង្រៀន ក៏ដូចជាសម្ភារៈសិក្សា គួរតែត្រូវ បានរៀបចំជាមួយនឹងភាពបត់បែននៃតម្រូវការរបស់កម្មករគ្មានជំនាញ។ ដើម្បីសម្រេចបានកម្រោងនេះ អ្នករៀបចំការអប់រំក្រៅប្រព័ន្ធ គួរតែសង្កត់ធ្ងន់ទៅលើម៉ោងទំនេរនិងវគ្គសិក្សារបស់កម្មករដែលគ្មានជំនាញ ព្រោះថាជាធម្មតា ពួកគេអាចចូលរួមមិនលើសពី ២ម៉ោង ក្នុងមួយសប្តាហ៍ជាមួយនឹងវគ្គសិក្សានៅចុង សប្តាហ៍។ នៅក្នុងថ្នាក់នីមួយៗគួរតែមានសៀវភៅសិក្សាគ្រប់គ្រាន់។ ម៉្យាងវិញទៀត ដោយសារអ្នកសិក្សាភាគ ច្រើនមានទំនោរចូលចិត្តការរៀនជាមួយគ្រូ ឬអ្នកសម្របសម្រួល គ្រូត្រូវយកចិត្តទុកដាក់បន្ថែមលើអ្វីដែល

ខ្លួនកំពុងបង្រៀនហើយអាចកត់សំគាល់នូវវឌ្ឍនភាពរបស់អ្នកសិក្សាម្នាក់ៗនៅក្នុងថ្នាក់ ដូច្នេះពួកគេអាចបង្កើតនូវទំនាក់ទំនងសកម្មជាមួយអ្នកសិក្សាទាំងអស់ដែលមកពីមជ្ឈដ្ឋានផ្សេងៗគ្នា។

## ៤.៥ ការពិភាក្សាពីបញ្ហាប្រឈមក្នុងការគ្រប់គ្រង មសស នៅសហគមន៍ខេត្តកំពង់ស្ពឺ

មសស មួយដំណើរការទៅបានដោយមានគ្រប់គ្រងពីគណៈគ្រប់គ្រង និងមានការចូលរួមសហការពីគ្រប់សមាជិកទាំងអស់ក្នុងអនុវត្តការងាររបស់ខ្លួនជាប្រចាំទាំងការបង្រៀនបច្ចេកទេស ការប្រមូល ព័ត៌មានទូទៅពាក់ព័ន្ធនឹង មសស ព្រមទាំងលទ្ធផលនៃការសិក្សារបស់សិស្ស ។ ការងារគ្រប់គ្រងដើរតួនាទីសំខាន់ក្នុងការងារបណ្តុះបណ្តាលនិងមានការគាំទ្រទាំងសម្ភារ និងថវិកាពីថ្នាក់ជាតិ ព្រមទាំងដៃគូ អភិវឌ្ឍន៍នានាដែលគាំទ្រនូវការងារ មសស ក្នុងគោលបំណងដើម្បីបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់សហគមន៍ជំនាញវិជ្ជាជីវៈមួយដែលមានគុណភាព និង ឆ្លើយតបនិងតម្រូវការទីផ្សារការងារ និងចូលរួមកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍ និងចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសតាមរយៈពាក្យស្លោកមួយ "យុវជនម្នាក់ ត្រូវមានជំនាញមួយ"។

បញ្ហាប្រឈមលើកិច្ចការងារគ្រប់គ្រង មសស នៅសហគមន៍ខេត្តកំពង់ស្ពឺ គឺការបង្កើនសមធម៌ក្នុងការចូលរៀន។ គុណភាពរបស់សិស្សបញ្ចប់ថ្នាក់អក្ខរកម្មទី៤ ត្រូវលើកកម្ពស់និងផ្តល់នូវចំណេះដឹងពាក់ព័ន្ធដទៃទៀតសម្រាប់ការអប់រំបច្ចេកទេសវិជ្ជាជីវៈ។ មសស នៅសហគមន៍ខេត្តកំពង់ស្ពឺ ជាពិសេសនៅតំបន់ជនបទខ្វះខាតធាតុចូលដូចជា៖ គ្រូបង្រៀនតាមឯកទេស សម្ភារៈបង្រៀននិងគ្រឿងបរិក្ខារ សៀវភៅសិក្សាគោល បន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ ភាសា និងបរិក្ខារបណ្ណាល័យជាដើម។ វិធីសាស្ត្របង្រៀនក្នុងពេលបច្ចុប្បន្ន អនុវត្តតាមរបៀបអនឡាញ សិស្សចម្លងតាម ដកស្រង់ និងការចងចាំជាដើម។ វិធីសាស្ត្រទាំងនេះគួរត្រូវបញ្ចូលនូវការគិត និងជំនាញវិភាគ(soft skills)។ ស្តង់ដារគ្រូបង្រៀនអប់រំបច្ចេកទេស គួរត្រូវពិនិត្យតាមដាន វាយតម្លៃ និងអភិវឌ្ឍន៍ជាប្រចាំ។ ការអប់រំបច្ចេកទេសជាកិច្ចការងារមួយដែលត្រូវផ្តល់ការយកចិត្តទុកដាក់ខ្ពស់ ទន្ទឹមពេលដែលគោលនយោបាយស្តីពីការអប់រំបច្ចេកទេស បានទទួលអនុម័តឱ្យប្រើប្រាស់ក្នុងខែកុម្ភៈ ឆ្នាំ២០១៣។ នាពេលបច្ចុប្បន្ន សាលាមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេសចំនួនពីរកំពុងដំណើរការ និងផ្តល់នូវមុខវិជ្ជាសំខាន់បួន។ សិស្សដែលបញ្ចប់ការសិក្សានៅសាលាទាំងនេះ

អាចរកការងារបាន។ កម្មវិធីអប់រំបច្ចេកទេស ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន មានកង្វះខាតទាំងក្រប ខណ្ឌគុណភាព និងធាតុចូលមួយចំនួនដែលត្រូវឱ្យមានគុណភាព។ ការងារអប់រំបច្ចេកទេស គួរត្រូវដកបទ ពិសោធន៍បន្ថែមពីប្រទេសក្នុងតំបន់ ឬជិតខាង និងដៃគូអភិវឌ្ឍន៍នានា សំដៅគាំទ្រដល់កម្មវិធីអប់រំ បច្ចេកទេស។

**តារាង៤.២៣៖ សរុបពីគណៈគ្រប់គ្រង គ្រូបង្រៀន បំពេញការងារលើដំណើរការប្រតិបត្តិ**

| ល.រ | បរិយាយ | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|
| ១ | ទិន្នន័យសរុបពីគណៈគ្រប់គ្រង លើប្រសិទ្ធភាពនៃការគ្រប់គ្រង មសស | 3.79 | 0.34 | ល្អ |
| ២ | ទិន្នន័យសរុបពីគ្រូបង្រៀន លើប្រសិទ្ធភាពនៃការគ្រប់គ្រង មសស | 3.87 | 0.65 | ល្អ |
| **សរុប** | | **3.83** | **0.50** | **ល្អ** |

តារាងទិន្នន័យ៤.២៤ បានបង្ហាញពីមធ្យមភាគសរុបលើការងារគ្រប់គ្រងពីគណៈគ្រប់គ្រងនិង លោកគ្រូ អ្នកគ្រូ ក្នុងដំណើរការ គ្រប់គ្រង និងការបង្រៀនបច្ចេកទេសដែលបានបង្ហាញពីកម្រិត"ល្អ" របស់ គណៈគ្រប់គ្រង និងគ្រូបង្រៀន ។ ក្នុងន័យបញ្ជាក់ថាការអនុវត្តការគ្រប់គ្រង មសស របស់គណៈគ្រប់គ្រង គឺមានចំណុចវិជ្ជមានច្រើនក្នុងការងារប្រចាំថ្ងៃ ទាំងការអនុវត្តតាមផែនការ និង ការងារគ្រប់គ្រង់ការបង្រៀន របស់គ្រូបង្រៀន។ ចំណែកសម្រាប់គ្រូបង្រៀនបច្ចេកទេសក៏បានបង្ហាញនូវលទ្ធផលវិជ្ជមានក្នុងការងារបង្រៀន ដែលអាចលើកកម្ពស់ដល់វិជ្ជាជីវៈនៃការបង្រៀនដែលសម្រេចតាមគោលដៅ និង អាចទទួលបាននូវលទ្ធផល សិក្សារបស់សិស្ស មានទាំងគុណភាព និង ប្រសិទ្ធភាពនៃការសិក្សា។ សម្រាប់កម្មករគ្មានជំនាញដែលមិនទាន់ បានចូលរួមក្នុងការអប់រំក្រៅប្រព័ន្ធដើម្បីការអភិវឌ្ឍវិជ្ជាជីវៈគួរតែត្រូវបានលើកទឹកចិត្តឱ្យចូលរួមដោយការ ផ្សាយពាណិជ្ជកម្មតាមកញ្ចក់ទូរទស្សន៍ ថាមនុស្សភាគច្រើនចំណាយពេលមលើវាបន្ទាប់ពីធ្វើការងាររួច ដូច្នេះពួកគេនឹងត្រូវបានជូនដំណឹងអំពីវគ្គសិក្សាដែលមានស្រាប់ ដែលនិងត្រូវបណ្តុះបណ្តាលហើយនិង មជ្ឈមណ្ឌលសិក្សាសហគមន៍ដែលពួកគេអាចទាក់ទងបាននៅជិតផ្ទះរបស់ពួកគេ។

តាមរយៈទិន្នន័យបរិមាណវិស័យ និងគុណវិស័យការសិក្សាស្រាវជ្រាវ លើប្រសិទ្ធភាពនៃការ

គ្រប់គ្រងអប់រំបច្ចេកទេស មសស នៅកំពង់ស្ពឺ ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់ សិស្ស ឬកម្មករគ្មានជំនាញនៅកម្ពុជា គួរតែផ្តល់ដំណោះស្រាយជាក់លាក់លើចំណោទបញ្ហា រួមមានៈ

ក. ផ្តល់ថវិកាជាតិដែលទទួលបានសម្រាប់ការរៀបចំកម្មវិធីបណ្តុះបណ្តាលការអប់រំក្រៅប្រព័ន្ធ ដោយផ្តោតលើគុណភាពនៃកម្មវិធីបណ្តុះបណ្តាលជាជាងបរិមាណ។

ខ. ជ្រើសរើសមនុស្សត្រឹមត្រូវអោយធ្វើការនៅកន្លែងត្រឹមត្រូវ ដូច្នេះការទទួលខុសត្រូវនឹងត្រូវបញ្ជូនទៅឱ្យមនុស្សត្រឹមត្រូវដែរ ដើម្បីការលើកស្ទួយការអនុវត្តអោយកាន់ល្អប្រសើរក្នុងការអប់រំក្រៅប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់កម្មករគ្មានជំនាញនៅកម្ពុជា។

គ. រៀបចំបរិយាកាសសិក្សាដែលគួរជឿជាក់ និងផ្តល់តម្លៃដល់អ្នកសិក្សា ដូច្នេះ កម្មករដែលគ្មានជំនាញត្រូវបានលើកទឹកចិត្តឱ្យចូលរួម និងធ្វើអន្តរកម្មយ៉ាងសកម្មនៅក្នុងវគ្គបណ្តុះបណ្តាលនេះ ពីព្រោះពួកគេមានអារម្មណ៍កក់ក្តៅចំពោះលក្ខណៈគួរអោយគោរពដែលនឹងត្រូវគេផ្តល់អោយ។

ឃ. ដំណើរបែបការវិមជ្ឈការតាមរយៈខ្សែបន្ទាត់នៃការគ្រប់គ្រង ដើម្បីជួយសម្រួលដល់បញ្ហាប្រើប្រាស់ពេលវេលា ដែលត្រូវចំណាយសម្រាប់រាល់ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ទៅលើការរៀបចំការអប់រំក្រៅប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈដល់កម្មករគ្មានជំនាញនៅកម្ពុជា។

ង. រៀបចំការប្រឡងទុកមុនដល់កម្មករដែលគ្មានជំនាញ មុនពេលទទួលយកពួកគេចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញ ដើម្បីវាស់កម្រិតអក្ខរកម្ម និងសង្កេតជំនាញចាំបាច់ ដែលនិងត្រូវធ្វើការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ ដូច្នេះក្នុងនាមជាអ្នករៀបចំការអប់រំក្រៅប្រព័ន្ធអាចរៀបចំសកម្មភាពត្រឹមត្រូវ សម្ភារៈគ្រប់គ្រាន់ក៏ដូចជាបរិយាកាសសិក្សាសមរម្យ សម្រាប់កម្មករគ្មានជំនាញទាំងនោះ។

ច. វាយតម្លៃលើលទ្ធផលនៃការសិក្សាដែលទទួលបានបន្ទាប់ពីវគ្គបណ្តុះបណ្តាលត្រូវបានបញ្ចប់ ដោយការពិនិត្យលើវឌ្ឍនភាព និងការអភិវឌ្ឍដែលបានកើតឡើងនៅក្នុងដំណាក់កាលបណ្តុះបណ្តាលនីមួយៗនិងលទ្ធផលនៃជំនាញដែលនិងត្រូវបណ្តុះបណ្តាលថាតើអ្នកគ្មានជំនាញមិនត្រឹមតែទទួលបានជំនាញការងារជាក់លាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំនាញរស់នៅ

ប្រចាំថ្ងៃទៀតផង ដើម្បីជួយសម្រួលដល់គុណភាពល្អនៃជីវិតជាមួយនឹងកម្រិតជីវភាពរស់នៅប្រសើរដែលត្រូវគិតគូរ។

ឆ. លើកទឹកចិត្តដល់គ្រូបង្រៀននិងមន្ត្រីស្ម័គ្រចិត្តបន្ថែមទៀត ដើម្បីធ្វើការនៅក្នុងការអប់រំក្រៅប្រព័ន្ធ សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ ហើយមនុស្សទាំងនេះគួរតែត្រូវបានគេគោរព ពីព្រោះពួកគេបានវិនិយោគដោយស្មោះត្រង់នូវរាល់ការប្តេជ្ញាចិត្តនិងការខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់ការអប់រំក្រៅប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈដល់កម្មករដែលគ្មានជំនាញ។ រដ្ឋាភិបាលគួរតែដឹងពីគុណប្រយោជន៍របស់ពួកគេដោយផ្តល់នូវប្រាក់ខែបន្ថែមនិងផ្តល់រង្វាន់ពិសេស ដើម្បីធ្វើឱ្យសមិទ្ធផលដែលពួកគេបានធ្វើអោយកាន់តែល្អប្រសើរឡើង ដូច្នេះពួកគេរក្សាខិតខំប្រឹងប្រែងបន្តទៀត។

ជ. វាយតម្លៃការអនុវត្តនៃកម្មវិធីអប់រំក្រៅប្រព័ន្ធទាំងមូល សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីមើលថាតើកម្មវិធីសិក្សាការមានគុណភាពខ្ពស់ដែរឬទេ ការបណ្តុះបណ្តាលគ្រូនិងការគ្រប់គ្រងថវិកាធនធានមនុស្ស សម្ភារៈនិងវិមជ្ឈការ ត្រូវបានប្រើប្រាស់ដើម្បីផ្តល់នូវលទ្ធផលគួរជាទីពេញចិត្តនៃកម្មករដែលគ្មានជំនាញជាមួយនឹងជំនាញជាក់លាក់ ហើយនិងត្រូវបានផ្លាស់ប្តូរទៅជាកម្មករជំនាញវិញ។ វាបញ្ជាក់ថាកម្មវិធីអប់រំក្រៅប្រព័ន្ធ សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់កម្មករដែលគ្មានជំនាញដែលមានប្រសិទ្ធភាព ត្រូវបានគេចាត់ទុកថាជាកម្មវិធីជោគជ័យ លុះត្រាតែកម្មវិធីនេះផលិតអ្នកសិក្សាដែលមានសមត្ថភាពដែលអាចអនុវត្តអ្វីដែលពួកគេបានរៀន ទៅលើការអនុវត្តជាក់ស្តែងសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគេនិងលើកកម្ពស់គុណភាពនៃការរស់នៅ សម្រាប់ការអភិវឌ្ឍនៃសង្គមប្រកប ដោយនិរន្តរភាព។

សរុបសេចក្តីមក ស្របតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល គឺផ្តោតលើការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ហើយក៏មានបញ្ជាក់ថា ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌គឺ ជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងកសាងមូលធនមនុស្សទៅពេលអនាគត ស្របតាមកម្មវិធីសិក្សាអប់រំបច្ចេកទេស ក៏ដូចជាការចូលរួមជំរុញកម្លាំងពលកម្ម

តាមរយៈវិស័យអប់រំ សំដៅលើកម្ពស់ខឿនសេដ្ឋកិច្ចជាតិ ពិសេសក្នុងពេលដែលកម្ពុជាឈានចូលទៅជាប្រទេសចំណូលមធ្យមកម្រិតទាប ហើយបន្តឡើងទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ តាមចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ការអភិវឌ្ឍធនធានមនុស្ស ជាពិសេសយុវជន គឺសំដៅទៅលើការកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញ ការច្នៃប្រឌិត និងនវានុវត្តន៍ គ្រប់ផ្នែក គ្រប់វិស័យ ពិសេសផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ព្រមទាំងសមត្ថភាពក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍ ពោលគឺសំដៅផ្តល់ការសិក្សាពេញមួយជីវិត។ ឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ដូចដែលបានបង្ហាញពីខាងលើ គណៈគ្រប់គ្រងសាលាអប់រំបច្ចេកទេស គួរតែផ្តល់ការបំប៉នបន្ថែមស្តីពីការគ្រប់គ្រងនិងដឹកនាំមជ្ឈមណ្ឌលសហគមន៍ សំដៅធានាដល់តម្រូវការសិក្សារបស់សិស្ស និងគុណភាពលើជំនាញបំពេញតម្រូវការរបស់សហគមន៍។ ប្រធានក្រុមបច្ចេកទេសនៃមជ្ឈមណ្ឌលធនធាន គួរផ្តល់ការបំប៉នស្តីពីស្តង់ដារកម្មវិធីសិក្សាអប់រំបច្ចេកទេស។ ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀនអប់រំបច្ចេកទេស លើជំនាញនៅមជ្ឈមណ្ឌលសហគមន៍គួរតែត្រូវបានពង្រីក និងពង្រឹងបន្ថែមតាមតម្រូវការជាក់ស្តែង ព្រមទាំងផ្តល់កិច្ចគាំទ្រលើកញ្ចប់ថវិកាគាំទ្រគ្រប់គ្រាន់ផងដែរ។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

គុណភាព និងប្រសិទ្ធភាពការអប់រំបច្ចេកទេស បានបង្ហាញតាមរយៈការអនុវត្តការងារគ្រប់គ្រងនៅក្នុងការងាររបស់ មសស ដែលបានដំណើរការលើការបណ្តុះបណ្តាលជំនាញមុខរបរ សម្រាប់ប្រជាពលរដ្ឋគ្រប់រូប សំដៅលើកកម្ពស់គុណភាពនៃការរស់ជាប្រចាំរបស់ប្រជាពលរដ្ឋសហគមន៍។

## ៥.១ សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវ នេះបានផ្តល់ជារបកគំហើញថ្មីមួយ ស្តីពីប្រសិទ្ធភាពនៃការគ្រប់គ្រង មសស ដោយផ្តោតលើលទ្ធផលសិក្សារបស់សិស្សក្នុងខេត្តកំពង់ស្ពឺ។ គោលបំណងសិក្សាស្វែងយល់ពី ប្រសិទ្ធភាពនៃការគ្រប់គ្រង និងបញ្ហាប្រឈមនានា ព្រមទាំងពិនិត្យនិងវាយតម្លៃនៃកម្រិតគុណភាពការបណ្តុះបណ្តាលការអប់រំបច្ចេកទេសរបស់គ្រូបង្រៀននៅ មសស។ វិធីសាស្ត្រស្រាវជ្រាវបានប្រើក្នុងគឺអនុវត្តតាមបែបបរិមាណវិស័យ ដោយធ្វើការប្រមូលទិន្នន័យសិក្សាតាមរយៈកម្រងសំណួរលើ មសស ចំនួន ២៤កន្លែង ដែលមានអ្នកឆ្លើយសំណួរមានចំនួនសរុប ១៥១នាក់ គណៈគ្រប់គ្រងចំនួន ៣៥នាក់ គ្រូចំនួន ៣១នាក់ សិស្សចំនួន ៧០នាក់ និងសហគមន៍ចំនួន ១៥នាក់ក្នុង មសស ទាំងអស់ក្នុងខេត្តដែលកំពុងអនុវត្តការងារ និង សិក្សាការអប់រំបច្ចេកទេសនៅ មសស ក្នុងខេត្តកំពង់ស្ពឺ។ ការវិភាគទិន្នន័យសិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវទិន្នន័យទទួលបានពី គណៈគ្រប់គ្រង ពីគ្រូ ពីសិស្ស ពីសហគមន៍ ឆ្លុះបញ្ចាំងឱ្យឃើញថា ការគ្រប់គ្រង មសស នៅកំពង់ស្ពឺមានចំណុចវិជ្ជមាន ទាក់ទងទៅនឹងធនធានមនុស្ស ដោយផ្តោតទាំង ការដឹកនាំ គ្រូបង្រៀន និង បុគ្គលិកគាំទ្រសេវា។ ដោយឡែកកត្តាធនធាន និង ការចូលរួមគាំទ្រពីភាគីពាក់ព័ន្ធ ចំពោះសកម្មភាព មសស គឺជាចំណុចសំខាន់ ដែលគាំទ្រដល់ការបណ្តុះបណ្តាល អប់រំបច្ចេកទេស និងដំណើរការប្រព្រឹត្តទៅប្រចាំថ្ងៃរបស់ មសស ។ ក្នុងន័យនេះធនធានពុំគ្រប់គ្រាន់ បានធ្វើឱ្យប៉ះពាល់ទាំងគុណភាព ចំណេះដឹង ជំនាញ របស់សិស្សានុសិស្ស ដែលទទួលការ

អប់រំបច្ចេកទេស។ បញ្ហាកង្វះធនធានរូបវន្ត និងការគាំទ្រពីភាគីពាក់ព័ន្ធ គឺជាចំណុចត្រូវការខ្លាំងណាស់ទាំងសហគមន៍មូលដ្ឋាន លោកគ្រូ អ្នកគ្រូ ព្រមទាំងសិស្សានុសិស្សនៅ មសស ។ ការពង្រឹងលើការផ្តត់ផ្គង់សម្ភាររូបវន្ត និង ការគាំទ្រពីភាគីពាក់ព័ន្ធដទៃទៀត គឺយន្តការមួយ ជួយពង្រឹងដល់ការងារអប់រំបច្ចេកទេសមានភាពល្អប្រសើរ សំដៅលើកកម្ពស់គុណភាព ប្រសិទ្ធភាពជំនាញបច្ចេកទេស ដែលនាំឱ្យធានាបាននូវការគ្រប់គ្រង ទទួលបានទាំងប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងយុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំក៏ដូចជាស្របតាមគោលនយោបាយស្តីពីការអប់រំបច្ចេកទេស ដើម្បីអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា។

ជារួមប្រសិទ្ធភាពនៃការគ្រប់គ្រង លើការអនុវត្តការងារអប់រំបច្ចេកទេសនៅ មសស បានបង្ហាញពីកម្រិតល្អនៃការងាររៀបចំផែនការសម្រាប់ការអនុវត្ត ដែលបង្កលទ្ធភាពដល់ ការសិក្សាជំនាញបច្ចេកទេសរបស់សិស្ស ការអនុវត្តការបង្រៀនរបស់គ្រូដោយគោរពតាមគោលការណ៍បណ្តុះបណ្តាលជំនាញ និងមូលធនមនុស្សពេញលេញ និងបន្តអភិវឌ្ឍន៍កម្មវិធីអប់រំបច្ចេកទេសនៅតាម មសស ដើម្បីលើកកម្ពស់កម្រិតជំនាញវិជ្ជាជីវៈឱ្យមានគុណភាព និងស្របនឹងទីផ្សារការងារដែលជាតម្រូវការរបស់ប្រទេស និងវិនិយោគទុន។

យោងលើលទ្ធផលខាងលើ អ្នកស្រាវជ្រាវសង្ឃឹមថា ការសិក្សានេះអាចជួយជំរុញលើការអនុវត្តលើការងារអប់រំបច្ចេកទេសឱ្យកាន់តែល្អប្រសើរ និងលើទឹកចិត្តដល់អ្នកគ្រប់គ្រង គ្រូបង្រៀន សិស្ស និងភាគីពាក់ព័ន្ធ ចូលរួមរួមដោះស្រាយរាល់បញ្ហាប្រឈមនានា ដើម្បីលើកកម្ពស់ការងារបណ្តុះបណ្តាលជំនាញឱ្យមានប្រសិទ្ធផល នៃជំនាញវិជ្ជាជីវៈ ឆ្លើយតបនឹងបរិបទនៃបដិវត្តន៍ឧស្សាហកម្ម ៤.០ ព្រមទាំងអាចឆ្លើយតបតាមតម្រូវការទីផ្សារការងារ និងចូលរួមអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់ប្រទេស។

## ៥.២ សំណូមពរ

តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី ប្រសិទ្ធភាពនៃការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដោយផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សារបស់សិស្សក្នុងខេត្តកំពង់ស្ពឺ បានរកឃើញជាលទ្ធផលពីចំណុចល្អនៃការគ្រប់គ្រងមជ្ឈមណ្ឌល និងបញ្ហាប្រឈមមួយចំនួន ដែលគ្រូបង្រៀន

កំពុងជួបប្រទះ ព្រមជាមួយការរក្សាគម្លាតសង្គម (Covid-19) ក្នុងដំណើរការបង្រៀនការអប់រំបច្ចេកទេស ដែលទាមទារឱ្យមានកិច្ចសហការ ការជំរុញលើកកម្ពស់និងពង្រឹងបន្ថែមពីដៃគូអភិវឌ្ឍន៍ ក៏ដូចជា សហគមន៍ សំដៅធានាបានការប្រកបការងាររបស់សិក្សា លើជំនាញដែលបានសិក្សា និង ចំណេះដឹងតាម ការអប់រំបច្ចេកទេស។ អ្នកសិក្សាស្រាវជ្រាវ សូមលើកនូវសំណូមពរដូចខាងក្រោមៈ

**ក. ក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ**

ស្ថិតក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩ ការរៀនតាមអនឡាញ និងការសិក្សាពីចម្ងាយ កម្មវិធីអប់រំក្រៅប្រព័ន្ធមានតែកម្មវិធីអក្ខរកម្មប៉ុណ្ណោះ ដែលបានរៀបចំវីដេអូសិក្សាពីចម្ងាយ។ លើកកម្ពស់ ការបង្រៀនតាមអនឡាញ គឺជាបរិបទថ្មីមួយដែលអាចទាក់ទាញសិស្សឱ្យរៀនបន្ថែម។

- នាយកដ្ឋានអប់រំក្រៅប្រព័ន្ធបន្តចុះពិនិត្យតាមដានផ្តោតលើសកម្មភាពរៀន និងបង្រៀន ដោយ ប្រកាន់ភ្ជាប់នូវវិធានការការពារជំងឺកូវីដ១៩ ដើម្បីសុខសុវត្ថិភាពដល់កម្មករ កម្មការិនី។
- បន្តជំរុញគ្រូបង្រៀនអប់រំបច្ចេកទេសចូលរួម រិះរកវិធីសាស្ត្រ និងបច្ចេកទេសលើវិធីសាស្ត្រ បង្រៀន ពីចម្ងាយ មានភាពទាក់ទាញ គុណភាព និងប្រសិទ្ធភាពខ្ពស់ពីអ្នកសិក្សា។
- បង្កលទ្ធភាពល្អប្រសើរលើលំហូរថវិកាគាំទ្រ ឆ្លើយតបភាពចាំបាច់នៃការចំណាយ ដើម្បីធានាថា ថវិកាទាន់នឹងតម្រូវការនៃការប្រើប្រាស់របស់ មសស។

**ខ. គណៈគ្រប់គ្រង និងគ្រូបង្រៀនការអប់រំបច្ចេកទេស**

- ធ្វើផែនការប្រតិបត្តិ និង ផែនការថវិកា ដោយមានបង្ហាញនូវសូចនាករលទ្ធផលរំពឹងទុក
- ចុះប្រមូលព័ត៌មានពីតម្រូវការសហគមន៍ដើម្បី រៀបចំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ
- ធ្វើផែនការ និងកម្មវិធីបង្រៀន ឱ្យច្បាស់លាស់ និងមានបង្ហាញពីលទ្ធផលរំពឹងទុក
- ធ្វើវគ្គបំប៉នខ្លី ឡើងវិញនៅជំនាញណាមួយ ដែលសិស្សជំនាញស្នើសុំបំប៉នឡើងវិញ
- ប្រជុំផ្សព្វផ្សាយ និងធ្វើរបាយការណ៍វឌ្ឍនភាព ជាប្រចាំ
- ចូលរួមប្រជុំ គ្រប់រូបភាពជាគណៈគ្រប់គ្រង ទាំងក្នុង មសស និងនៅតាមសហគមន៍
- ពិនិត្យ និងវាយតម្លៃការ ការបណ្តុះបណ្តាលជំនាញរបស់គ្រូ និងសិស្សជំនាញជាចាំ និង

តាមដានការអនុវត្តជាក់ស្តែង និងលើកទឹកចិត្តសិស្សក្នុងការសិក្សាផ្ទាល់។

**គ. សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត**

